ខេមា មីក្រូហិរញ្ញវត្ថុ លីមីតធីត
CAMMA MICROFINANCE LIMITED

# របាយការណ៍ប្រចាំឆ្នាំ២០២៣

ឯកសារសាធារណៈ

# មាតិកា


ទស្សនវិស័យ និងបេសកកម្ម ១
គុណតម្លៃស្នូល ១
វិសាលភាពប្រតិបត្តិការ ១
ទិន្នន័យសំខាន់ៗ ២

## ១

**ប្រវត្តិ ខេមា** ៤
សាវតារបស់ ខេមា ៥
ព្រឹត្តិការណ៍សំខាន់ៗ ៦
ម្ចាស់កម្ចី និងដៃគូ ៧
ចំណាប់អារម្មណ៍របស់ប្រធានក្រុមប្រឹក្សាភិបាល ៨
របាយការណ៍របស់អគ្គនាយកប្រតិបត្តិស្តីទី ១១

## ២

**អភិបាលកិច្ច** ១៤
រចនាសម្ព័ន្ធគ្រប់គ្រង ១៥
គណៈគ្រប់គ្រង ១៦
ការគ្រប់គ្រងហានិភ័យ និងការត្រួតពិនិត្យផ្ទៃក្នុង ២០

## ៣

**ទិដ្ឋភាពទូទៅ នៃអាជីវកម្ម** ២២
ផលិតផល និងសេវាកម្ម ២៣
សមិទ្ធផលអាជីវកម្ម ២៥
សេចក្តីសង្ខេបអំពីសមិទ្ធផលហិរញ្ញវត្ថុ ២៧
បណ្តុះបណ្តាល និងអភិវឌ្ឍន៍សមត្ថភាពបុគ្គលិក ៣០
អំពីអតិថិជន ៣២

## ៤

**ការរីកចម្រើនប្រកបដោយនិរន្តរភាព** ៣៤
កិច្ចការពារបរិស្ថាន សង្គម និងអភិបាលកិច្ច ៣៥
អនុលោមភាពគោលការណ៍ការពារអតិថិជន ៣៦
ទំនួលខុសត្រូវក្នុងសង្គម ៣៨
ការលើកកម្ពស់សមភាពយេនឌ័រ ៣៩
ផលិតផលដែលជួយលើកកម្ពស់បរិស្ថាន និងសង្គម ៤០
អតិថិជនរបស់ ខេមា ៤១

## ៥

**របាយការណ៍ហិរញ្ញវត្ថុ និង**
**របាយការណ៍របស់សវនករឯករាជ្យ** ៤២
របាយការណ៍របស់ក្រុមប្រឹក្សាភិបាល ៤៣
របាយការណ៍របស់សវនករឯករាជ្យ ៤៦
របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ ៤៩
របាយការណ៍លទ្ធផលលម្អិត ៥០
របាយការណ៍ស្តីពីបម្រែបម្រួលមូលធន ៥១
របាយការណ៍លំហូរទឹកប្រាក់ ៥២

**បណ្តាញសាខា** ៥៣

# ទស្សនវិស័យ

ក្លាយជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដ៏មានទំនុកចិត្ត ក្នុងការផ្តល់នូវសេវាហិរញ្ញវត្ថុ ប្រកបដោយបរិយាប័ន្ន និងភាពច្នៃប្រឌិតដល់ប្រជាជនកម្ពុជា និងរក្សាបាននូវអត្ថប្រយោជន៍ជូនអតិថិជន បុគ្គលិក ភាគទុនិក និងសង្គមជាតិទាំងមូល។

# បេសកកម្ម

ផ្តល់នូវសេវាហិរញ្ញវត្ថុប្រកបដោយភាពច្នៃប្រឌិត និងមានឥទ្ធិពលដល់សហគមន៍ សហគ្រាសខ្នាតតូចនិងមធ្យម និងកសិករ ជាពិសេសស្ត្រី ប្រកបដោយប្រសិទ្ធភាព និរន្តរភាព និងការទទួលខុសត្រូវខ្ពស់។

# តម្លៃស្នូល

**តម្លាភាព៖** ពួកយើងធានាផ្តល់នូវព័ត៌មានពេញលេញអំពីផលិតផលជូនអតិថិជនប្រកបដោយតម្លាភាព។

**សុចរិតភាព៖** ពួកយើងធានានូវភាពស្មោះត្រង់ និងក្រមសីលធម៌ខ្ពស់របស់បុគ្គលិកក្នុងការផ្តល់ផលិតផល និងសេវាកម្មជូនអតិថិជន។

**សេវាកម្មដ៏ល្អបំផុត៖** ពួកយើងប្តេជ្ញាក្នុងការផ្តល់សេវាកម្មដ៏ល្អបំផុតប្រកបដោយប្រសិទ្ធភាព និងឆាប់រហ័ស។

**ភាពច្នៃប្រឌិត៖** ពួកយើងព្យាយាមបង្កើតនូវភាពប្លែក និងអត្ថប្រយោជន៍បន្ថែម (Add Value) ទៅលើផលិតផល និងសេវាកម្ម ដើម្បីឆ្លើយតបទៅនឹងតម្រូវការអតិថិជន។

**វិជ្ជាជីវៈ៖** ពួកយើងធានានូវការផ្តល់សេវាប្រកបដោយវិជ្ជាជីវៈខ្ពស់ និងដោយការគោរពជូនចំពោះអតិថិជន។

# វិសាលភាពប្រតិបត្តិការ




ចំណាំ៖ ផែនទីនេះប្រើសម្រាប់តែបង្ហាញតំបន់ប្រតិបត្តិការរបស់ គ្រឹះស្ថាន ខេមា តែប៉ុណ្ណោះ។

| សូចនាករសំខាន់ៗ | ២០២២ | ២០២៣ |
|---|---|---|
| រាជធានី-ខេត្ត ដែលកំពុងមានប្រតិបត្តិការ | ៥ | ៥ |
| ក្រុង-ស្រុក-ខណ្ឌ ដែលកំពុងមានប្រតិបត្តិការ | ៤៤ | ៥៣ |
| សង្កាត់-ឃុំ ដែលកំពុងមានប្រតិបត្តិការ | ២៣៦ | ២៨៧ |
| ភូមិ ដែលកំពុងមានប្រតិបត្តិការ | ៧៨៥ | ៨៩១ |
| ចំនួនសាខាសរុប | ៥ | ៧ |
| ចំនួនបុគ្គលិកសរុប | ១៧០ | ២០៣ |
| ចំនួនបុគ្គលិកជាភ្នាក់ងារឥណទាន | ៥៦ | ៧៨ |

# ទិន្នន័យសំខាន់ៗ

| សមិទ្ធផល ផ្នែកប្រតិបត្តិការ | ២០២១ | ២០២២ | ២០២៣ | ប្រែប្រួល |
|---|---|---|---|---|
| សរុបការិយាល័យប្រតិបត្តិការ | ៤ | ៥ | ៧ | ៤០% |
| ចំនួនបុគ្គលិក | ១២៨ | ១៧០ | ២០៣ | ១៩% |
| ចំនួនបុគ្គលិកជាភ្នាក់ងារឥណទាន | ៤៣ | ៥៦ | ៧៨ | ៣៩% |
| ចំនួនអតិថិជនសកម្ម | ១.៥៣៥ | ២.១៧៧ | ៣.០២៤ | ៣៩% |
| ផលប័ត្រឥណទាន (ដុល្លារ) | ១៥.៥០២.៨១៦ | ២៣.៦៨១.៨៧៧ | ២៧.០៣០.៩៧៤ | ១៤% |

| សមិទ្ធផល ផ្នែកហិរញ្ញវត្ថុ | ២០២១ | ២០២២ | ២០២៣ | ប្រែប្រួល |
|---|---|---|---|---|
| ទ្រព្យសកម្ម | ១៦.៥២៦.៣២៥ | ២៤.៨៤៨.៣៣៣ | ២៧.៦៧៨.៧៧២ | ១១% |
| ទ្រព្យអកម្ម | ៩.៥៩៧.៥៣៤ | ១៧.៧៧៥.១៥២ | ១៩.៣៣២.១៩៧ | ៩% |
| ទ្រព្យម្ចាស់ភាគទុនិក | ៦.៩២៨.៧៩១ | ៧.០៧៣.១៨០ | ៨.៣៤៦.៥៧៥ | ១៨% |
| មូលធនវិនិយោគ | ៥.៥៩៣.០០០ | ៥.៥៩៣.០០០ | ៧.៣៤៣.០០០ | ៣១% |
| ប្រាក់ចំណេញសុទ្ធរក្សាទុក | ៧៥៤.៧៤៨ | ៩៤០.៤៣២ | ២៦០.៣៨០ | (៧២%) |
| ទុនបម្រុងបទប្បញ្ញត្តិ | ៥៨១.០៤៣ | ៥៣៩.៧៤៩ | ៧៤៣.១៩៥ | ៣៨% |
| ចំណូលការប្រាក់ | ២.១៤៦.៤៤៣ | ២.៧៩០.៤៩១ | ៣.៧៣៣.៣៣១ | ៣៤% |
| ចំណាយការប្រាក់ | (៥៣៥.៣៦៦) | (៨០០.៦២៦) | (១.២២៣.២៥០) | ៥៣% |
| ចំណូលការប្រាក់សុទ្ធ | ១.៦១១.០៧៧ | ១.៩៨៩.៨៦៥ | ២.៥១០.០៨១ | ២៦% |
| សំវិធានធនឥណទានស្តង់ដារ | | | | |
| ឥណទានអាក្រក់ និងសង្ស័យ | (៨០.៥៨០) | (២៥.៣០៤) | (៣០.៨៤២) | ២២% |
| ចំណូលការប្រាក់សុទ្ធបន្ទាប់ពី | | | | |
| សំវិធានធនឥណទានអាក្រក់ និងសង្ស័យ | ១.៥៣០.៤៩៧ | ១.៩៦៤.៥៦១ | ២.៤៧៩.២៣៩ | ២៦% |
| ចំណូលមិនមែនការប្រាក់ | ១៤៩.១០៥ | ១០២.០៣២ | ១២៧.៥០២ | ២៥% |
| ចំណាយបុគ្គលិក | (៩៥០.៥៧៦) | (១.២២៩.២៩៧) | (១.៥៦៦.៩៩៧) | ២៧% |
| ចំណាយប្រតិបត្តិការ និងផ្សេងៗ | (៣៤៥.១១៤) | (៥៨៧.៦៥១) | (៦១៦.៤២០) | ៥% |
| ចំណាយលើការដករំលស់ | (៤២.៦៦០) | (៤៣.៧០២) | (៧២.៩៥៧) | ៦៧% |
| ប្រាក់ចំណេញ/ខាតមុនបង់ពន្ធ | ៣៤១.២៥២ | ២០៥.៩៤៣ | ៣៥០.៣៦៦ | ៧០% |
| ពន្ធលើប្រាក់ចំណេញ | (៧៦.១៨៦) | (៦១.៥៥៣) | (៧៦.៩៧២) | ២៥% |
| ប្រាក់ចំណេញក្នុងឆ្នាំ | ២៦៥.០៦៦ | ១៤៤.៣៩០ | ២៧៣.៣៩៤ | ៨៩% |
| ប្រាក់ចំណេញធៀបនឹងទ្រព្យសកម្ម | ១,៦០% | ០,៦០% | ១,០៣% | ៧៣% |
| ប្រាក់ចំណេញធៀបនឹងទ្រព្យម្ចាស់ | ៣,៨៣% | ២,០៤% | ៣,៦២% | ៧៧% |
| ទំហំហានិភ័យឥណទាន | ៣,៤៤% | ៣,៩២% | ៥,៥៤% | ៤១% |
| លទ្ធភាពអាចប្រតិបត្តិការខ្លួនឯង | ១០៩,៨៣% | ១០៣,៨៧% | ១០៧,២៥% | ៣% |

## សមាមាត្រសមតុល្យឥណទានតាមវិស័យ




## ចំនួនអតិថិជនតាមបណ្ដាសាខា




## សមាមាត្រចំនួនអតិថិជនតាមភេទ




## សមាមាត្រចំនួនអតិថិជនតាមរយៈពេលកម្ចី



# ១

# ប្រវត្តិ ខេមា

- សារតារបស់ ខេមា
- ព្រឹត្តិការណ៍សំខាន់ៗ
- ម្ចាស់កម្មី និងដៃគូ
- ចំណាប់អារម្មណ៍របស់ប្រធានក្រុមប្រឹក្សាភិបាល
- របាយការណ៍របស់អគ្គនាយកប្រតិបត្តិស្តីទី

# សារតារបស់ ខេមា

គ្រឹះស្ថាន ខេមា មីក្រូហិរញ្ញវត្ថុ លីមីតធីត ត្រូវបានផ្តួចផ្តើមគំនិត និងបង្កើតឡើងនៅក្នុងឆ្នាំ២០០៨ ដែលក្នុងពេលនោះ ខេមា គឺជាប្រតិបត្តិករឥណទានឯកជនមួយដែលបានធ្វើប្រតិបត្តិការ និងសេវាផ្តល់ឥណទានជូនប្រជាពលរដ្ឋកម្ពុជា ក្នុងរាជធានីភ្នំពេញ និងខេត្តកណ្តាល។

តម្រូវការឥណទានដើម្បីពង្រីកមុខរបរ បង្កើនប្រាក់ចំណូល និងលើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ប្រជាពលរដ្ឋបានកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ។ អតិថិជនដែលទទួលបានឥណទានក៏មានជីវភាពធូរធារ និងមានការអភិវឌ្ឍជាលំដាប់។ ដើម្បីឆ្លើយតបនឹងកំណើននៃតម្រូវការឥណទាន ក៏ដូចជាការចូលរួមចំណែក លើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋចាំបាច់តម្រូវឱ្យខេមាពង្រីកវិសាលភាពប្រតិបត្តិការ បង្កើនទំនុកចិត្ត ភាពជឿជាក់ និងពង្រឹងគុណភាពសេវាកម្មរបស់ខ្លួន។

កត្តាទាំងនេះជំរុញឱ្យគ្រឹះស្ថាន ខេមា ប្រែក្លាយពីប្រតិបត្តិករឥណទានឯកជន មកជាគ្រឹះស្ថាន ខេមា មីក្រូហិរញ្ញវត្ថុ លីមីតធីត ដ៏មានទំនុកចិត្តមួយតាមរយៈការចុះបញ្ជីទៅជាក្រុមហ៊ុនទទួលខុសត្រូវមានកម្រិតនៅក្រសួងពាណិជ្ជកម្ម ដែលមានវិញ្ញាបនបត្រចុះបញ្ជីលេខ Co.0700 KH/2010 នៅថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១០ ជាមួយនឹងដើមទុនចុះបញ្ជីចំនួន ២០០.០០០ (ពីររយពាន់) ដុល្លារអាមេរិក។

បន្ទាប់មក នៅថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១០ គ្រឹះស្ថាន ខេមា ទទួលបានអាជ្ញាបណ្ណផ្លូវការពី ធនាគារជាតិនៃកម្ពុជា គឺជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលមានសិទ្ធិពេញលេញក្នុងការផ្តល់ឥណទានជូនអតិថិជន។ គ្រឹះស្ថាន ខេមា បានរៀបចំខ្លួនឱ្យក្លាយជា គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដែលមានអភិបាលកិច្ចល្អ មានប្រព័ន្ធស្តង់ដារការងារត្រឹមត្រូវ មានគោលការណ៍ការពារអតិថិជនច្បាស់លាស់ និងមានការប្តេជ្ញាចិត្តខ្ពស់ក្នុងការផ្តល់សេវាហិរញ្ញវត្ថុ ប្រកបដោយទំនួលខុសត្រូវ និងមានផលជះវិជ្ជមានចំពោះសង្គម និងបរិស្ថាន ។

គិតត្រឹមបំណាច់ឆ្នាំ២០២៣ គ្រឹះស្ថាន ខេមា មានដើមទុនចុះបញ្ជីចំនួន ៧.៣៤៣.០០០ដុល្លារ មានសាខាប្រតិបត្តិការចំនួន ៧ មានបុគ្គលិក ២០៣នាក់ បាននិងកំពុងបម្រើសេវាកម្មដល់អតិថិជនចំនួន ៣.០២៤នាក់ ជាមួយនឹងផលប័ត្រឥណទាន ២៧.០៣០.៩៧៤ដុល្លារអាមេរិក។

នៅថ្ងៃខាងមុខ គ្រឹះស្ថាន ខេមា នឹងបន្តពង្រីកបណ្តាញប្រតិបត្តិការរបស់ខ្លួនទៅដល់ទីជនបទ និងប្រជុំជន ព្រមទាំងអភិវឌ្ឍផលិតផល និងសេវាហិរញ្ញវត្ថុថ្មីៗបន្ថែមទៀត ដើម្បីឆ្លើយតបនឹងតម្រូវការរបស់អតិថិជន។ ជាមួយគណៈគ្រប់គ្រងដែលមានបទពិសោធន៍ច្រើនឆ្នាំ អភិបាលកិច្ចល្អ និងការប្តេជ្ញាចិត្តក្នុងសកម្មភាពសង្គម គ្រឹះស្ថាន ខេមា បានត្រៀមខ្លួនជាស្រេចក្នុងការបន្តពង្រីកបណ្តាញប្រតិបត្តិការ និងឥទ្ធិពលវិជ្ជមានរបស់ខ្លួននៅទូទាំងប្រទេស។

# ព្រឹត្តិការណ៍សំខាន់ៗ



**២០២៣**

- គ្រឹះស្ថាន ខេមា ទទួលបានអាជ្ញាបណ្ណក្នុងការបើកដំណើរការសាខាស្រុកស្អាង និងសាខាស្រុកកំពង់ត្រាច។
- គ្រឹះស្ថាន ខេមា បានបង្កើតឱ្យមានឥណទានបៃតង និងឥណទានទឹកស្អាតនិងអនាម័យ។

**២០២២**

- គ្រឹះស្ថាន ខេមា បានទទួលអាជ្ញាបណ្ណក្នុងការបើកដំណើរការ សាខាខេត្តកំពង់ស្ពឺ។
- គ្រឹះស្ថាន ខេមា បានបង្កើតឱ្យមានឥណទានកសិកម្ម និងឥណទានគ្មានទ្រព្យធានា។

**២០២១**

គ្រឹះស្ថាន ខេមា បានបង្កើនដើមទុនចុះបញ្ជីដល់ចំនួន ៥.៥៩៣.០០០ដុល្លារ (ប្រាំលានប្រាំរយកៅសិបបីពាន់ដុល្លារអាមេរិក)។

**២០២០**

គ្រឹះស្ថាន ខេមា បានទទួលអាជ្ញាបណ្ណក្នុងការបើកដំណើរការសាខាស្រុកគងពិសី។

**២០១៩**

គ្រឹះស្ថាន ខេមា ក៏បានបង្កើនដើមទុនចុះបញ្ជីដល់ចំនួន ៣.៥៩៣.០០០ដុល្លារ (បីលានប្រាំរយកៅសិបបីពាន់ដុល្លារអាមេរិក)។

**២០១៧**

គ្រឹះស្ថាន ខេមា បានទទួលអាជ្ញាបណ្ណក្នុងការបើកដំណើរការសាខាក្រុងតាខ្មៅ។

**២០១៦**

គ្រឹះស្ថាន ខេមា បានទទួលអាជ្ញាបណ្ណក្នុងការបើកដំណើរការសាខាស្រុកអង្គស្នួល។

**២០១៥**

គ្រឹះស្ថាន ខេមា បានបង្កើនដើមទុនចុះបញ្ជីដល់ចំនួន ២.១០៣.០០០ដុល្លារ (ពីរលានមួយរយបីពាន់ដុល្លារអាមេរិក)។

**២០១០**

- ខេមា បានទទួលអាជ្ញាបណ្ណជា គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ពី ធនាគារជាតិនៃកម្ពុជា។
- គ្រឹះស្ថាន ខេមា បានចុះបញ្ជីដើមទុនសរុបចំនួន ២០០.០០០ ដុល្លារ (ពីរយពាន់ដុល្លារអាមេរិក)។

**២០០៨**

គ្រឹះស្ថាន ខេមា មីក្រូហិរញ្ញវត្ថុ លីមីតធីត ត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០០៨ ដែលក្នុងពេលនោះខេមាគឺជាប្រតិបត្តិករឥណទានឯកជនមួយដែលបានធ្វើប្រតិបត្តិការ ផ្តល់សេវាឥណទានជូនប្រជាពលរដ្ឋកម្ពុជា ក្នុងរាជធានីភ្នំពេញ និងខេត្តកណ្តាល។

# ម្ចាស់កម្ចី និងដៃគូ

| | |
|---|---|
| | ធនាគារ កាថេ យូណៃធីត (កម្ពុជា) ចំកាត់ |
| | ធនាគារ វឌ្ឍនៈ |
| | ធនាគារពាណិជ្ជកម្មក្រៅប្រទេស នៃកម្ពុជា |
| | ធនាគារ ជីប ម៉ុង ខមមើសល ប៊ែង ម.ក |
| | ធនាគារសហគ្រាសធុនតូច និងមធ្យម កម្ពុជា ម.ក |
| | ធនាគារ ស្ថាបនា ភីអិលស៊ី |
| | ធនាគារឯកទេសវីង (ខេមបូឌា) លីមីតធីត |

| | | | |
|---|---|---|---|
| | ធនាគារជាតិនៃកម្ពុជា | | ធនាគារ អេស៊ីលីដា ភីអិលស៊ី |
| | សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា | | ធនាគារ អ អេច ប៊ី (ខេមបូឌា) ម.ក |
| | ក្រុមហ៊ុនក្រេឌីត ប្យូរ៉ូ (ខេមបូឌា) ខូអិលធីឌី | | ធនាគារ វឌ្ឍនៈ អាស៊ី ចំកាត់ |
| | សាជីវកម្មធានាឥណទានកម្ពុជា | | គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អេ អឹម ខេ ភីអិលស៊ី |
| | អង្គការ Water.org | | ទ្រូម៉ាន់នី (ខេមបូឌា) ភីអិលស៊ី |

# ចំណាប់អារម្មណ៍របស់ប្រធានក្រុមប្រឹក្សាភិបាល

## លោកស្រី ឌិត នីតា



ក្នុងឆ្នាំ២០២៣ ស្ថានភាពសេដ្ឋកិច្ចពិភពលោកក្រោយពីការងើបឡើងវិញពីវិបត្តិកូវីដ-១៩ ជួបបញ្ហាប្រឈមជាច្រើនដែលបានដាក់បន្ទុកដល់ពាណិជ្ជកម្ម ការប្រើប្រាស់ និងការវិនិយោគសកល។ ជាអាទិ៍ ការបន្តដំឡើងអត្រាការប្រាក់គោលដើម្បីកាត់បន្ថយអតិផរណា ការរួមតូចនៃលំហនយោបាយសារពើពន្ធ ការកើនឡើងហានិភ័យនៃការបែងចែកភូមិសាស្ត្រនយោបាយនិងវិបត្តិអចលនទ្រព្យ និងភាពទន់ខ្សោយនៃតម្រូវការក្នុងស្រុកនៅប្រទេសចិន។ ក្នុងស្ថានភាពនេះ កំណើនសេដ្ឋកិច្ចពិភពលោកត្រូវបានរំពឹងថាអាចសម្រេចបានទាបជាងឆ្នាំ២០២២។

ក្នុងស្ថានភាពដែលកំណើនសេដ្ឋកិច្ចពិភពលោកត្រូវបានព្យាករថាបន្តថយចុះបន្តិច ការងើបឡើងវិញនៃសេដ្ឋកិច្ចកម្ពុជាបានប្រឈមនឹងសម្ពាធមួយចំនួន ពិសេសការនាំចេញនូវផលិតផលកាត់ដេរ កំណើននៃវិស័យសំណង់ និងអចលនទ្រព្យ។ យោងលើរបាយការណ៍ប្រចាំឆ្នាំ២០២៣ ចេញផ្សាយដោយ ធនាគារជាតិនៃកម្ពុជា បានបង្ហាញថាសេដ្ឋកិច្ចកម្ពុជាបន្តមានកំណើនក្នុងអត្រា ៥,៥% ខ្ពស់ជាងឆ្នាំ២០២២ បន្តិច (៥,៣%)។ កំណើននេះ គាំទ្រដោយការងើបឡើងវិញនៃវិស័យទេសចរណ៍ កំណើនការនាំចេញផលិតផលមិនមែនកាត់ដេរ កំណើនតម្រូវការក្នុងស្រុក និងការអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមដ៏ត្រឹមត្រូវរបស់រាជរដ្ឋាភិបាលកម្ពុជា។

ស្ថិតក្នុងវឌ្ឍនភាពសេដ្ឋកិច្ចទាបក្នុងតំបន់ និងក្នុងប្រទេស គ្រឹះស្ថាន ខេមា បានអនុវត្តផែនការយុទ្ធសាស្ត្រដោយប្រុងប្រយ័ត្ន និងអាចរក្សាបាននូវភាពធន់របស់ខ្លួន ដែលស្តែងចេញតាមរយៈកំណើនផលប័ត្រឥណទាន ១៤% អតិថិជន ៣៩% និងកំណើនវិជ្ជមាននៃអនុបាតប្រាក់ចំណេញធៀបនឹងទ្រព្យសកម្មដោយរក្សាបាននូវអត្រាហានិភ័យឥណទានទាបជាងអត្រាហានិភ័យឥណទានជាមធ្យមក្នុងវិស័យ និងសមិទ្ធផលផ្សេងទៀតដូចមានបង្ហាញក្នុងរបាយការណ៍ប្រចាំឆ្នាំ២០២៣។

នវានុវត្តន៍ និងបច្ចេកវិទ្យា គឺជាមូលដ្ឋានគ្រឹះនៃយុទ្ធសាស្ត្ររបស់គ្រឹះស្ថាន ខេមា ។ ឆ្នាំកន្លងទៅ ខេមា បានបង្កើននូវប្រសិទ្ធភាពប្រតិបត្តិការឥណទានឌីជីថល ទាញយកផល

វិជ្ជមានពីការប្រើប្រាស់នូវកម្មវិធីរៀនតាមបែបឌីជីថល (CAMMA Digital Leaning App) និងបង្កើតមាតិកាថ្មីៗក្នុងការធ្វើទីផ្សារតាមប្រព័ន្ធឌីជីថល។ ប្រព័ន្ធមជ្ឈមណ្ឌលទំនាក់ទំនង (Contact Center System) ត្រូវបានដាក់ឱ្យអនុវត្តដោយជោគជ័យនៅត្រីមាសទី ៣ ឆ្នាំមុន ក្នុងន័យធ្វើឱ្យប្រសើរឡើងនូវការផ្តល់សេវាអតិថិជនតាមទូរស័ព្ទ និងបណ្តាញទំនាក់ទំនងសង្គមរបស់គ្រឹះស្ថាន។ ប្រព័ន្ធអនុម័តឥណទាន (Loan Originating System) ក៏ត្រូវបានអភិវឌ្ឍរួចរាល់ ដោយគ្រោងដាក់ឱ្យដំណើរការក្នុងឆ្នាំ ២០២៤ ដែលជាកាតាលីករជម្រុញល្បឿនសេវាកម្មឥណទានរបស់គ្រឹះស្ថានឈានឡើងមួយកម្រិត។ ទន្ទឹមនឹងនេះកម្មវិធីគ្រប់គ្រងធនធានមនុស្សតាមបែបឌីជីថលក៏ត្រូវបានអភិវឌ្ឍផងដែរ។

គ្រឹះស្ថាន ខេមា ផ្តោតការយកចិត្តទុកដាក់ទៅលើកិច្ចការពារអតិថិជន។ ខចែងស្តង់ដារនៃកិច្ចសន្យាឥណទានដែលផ្តួចផ្តើមដោយ ធនាគារជាតិនៃកម្ពុជា និងបង្កើតឡើងដោយសមាគមធនាគារនៅកម្ពុជា និងសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជាត្រូវបានដាក់ឱ្យអនុវត្តដើម្បីធានាពីសិទ្ធិ និងអត្ថប្រយោជន៍របស់អតិថិជន។ គ្រឹះស្ថានបានបន្តពង្រឹងការអនុវត្តយន្តការបណ្តឹងតវ៉ារបស់អតិថិជន ដោយតម្លើងការតាមដានត្រួតពិនិត្យដល់កម្រិតក្រុមប្រឹក្សាភិបាល និងគ្រោងអភិវឌ្ឍប្រព័ន្ធគ្រប់គ្រងបណ្តឹងតវ៉ារបស់អតិថិជនតាមប្រព័ន្ធអេឡិកត្រូនិកនៅក្នុងឆ្នាំ ២០២៤។ ក្នុងការប្តេជ្ញាចិត្តរបស់ខ្លួន ខេមា បានចាត់តាំងឱ្យមានបុគ្គលិកទទួលខុសត្រូវលើការងារ កិច្ចការពារអតិថិជន អនុវត្តផែនការសកម្មភាពសង្គមនិងបរិស្ថាន ធ្វើការវាយតម្លៃការអនុវត្តកិច្ចការពារអតិថិជនដោយខ្លួនឯងមុននឹងឈានទៅដាក់ពាក្យស្នើសុំវិញ្ញាបនបត្រកិច្ចការពារអតិថិជនផ្លូវការពីក្រុមហ៊ុនវាយតម្លៃអន្តរជាតិដែលជាគោលដៅរបស់គ្រឹះស្ថាននៅឆ្នាំបន្ទាប់។

ផលិតផលឥណទានបៃតង និងឥណទានទឹកស្អាត និងអនាម័យដែលជាផលិតផលឥណទានសង្គមត្រូវបានដាក់ឱ្យដំណើរការនៅត្រីមាសទី៣ នៃឆ្នាំ២០២៣ និងសម្រេចបានលទ្ធផលតាមផែនការគ្រោងទុក។ ផលិតផលថ្មីនេះបានផ្តល់ឱកាសឱ្យគ្រឹះស្ថាន ខេមា ទទួលបានភាពជាដៃគូជាមួយអង្គការអន្តរជាតិ Water.org រួមជាកម្លាំងលើកម្ពស់សុខុមាលភាព និងជីវភាពរស់នៅរបស់សហគមន៍ ធ្វើឱ្យមានផលជះជាវិជ្ជមានដល់បរិស្ថាន និងសង្គម ដែលជាផ្នែកមួយនៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។ គ្រឹះស្ថាន ខេមា បន្តប្តេជ្ញាចិត្តរួមចំណែកក្នុងកិច្ចការពារសង្គម បរិស្ថាន ការអនុវត្តទៅតាមបទប្បញ្ញត្តិនៃព្រះរាជាណាចក្រកម្ពុជា និងគោលការណ៍ហិរញ្ញវត្ថុប្រកបដោយចីរភាពកម្ពុជា (CSFP) ព្រមទាំងបន្តចាប់ដៃគូជាយុទ្ធសាស្ត្រជាមួយភាគីពាក់ព័ន្ធដើម្បីរក្សាបាននូវអត្ថប្រយោជន៍ជូនអតិថិជន និងសង្គម ដែលជាមូលដ្ឋានគ្រឹះនៃទស្សនវិស័យរបស់គ្រឹះស្ថាន។

នៅឆ្នាំបន្ទាប់ខាងមុខ គ្រឹះស្ថាន ខេមា នៅតែអនុវត្តយុទ្ធសាស្ត្រឌីជីថលជាអាទិភាព។ ដាក់ឱ្យដំណើរការប្រព័ន្ធអនុម័តឥណទាន (LOS) ប្រព័ន្ធគ្រប់គ្រងបណ្តឹងតវ៉ារបស់អតិថិជន (E-complaint) ប្រព័ន្ធគ្រប់គ្រងធនធានមនុស្ស (HR System) កែលម្អ Digital Learning App និងជម្រុញការធ្វើទីផ្សារតាមប្រព័ន្ធឌីជីថល។ គ្រឹះស្ថាន នឹងយកចិត្តទុកដាក់បម្រែបម្រួលជាវិជ្ជមានទៅលើអនុបាតប្រតិបត្តិការ អនុបាតហិរញ្ញវត្ថុ ដែលជាគន្លឹះបង្កើនភាពធន់ ទទួលបានទំនុកចិត្តពីភាគទុនិក និងដៃគូសហការ តាមរយៈកំណើនផលិតភាពការងាររបស់បុគ្គលិក អភិវឌ្ឍ និងកែលម្អផលិតផលសក្តានុពល ពង្រឹងសមត្ថភាពធនធានមនុស្ស គៀរគរប្រភពទុនក្រៅប្រទេស កសាងភាពជាដៃគូជាមួយភាគីពាក់ព័ន្ធ អនុវត្តស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តជាតិនៃកម្ពុជា (CIFRS) និងកិច្ចខិតខំប្រឹងប្រែងអនុវត្តកិច្ចការពារអតិថិជន។

ការកើនឡើងអតិថិជនឥណទានខ្នាតតូចបំផុតគឺជាការពង្រីកវិសាលភាពប្រតិបត្តិការ ជំរុញបរិយាប័ន្នហិរញ្ញវត្ថុនឹងមានផលជះវិជ្ជមានដល់ អនុបាតប្រតិបត្តិការ អនុបាតហិរញ្ញវត្ថុ ដែលជាយុទ្ធសាស្ត្រចំណែកទីផ្សារប្រកបដោយប្រសិទ្ធភាព ហើយគ្រឹះស្ថាន ខេមា អនុវត្តបានល្អកាលពីឆ្នាំកន្លងទៅ និងបន្តអនុវត្តនៅឆ្នាំបន្តបន្ទាប់ទៀត។ គ្រឹះស្ថាននឹងដាក់ឱ្យអនុវត្តផងដែរនូវភាពជាដៃគូជាមួយក្រុមហ៊ុនធានារ៉ាប់រងខ្នាតតូច ដើម្បីផ្តល់សេវាធានារ៉ាប់រងដល់អតិថិជនឥណទានក្រុម និងអតិថិជនឥណទានខ្នាតតូចបំផុត ក្នុងន័យប្រាកដថាពួកគេ និងក្រុមគ្រួសារ អាចគេចផុតពីហានិភ័យដែលកើតឡើងដោយចៃដន្យ។

សមិទ្ធផលបន្តបន្ទាប់ កើតឡើងពីការកំណត់ច្បាស់លាស់នូវចក្ខុវិស័យ បេសកកម្ម តម្លៃស្នូល និងផែនការយុទ្ធ

សាស្ត្ររបស់គ្រឹះស្ថាន និងការខិតខំប្រឹងប្រែងរបស់បុគ្គលិកគ្រប់លំដាប់ថ្នាក់ ប្រកបដោយក្រមសីលធម៌ វិជ្ជាជីវៈ និងភាពស្មោះត្រង់ចំពោះអតិថិជន និងគ្រឹះស្ថាន។

នាងខ្ញុំប្តេជ្ញាដឹកនាំគ្រឹះស្ថាន ខេមា ប្រកបដោយវឌ្ឍនភាព និងនិរន្តរភាព ដើម្បីឈានទៅសម្រេចជោគជ័យតាមគោលដៅដែលបានកំណត់។ ដោយក្តីសង្ឃឹមយ៉ាងមុតមាំថា សមាជិកក្រុមប្រឹក្សាភិបាល បុគ្គលិកគ្រប់លំដាប់ថ្នាក់នឹងចូលរួមយ៉ាងសស្រាក់សស្រាំជាមួយនាងខ្ញុំ ប្រកបដោយឆន្ទៈ និងស្មារតីធ្វើការងារជាក្រុម ក្នុងដំណើរដ៏វែងឆ្ងាយនេះ។ នាងខ្ញុំជឿជាក់ថា ឆ្នាំ២០២៤ គ្រឹះស្ថាននឹងទទួលបានជោគជ័យថែមមួយកម្រិតទៀត។

ជាទីបញ្ចប់ នាងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ជូនចំពោះថ្នាក់គ្រប់គ្រង បុគ្គលិកគ្រប់លំដាប់ថ្នាក់ ចំពោះការលះបង់នូវកម្លាំងកាយចិត្ត រួមចំណែកបំពេញបេសកម្មរបស់គ្រឹះស្ថាន ខេមា ក្នុងការផ្តល់ដំណោះស្រាយហិរញ្ញវត្ថុប្រកបដោយភាពច្នៃប្រឌិតជូនប្រជាជនកម្ពុជា ដោយការយកចិត្តទុកដាក់ និងទំនួលខុសត្រូវខ្ពស់។ នាងខ្ញុំក៏សូមថ្លែងអំណរគុណជូនចំពោះរាជរដ្ឋាភិបាលកម្ពុជា ធនាគារជាតិនៃកម្ពុជា អតិថិជន និងដៃគូទាំងអស់ចំពោះកិច្ចសហការ និងការគាំទ្រ។

ដោយសេចក្តីគោរពដ៏ខ្ពង់ខ្ពស់

**លោកស្រី ឱត និតា**
**ប្រធានក្រុមប្រឹក្សាភិបាល**

# របាយការណ៍របស់ អគ្គនាយកប្រតិបត្តិស្តីទី

**លោក លី ឈាង**



រយៈពេលជាង ១៣ឆ្នាំ គ្រឹះស្ថាន ខេមា មានមោទកភាពក្នុងការចូលរួមចំណែកអភិវឌ្ឍសហគមន៍ តាមរយៈការផ្តល់សេវាហិរញ្ញវត្ថុប្រកបដោយបរិយាប័ន្ន ផលិតផលឥណទានប្រកបដោយភាពច្នៃប្រឌិត និងគំនិតផ្តួចផ្តើមនានាក្នុងន័យជំរុញឱ្យមានការផ្លាស់ប្តូរជាវិជ្ជមានដើម្បីធ្វើដំណើរឆ្ពោះទៅកាន់អនាគតដ៏ល្អប្រសើរសម្រាប់ប្រជាជនកម្ពុជា។

នៅក្នុងឆ្នាំ២០២៣ កំណើនឥណទាននៅប្រទេសកម្ពុជាថយចុះក្នុងកម្រិតទាបបំផុតមិនធ្លាប់មានក្នុងរយៈពេលពីរទសវត្សរ៍ចុងក្រោយ ដោយសារតែការងើបឡើងទន់ខ្សោយនៃវិស័យមួយចំនួន។ ការថយចុះកំណើនឥណទាន និងការកើនឡើងអនុបាតឥណទានមិនដំណើរការ តម្រូវឱ្យគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ បន្តបង្កើនការតាមដាន វាយតម្លៃ និងធ្វើស្ត្រេសតេស្តជាប់ជាប្រចាំលើហានិភ័យ ដែលអាចកើតឡើងជាយថាហេតុ។ បើទោះជាយ៉ាងនេះក្តី គ្រឹះស្ថាន ខេមា រក្សាបាននូវកំណើនផលប័ត្រឥណទានរបស់ខ្លួន និងអភិវឌ្ឍផលិតផលថ្មីដ៏មានសក្តានុពល ព្រមទាំងបើកសាខាថ្មីពីរបន្ថែមទៀត។ ខ្ញុំបាទនឹងលើកយកសមិទ្ធផលសំខាន់ៗ ដែលគ្រឹះស្ថាន ខេមា សម្រេចបានក្នុងឆ្នាំ២០២៣ មកបង្ហាញជូនក្នុងរបាយការណ៍នេះ។

## សមិទ្ធផលសំខាន់ៗក្នុងឆ្នាំ២០២៣

គិតត្រឹមខែធ្នូ ឆ្នាំ២០២៣ ទ្រព្យសកម្មរបស់គ្រឹះស្ថាន ខេមា បានកើនឡើងដល់ ២៧.៦៧៨.៧៧២ដុល្លារ គឺកើនឡើងប្រមាណ ១១,៣៩% ធៀបនឹងឆ្នាំ២០២២។ តាមរយៈការិយាល័យសាខាចំនួន៧ គ្រឹះស្ថាន ខេមា កំពុងធ្វើប្រតិបត្តិការនៅភូមិចំនួន ៨៩១ នៃឃុំ-សង្កាត់ចំនួន ២៨៧ ក្នុងក្រុង- ស្រុក-ខណ្ឌចំនួន ៥៣ នៅ ៥ រាជធានី-ខេត្ត គ្រឹះស្ថានមានបុគ្គលិកសរុប ២០៣នាក់ ផលប័ត្រឥណទាន ២៧.០៣០.៩៧៤ដុល្លារ អតិថិជន ៣.០២៤នាក់ ក្នុងនោះ ៥៩% នៃអតិថិជនសរុបជាស្ត្រី។ គ្រឹះស្ថានសម្រេចបាននូវផលប័ត្រឥណទានជាប្រាក់រៀលចំនួន ១៣,៦៩%។ ដើម្បីពង្រីកវិសាលភាពនៃប្រតិបត្តិការរបស់ខ្លួន នៅត្រីមាសទី២ នៃឆ្នាំ២០២៣ គ្រឹះស្ថានបានបើកដំណើរការសាខាចំនួនពីរគឺ៖ សាខាស្រុកស្អាង ខេត្តកណ្តាល និងសាខាស្រុកកំពង់ត្រាច ខេត្តកំពត ដើម្បីជំរុញការផ្តល់សេវាកម្មឱ្យកាន់តែនៅជិតអតិថិជន។

ទន្ទឹមនឹងការបើកសាខាថ្មី គ្រឹះស្ថាន ខេមា ក៏បានធ្វើវិសោធនកម្មលើផលិតផលឥណទានគ្មានទ្រព្យធានា ដើម្បីអនុញ្ញាតឱ្យម្ចាស់អាជីវកម្មខ្នាតតូចផ្ទាល់ខ្លួននិងអតិថិជនដែលមានប្រភពចំណូលពីប្រាក់ខែនិងមុខរបរអាចស្នើកម្ចីបានដោយគ្មានទ្រព្យធានា។ គ្រឹះស្ថានក៏បានដាក់ឱ្យអនុវត្ត «ស្តង់ដារកិច្ចសន្យាឥណទាន និងខចែងស្តង់ដារកិច្ចសន្យាឥណទាន» ដើម្បីផ្តល់ភាពងាយស្រួលដល់អតិថិជន លើកកម្ពស់ តម្លាភាព និងកិច្ចការពារអតិថិជន។ ក្រៅពីការប្តេជ្ញាចិត្តក្នុងកិច្ចការពារអតិថិជន គ្រឹះស្ថានបានអភិវឌ្ឍ និងដាក់ឱ្យដំណើរការនូវផលិតផលឥណទានបៃតង និងឥណទានទឹកស្អាតនិងអនាម័យ ដើម្បីបង្កើតផលវិជ្ជមានចំពោះបរិស្ថាន និងសុខុមាលភាពសហគមន៍ក្នុងប្រទេសកម្ពុជា។ ផលិតផលទាំងពីរនេះ មានគោលបំណងបង្កើនលទ្ធភាពទទួលបានទឹកស្អាត និងបរិក្ខារអនាម័យប្រើប្រាស់គាំទ្រដល់ការវិនិយោគទៅលើអាជីវកម្មដែលចូលរួមចំណែកកាត់បន្ថយផលប៉ះពាល់អវិជ្ជមាន លើបរិស្ថាន ឬសកម្មភាពដែលបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ សម្តៅលើកកម្ពស់គុណភាព នៃការរស់នៅរបស់អតិថិជន។

ក្នុងឆ្នាំ២០២៣ គ្រឹះស្ថាន ខេមា សម្រេចបាននូវកំណើនប្រាក់ចំណេញ ៨៩% ធៀបនឹងឆ្នាំ២០២២។ ក្នុងនោះ អនុបាតទ្រព្យសកម្មសម្រេចបាន ១,០៣% និងអនុបាតមូលធនសម្រេចបានក្នុងអត្រា ៣,៦២% ប្រចាំឆ្នាំ។ កត្តាទាំងនេះបានធ្វើឱ្យគ្រឹះស្ថាន ខេមា អាចទទួលបានអនុបាតថ្លៃដើមធៀបទៅនឹងចំណូលប្រតិបត្តិការត្រឹម ៩៣,៥៤% ប្រចាំឆ្នាំ និងអត្រាចំណាយប្រតិបត្តិការត្រឹម ៩,២៣% ដែលជាលទ្ធផលល្អជាងឆ្នាំកន្លងទៅ។ បន្ថែមជាងនេះទៅទៀត គ្រឹះស្ថាន ខេមា បានរក្សាអនុបាតសាច់ប្រាក់ងាយស្រួល ១០០% និងអនុបាតសាធនភាព ៣១,០៥% ដែលខ្ពស់ជាងកម្រិតអនុលោមភាពអប្បបរមាដែលតម្រូវដោយ ធនាគារជាតិនៃកម្ពុជា ដែលកំណត់ឱ្យរក្សាមិនឱ្យតិចជាង ១៥%។ លទ្ធផលវិជ្ជមាននេះបង្ហាញពីសុខភាពហិរញ្ញវត្ថុរបស់គ្រឹះស្ថានកាន់តែរឹងមាំមួយកម្រិតទៀតនិងជាថាមពលរុញច្រានគ្រឹះស្ថានឱ្យសម្រេចបានគោលដៅកាន់តែល្អនៅឆ្នាំបន្ទាប់។

## យុទ្ធសាស្ត្រសម្រាប់ឆ្នាំ២០២៤

ផលិតផល«ឥណទានយានយន្ត»នឹងត្រូវធ្វើ វិសោធនកម្ម ដើម្បីផ្តល់ជូនលក្ខខណ្ឌកាន់តែងាយស្រួលដល់អតិថិជនក្នុងការទទួលបានកម្ចី។ គ្រឹះស្ថានក៏គ្រោងនឹងកែលម្អផលិតផលឥណទានរហ័ស ដើម្បីបង្កើនល្បឿនសេវាកម្មឆ្លើយតបនឹងតម្រូវការរបស់អតិថិជន។ ជាមួយគ្នានេះគ្រឹះស្ថាននឹងកែសម្រួលយុទ្ធសាស្ត្រក្នុងការលក់ឥណទានគ្មានទ្រព្យធានា និងឥណទានប្រាក់បៀវត្ស ដើម្បីឱ្យផលិតផលទាំងពីរនេះកាន់តែមានភាពប្រកួតប្រជែងនៅក្នុងទីផ្សារ ។ គ្រឹះស្ថាននឹងពង្រឹងបន្ថែមទៀតទៅលើផលិតផលឥណទានបៃតងជាពិសេសឥណទានទឹកស្អាតនិងអនាម័យតាមរយៈការបង្កើនសកម្មភាពទីផ្សារ និងការផ្តល់ហិរញ្ញប្បទានដល់គ្រឹះស្ថានឥណទានជនបទ។ គ្រឹះស្ថានក៏គ្រោងនឹងដាក់ឱ្យដំណើរការនូវ «បើងការស្នួរេន» ដែលជាសេវាធានារ៉ាប់រងទៅលើឥណទានសម្រាប់ផលិតផលឥណទានក្រុមនិងឥណទានខ្នាតតូចបំផុតដែលមានទំហំកម្ចីក្រោម២០លានរៀលឬសមមូលប្រាក់ដុល្លារ។

គ្រឹះស្ថានក៏នៅតែបន្តការយកចិត្តទុកដាក់ទៅលើការអភិវឌ្ឍចំណេះជំនាញថ្មីៗបន្ថែមទៀតដល់បុគ្គលិកទាំងនៅក្នុងគ្រឹះស្ថាន និងខាងក្រៅគ្រឹះស្ថាន នៅតែជាយន្តការអាទិភាពនៅក្នុងឆ្នាំ ២០២៤។ គ្រឹះស្ថានក៏បានកំពុងធ្វើបច្ចុប្បន្នភាពឱ្យកាន់តែប្រសើរឡើងថែមទៀតនៅលើ Digital Learning App ដើម្បីជាមធ្យោបាយសម្រាប់បុគ្គលិកគ្រប់លំដាប់ថ្នាក់របស់គ្រឹះស្ថានកាន់តែមានភាពងាយស្រួលក្នុងការចូលប្រើប្រាស់ទៅតាមតម្រូវការ គ្រប់ពេលវេលា គ្រប់ទីកន្លែង ។

ឆ្នាំ២០២៤ គ្រឹះស្ថាន ខេមា នៅតែបន្តពង្រីកវិសាលភាព ក្នុងការផ្តល់សេវាហិរញ្ញវត្ថុ តាមរយៈការពង្រីកតំបន់ប្រតិបត្តិការនៅតាមសាខាដែលកំពុងដំណើរការស្រាប់។ សាខានីមួយៗនឹងពង្រីកប្រតិបត្តិការរបស់ខ្លួនទៅតំបន់ថ្មីៗឱ្យកាន់តែធំទូលាយ និងបង្កើនចំណែកទីផ្សារនៅតំបន់ប្រតិបត្តិការបច្ចុប្បន្ន។ គ្រឹះស្ថានក៏ផ្តោតការយកចិត្តទុកដាក់លើការកសាងដៃគូសហការនិងដៃគូយុទ្ធសាស្ត្រដើម្បីសម្រួលដល់អតិថិជនក្នុងការទទួលបានសេវាកម្មនិងបង្កើនប្រសិទ្ធភាពប្រតិបត្តិការរបស់គ្រឹះស្ថាន និងបង្កើនផលិតភាពការងារឱ្យកាន់តែប្រសើរឡើង ។

តាមរយៈបទពិសោធន៍ជាង ១៣ឆ្នាំ គ្រឹះស្ថានបានយល់ច្បាស់នូវភាពខុសប្លែកគ្នារវាងតម្រូវការហិរញ្ញវត្ថុរបស់

សហគមន៍នៅទីជនបទ សហគ្រាសខ្នាតតូចនិងមធ្យម និង បុគ្គលិកក្នុងវិស័យឯកជន និងសាធារណៈ ដែលជាមូលដ្ឋាន គ្រឹះក្នុងការផ្ដល់ដំណោះស្រាយហិរញ្ញវត្ថុសមស្របនឹងតម្រូវ ការរបស់អតិថិជន។ ដោយមានការចូលរួមពីបុគ្គលិក និង គណៈគ្រប់គ្រងគ្រប់លំដាប់ថ្នាក់ គ្រឹះស្ថានបានសម្រេចនូវ សមិទ្ធផល និងភាពរីកចម្រើនលូតលាស់ជាលំដាប់។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមថ្លែងអំណរគុណដល់ រាជរដ្ឋាភិបាលកម្ពុជា ធនាគារជាតិនៃកម្ពុជា ដៃគូពាក់ព័ន្ធ ទាំងអស់ និងអតិថិជន សម្រាប់ការគាំទ្រគ្រឹះស្ថាន ខេមា នា ពេលកន្លងមក។ ទន្ទឹមនឹងនេះ ខ្ញុំសូមសម្ដែងនូវការដឹងគុណ យ៉ាងជ្រាលជ្រៅ ចំពោះបុគ្គលិកដែលបានខិតខំប្រឹងប្រែង យកចិត្តទុកដាក់ប្រកបដោយការប្ដេជ្ញាចិត្តខ្ពស់ក្នុងការបំពេញ ការងារ និងផ្ដល់សេវាដ៏ល្អបំផុតប្រកបដោយសុចរិតភាព តម្លាភាព ភាពច្នៃប្រឌិត និងវិជ្ជាជីវៈ។ ខ្ញុំក៏សូមថ្លែងអំណរគុណ ដល់ភាគទុនិក ប្រធានក្រុមប្រឹក្សាភិបាល និងសមាជិកក្រុម ប្រឹក្សាភិបាលទាំងអស់សម្រាប់ការផ្ដល់អនុសាសន៍ ដំបូន្មាន និងគាំទ្រយ៉ាងពេញទំហឹង ទាំងកម្លាំងកាយ និងកម្លាំងចិត្ត ដើម្បីឱ្យ គ្រឹះស្ថាន ខេមា មីក្រូហិរញ្ញវត្ថុ លីមីតធីត បន្តរក្សាជា ដៃគូហិរញ្ញវត្ថុដ៏ល្អបំផុតរបស់អតិថិជន។

ដោយសេចក្ដីគោរពដ៏ខ្ពង់ខ្ពស់



**លោក លី ឈាង**
**អគ្គនាយកប្រតិបត្តិស្ដីទី**

# ២

# អភិបាលកិច្ច

- រចនាសម្ព័ន្ធគ្រប់គ្រង
- គណៈគ្រប់គ្រង
- ការគ្រប់គ្រងហានិភ័យ និងការត្រួតពិនិត្យផ្ទៃក្នុង

# រចនាសម្ព័ន្ធគ្រប់គ្រង



# គណៈគ្រប់គ្រង





លោក លី ឈាង

អគ្គនាយកប្រតិបត្តិស្ដីទី

លោក **លី ឈាង** បានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ជំនាញគ្រប់គ្រងទូទៅ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ក្នុងឆ្នាំ ២០០៩។ លោកមានបទពិសោធន៍ច្រើនជាង ២០ឆ្នាំ នៅក្នុងវិស័យធនាគារ និងហិរញ្ញវត្ថុ។ លោកធ្លាប់បានកាន់តំណែងជាច្រើននៅធនាគារមានដូចជា៖ ភ្នាក់ងារឥណទានខ្នាតតូចបំផុត ឥណទានខ្នាតតូច ឥណទានខ្នាតមធ្យម ឥណទានគេហដ្ឋាន អនុប្រធានភ្នាក់ងារឥណទាន និងជាប្រធានភ្នាក់ងារឥណទានសាខា។ លោកបានចូលបម្រើការងារជាមួយ គ្រឹះស្ថាន ខេមា មីក្រូហិរញ្ញវត្ថុ លីមីតធីត នៅក្នុងតំណែងជា នាយកការិយាល័យប្រតិបត្តិការ នៅឆ្នាំ២០១៥។ លោកត្រូវបានដំឡើងតំណែងទៅជា នាយក នាយកដ្ឋានឥណទាន នៅថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៦ និងបន្ទាប់មកលោកត្រូវបាន គ្រឹះស្ថាន ខេមា មីក្រូហិរញ្ញវត្ថុ លីមីតធីត ដំឡើងតំណែងមួយកម្រិតទៀតទៅជា អគ្គនាយករងប្រតិបត្តិ នៅខែធ្នូ ឆ្នាំ២០២០។ លោកត្រូវបានតែងតាំងជា អគ្គនាយកប្រតិបត្តិស្ដីទី នៅខែកុម្ភៈ ឆ្នាំ២០២៣។

លោក សែន កំសាន្ត

នាយក នាយកដ្ឋានឥណទាន

លោក **សែន កំសាន្ត** បានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ លើមុខជំនាញហិរញ្ញវត្ថុ និងធនាគារ ក្នុងឆ្នាំ២០១០ នៅសាកលវិទ្យាល័យបៀលប្រាយ។ លោកបានចូលរួមវគ្គបណ្ដុះបណ្ដាលជាច្រើនដូចជា៖ ជំនាញផ្នែកលក់ និងទីផ្សារ ការអភិវឌ្ឍផលិតផល ការគ្រប់គ្រងសេវាកម្មអតិថិជន ការគ្រប់គ្រងសាខា ការគ្រប់គ្រងហានិភ័យឥណទាន ការត្រួតពិនិត្យផ្ទៃក្នុង និងការគ្រប់គ្រងគម្រោង។ល។ ក្នុងរយៈពេលជាង ១៩ ឆ្នាំកន្លងមក លោកធ្លាប់បានបម្រើការងារនៅ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងគ្រឹះស្ថានទូទាត់ (PSI) ជាច្រើនដូចជា៖ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អិលអូអិលស៊ី ធនាគារ អេសប៊ីអាយលីហ្សួរ ក្រុមហ៊ុន លីហ្សួរ ផេប្រ៊ូភីអិលស៊ី ក្រុមហ៊ុន អាស៊ាយែសអ៊ិចប្រេស គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជោគជ័យ ហ្វាយនែន ក្នុងតួនាទីចាប់ពី មន្ត្រីឥណទាន នាយកសាខា ប្រធានផ្នែក និងនាយកនាយកដ្ឋាន។ លោកបានចូលបម្រើការងារនៅ គ្រឹះស្ថាន ខេមា មីក្រូហិរញ្ញវត្ថុ លីមីតធីត ក្នុងតំណែងជា នាយក នាយកដ្ឋានឥណទាន នៅក្នុងខែធ្នូ ឆ្នាំ២០២០។



លោកស្រី វ៉ាត់ សុវណ្ណា

នាយិកា នាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ

លោកស្រី **វ៉ាត់ សុវណ្ណា** បានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងធុរកិច្ចក្នុងឆ្នាំ២០១៥ ពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច និងបានបញ្ចប់ថ្នាក់បរិញ្ញាបត្រ ផ្នែកគណនេយ្យ នៅវិទ្យាស្ថានវ៉ាន់ដាគណនេយ្យ ក្នុងឆ្នាំ២០០៨។ លោកស្រី ក៏បានបញ្ចប់ថ្នាក់ Diploma " ផ្នែកពន្ធ " ពីវិទ្យាស្ថាន ខេមអេដ នៅឆ្នាំ២០១១ និងពីសាលាជាតិពន្ធដារ និងត្រូវបានទទួលស្គាល់ពីអគ្គនាយកដ្ឋានពន្ធដារផងដែរនៅឆ្នាំ២០១៤។ នៅចុងឆ្នាំ២០២១ លោកស្រីបានបញ្ចប់ថ្នាក់ Diploma មុខវិជ្ជាស្តង់ដារគណនេយ្យថ្មី "CIFRS for SMEs" ពីវិទ្យាស្ថាន ខេមអេដ នឹងកំពុងបន្តសិក្សាកម្មវិធី ACCA បន្ថែមទៀតក្នុងការអភិវឌ្ឍជាបន្តក្នុងអាជីពការងាររបស់គាត់។ លោកស្រីមានបទពិសោធន៍វិជ្ជាជីវៈផ្នែកគណនេយ្យ ហិរញ្ញវត្ថុ និងផ្នែកពន្ធដារ ជាង១៥ឆ្នាំ ក្នុងវិស័យហិរញ្ញវត្ថុចាប់តាំងពីខែធ្នូ ឆ្នាំ ២០០៧ មកម្ល៉េះ ដោយអាជីពការងារជាដំបូងក្នុងតួនាទីជា គណនេយ្យករ នៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមួយ។ បន្ទាប់មក ក្នុងឆ្នាំ២០១០ លោកស្រីត្រូវបានតែងតាំងជាមន្ត្រីទទួលបន្ទុកផ្នែកពន្ធដារក្នុងគ្រឹះស្ថានផ្ទាល់ និងត្រូវបានដំឡើងជាមន្ត្រីជាន់ខ្ពស់ផ្នែកពន្ធដារ ក្នុងឆ្នាំ២០១៣។ មុនចូលរួមជាមួយ គ្រឹះស្ថាន ខេមា លោកស្រីគឺជា នាយិកាហិរញ្ញវត្ថុ នៅក្នុងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ វិថី។ បន្ទាប់មក នៅក្នុងខែកក្កដា ឆ្នាំ២០២០ លោកស្រី បានចាប់ផ្តើមចូលបម្រើការងារជាមួយ គ្រឹះស្ថាន ខេមា មីក្រូហិរញ្ញវត្ថុ លីមីតធីត ក្នុងតួនាទីជា នាយិកា នាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ រហូតមកដល់បច្ចុប្បន្ន។



លោក យ៉ាំង ហៃ

នាយក នាយកដ្ឋានសវនកម្មផ្ទៃក្នុង

លោក **យ៉ាំង ហៃ** បានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកហិរញ្ញវត្ថុ និងធនាគារ នៅសាកលវិទ្យាល័យ បៀលប្រាយ ក្នុងឆ្នាំ២០១០ និងបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ ផ្នែកគណនេយ្យ និងហិរញ្ញវត្ថុ នៅវិទ្យាស្ថានជាតិគ្រប់គ្រង ក្នុងឆ្នាំ២០០៣។ លោកបានចូលរួម វគ្គបណ្តុះបណ្តាលជាច្រើន ដូចជា ប្រសិទ្ធភាពនៃការត្រួតពិនិត្យផ្ទៃក្នុង សវនករផ្ទៃក្នុង ការគ្រប់គ្រងហានិភ័យឥណទានកម្រិតខ្ពស់ ជំនាញសវនកម្មព័ត៌មានវិទ្យា ជំនាញភាពជាអ្នកដឹកនាំ ជំនាញបង្វឹក ការសរសេររបាយការណ៍ ច្បាប់ពន្ធដារ ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុ និងការក្លែងបន្លំ។ លោកមានបទពិសោធន៍បម្រើការងារក្នុងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុច្រើនជាង ១៥ឆ្នាំ រួមមានការបម្រើការងារនៅ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ក្នុងមុខតំណែងជា មន្ត្រីឥណទាន។ លោកបានបម្រើការងារនៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អិលអូអិលស៊ី (២០០៥ ដល់ ២០១៥) ក្នុងតំណែងជា សវនករផ្ទៃក្នុង សវនករផ្ទៃក្នុងជាន់ខ្ពស់ និងជាប្រធានផ្នែកសវនករប្រតិបត្តិការ។ លោកចូលបម្រើការងារនៅគ្រឹះស្ថាន ខេមា មីក្រូហិរញ្ញវត្ថុ លីមីតធីត ក្នុងតំណែងជា នាយក នាយកដ្ឋានសវកម្មផ្ទៃក្នុង នៅខែវិច្ឆិកា ឆ្នាំ២០១៥។



### លោក ផេង ពុធមេត្រី
### នាយក នាយកដ្ឋានធនធានមនុស្ស និងរដ្ឋបាល

លោក **ផេង ពុធមេត្រី** បានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងរដ្ឋបាលអាជីវកម្ម បរិញ្ញាបត្រអក្សរសាស្ត្រអង់គ្លេស និងសញ្ញាបត្រជាន់ខ្ពស់ ផ្នែកភាសាអង់គ្លេសទូទៅ នៅសាកលវិទ្យាល័យ បញ្ញាសាស្ត្រកម្ពុជា។ លោកក៏មានបទពិសោធន៍ជាង ១៤ឆ្នាំ នៅលើជំនាញគ្រប់គ្រងធនធានមនុស្ស និងរដ្ឋបាល ផ្នែកបម្រើអតិថិជន និងទីផ្សារ ជាមួយក្រុមហ៊ុនជាតិ និងអន្តរជាតិ ព្រមទាំងគ្រឹះស្ថានហិរញ្ញវត្ថុជាច្រើនផងដែរ។ ក្រៅពីនេះ លោកក៏ធ្លាប់បានចូលរួមក្នុងសិក្ខាសាលា និងវគ្គសិក្សាជំនាញមួយចំនួនដូចជា ការគ្រប់គ្រងធនធានមនុស្ស ការគ្រប់គ្រងរដ្ឋបាលទូទៅ ការគ្រប់គ្រង និងភាពជាអ្នកដឹកនាំការកសាងក្រុមនិងវគ្គជាច្រើនទៀត។ លោកបានចូលបម្រើការងារនៅ គ្រឹះស្ថាន ខេមា មីក្រូហិរញ្ញវត្ថុ លីមីតធីត ក្នុងតំណែងជា នាយក នាយកដ្ឋានធនធានមនុស្ស និងរដ្ឋបាល នៅក្នុងឆ្នាំ២០១៩។



### លោក ទិត វណ្ណារិទ្ធ
### នាយក នាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន

លោក **ទិត វណ្ណារិទ្ធ** បានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកហិរញ្ញវត្ថុ នៅសាកលវិទ្យាល័យជាតិគ្រប់គ្រង ក្នុងឆ្នាំ២០០៨។ លោកក៏បានបញ្ចប់វគ្គសិក្សាផ្នែកអភិវឌ្ឍកម្មវិធីកុំព្យូទ័រ និងប្រព័ន្ធគ្រប់គ្រងមូលដ្ឋានទិន្នន័យ (Database) ។ លោកមានបទពិសោធន៍ ២៣ឆ្នាំ ក្នុងវិស័យធនាគារ ក្នុងផ្នែក៖ គណនេយ្យហិរញ្ញវត្ថុ រតនាគារ និងព័ត៌មានវិទ្យា។ លោកបានចូលបម្រើការងារនៅគ្រឹះស្ថាន ខេមា មីក្រូហិរញ្ញវត្ថុ លីមីតធីត ក្នុងឆ្នាំ២០១៣។ បច្ចុប្បន្នលោកមានតួនាទីជា នាយក នាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន។





## លោក ឈួន សុខចិត្ត

**នាយក នាយកដ្ឋានទីផ្សារ និងអភិវឌ្ឍន៍ផលិតផល**

លោក **ឈួន សុខចិត្ត** បានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងពាណិជ្ជកម្ម ពីសាកលវិទ្យាល័យ ន័រតុន ក្នុងឆ្នាំ២០១២ និងបរិញ្ញាបត្រផ្នែក គ្រប់គ្រងសហគ្រាស ពីសាកលវិទ្យាល័យ ភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច ក្នុងឆ្នាំ២០០៣។ លោកក៏ទទួលបានសញ្ញាបត្រមធ្យមឯកទេស ផ្នែកផែនការសេដ្ឋកិច្ច នៅមជ្ឈមណ្ឌលបណ្តុះបណ្តាលផែនការ និងស្ថិតិ ក្នុងឆ្នាំ២០០១។ លើសពីនេះ លោកក៏បានចូលរួមវគ្គបណ្តុះបណ្តាលជំនាញសំខាន់ៗជាច្រើននៅក្នុងប្រទេសកម្ពុជា ហ្វីលីពីន ជប៉ុន ថៃ និងម៉ាឡេស៊ី។ ជាមួយបទពិសោធន៍រយៈពេល១៨ឆ្នាំលោកក៏ធ្លាប់បម្រើការនៅក្នុងស្ថាប័នជាច្រើន ដូចជា ធនាគារ អេស៊ីលីដា ភីអិលស៊ី គ្រឹះស្ថាន មីក្រូហិរញ្ញវត្ថុ សីលានិធិ ក្រុមហ៊ុនតូយ៉ូតា (ខេមបូឌា) និងគ្រឹះស្ថាន មីក្រូហិរញ្ញវត្ថុ អិលអូអិលស៊ី ក្នុងតួនាទីជា មន្ត្រីឥណទាន ប្រធានមន្ត្រីឥណទាន នាយកទីផ្សារ ប្រធានផ្នែកលក់គ្រឿងបន្លាស់និងនាយកនាយកដ្ឋានទីផ្សារ។លោកបានចូលបម្រើការងារនៅគ្រឹះស្ថាន ខេមា មីក្រូហិរញ្ញវត្ថុ លីមីតធីត ក្នុងតំណែងជា នាយក នាយកដ្ឋានទីផ្សារ និងអភិវឌ្ឍន៍ផលិតផល នៅខែវិច្ឆិកា ឆ្នាំ២០២២។

## លោក វង ចាន់សុមាន

**ប្រធានមុខងារប្រតិបត្តិតាម**

លោក **វង ចាន់សុមាន** បានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ជំនាញគ្រប់គ្រងពាណិជ្ជកម្មក្នុងឆ្នាំ២០២២និងបានបញ្ចប់ការសិក្សាបរិញ្ញាបត្រ ជំនាញហិរញ្ញវត្ថុនិងធនាគារ ក្នុងឆ្នាំ២០១៦។ លោកក៏បានទទួលសញ្ញាបត្រនីតិពាណិជ្ជកម្មកម្ពុជា ក្នុងឆ្នាំ២០១៩ និងលោកបានបញ្ចប់ការសិក្សាវិញ្ញាបនបត្រ Regulatory Compliance Certification លើកទី២ ក្នុងឆ្នាំ២០២៣។ លើសពីនេះទៅទៀត លោកក៏បានចូលរួមវគ្គបណ្តុះបណ្តាលជាច្រើនដូចជា៖ ការគ្រប់គ្រងហានិភ័យឥណទាន ការគ្រប់គ្រងហានិភ័យប្រតិបត្តិការ ការគ្រប់គ្រងហានិភ័យសន្ទនីយភាព និងការវិភាគសេដ្ឋកិច្ច។ ជាមួយបទពិសោធន៍រយៈពេល១០ឆ្នាំ លោកក៏ធ្លាប់បានបម្រើការនៅក្នុងស្ថាប័នជាច្រើនដូចជា៖ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមហានគរ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប្រាសាក់ ក្នុងតួនាទីជាមន្ត្រីឥណទាន ប្រធានមន្ត្រីឥណទាន មន្ត្រីគ្រប់គ្រងហានិភ័យ និងមន្ត្រីប្រតិបត្តិ។ លោកត្រូវបានទទួលស្គាល់ជាប្រធានមុខងារប្រតិបត្តិតាម ពីធនាគារជាតិនៃកម្ពុជា និងអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ក្នុងឆ្នាំ២០២០ ដើម្បីទទួលបន្ទុកក្នុងការគ្រប់គ្រង ផ្នែកអនុលោមភាពរបស់គ្រឹះស្ថាន ក្រោយពីបានចូលបម្រើការងារនៅ គ្រឹះស្ថាន ខេមា មីក្រូហិរញ្ញវត្ថុ លីមីតធីត ក្នុងតំណែងជា ប្រធានមុខងារប្រតិបត្តិតាម ក្នុងឆ្នាំ២០១៩។

# ការគ្រប់គ្រងហានិភ័យ និងការត្រួតពិនិត្យផ្ទៃក្នុង

ការគ្រប់គ្រងហានិភ័យដើរតួនាទីយ៉ាងសំខាន់ ក្នុងការធ្វើឱ្យប្រសើរឡើងនូវគុណភាព នៃការគ្រប់គ្រងរបស់គ្រឹះស្ថាន ខេមា និងគាំទ្រដល់ដំណើរអាជីវកម្មឱ្យសម្រេចបាននូវគោលបំណងដែលបានកំណត់ដោយផ្តោតលើទិដ្ឋភាពចំនួនពីរគឺ៖ ការការពារភាគទុននិក និងការបង្កើនប្រសិទ្ធភាពនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង។

ដើម្បីធានាថាការពង្រីកប្រតិបត្តិការ និងសកម្មភាពអាជីវកម្មនៅក្នុងការវិវឌ្ឍប្រកបដោយចីរភាព និងបរិយាកាសប្រកួតប្រជែងខ្ពស់ ហើយនៅតែស្ថិតក្នុងកម្រិតហានិភ័យដែលទទួលយក និងអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិជាធរមានទាំងខាងផ្ទៃក្នុង និងខាងក្រៅ គ្រឹះស្ថាន ខេមា បានអនុវត្តប្រព័ន្ធគ្រប់គ្រងហានិភ័យរួមបញ្ចូលគ្នានៅទូទាំងគ្រឹះស្ថានទាំងមូល។ ប្រព័ន្ធគ្រប់គ្រងហានិភ័យមានភាពទូលំទូលាយសម្រាប់គ្រឹះស្ថាន (ក្របខ័ណ្ឌគ្រប់គ្រងហានិភ័យ)។

ការគ្រប់គ្រងហានិភ័យនៅក្នុងគ្រឹះស្ថាន ខេមា គឺដាច់ដោយឡែក និងឯករាជ្យពីមុខងារអាជីវកម្ម និងសវនកម្ម។ មុខងារទាំងនេះមានសកម្មភាពក្នុងការគ្រប់គ្រងហានិភ័យនៅកម្រិតផ្សេងៗនៃគ្រឹះស្ថាន។

ការគ្រប់គ្រងហានិភ័យរបស់គ្រឹះស្ថាន ខេមា ដំណើរការក្រោមគំនូសបន្ទាត់ ៣ជួរនៃការការពារ នៃគណនេយ្យភាពដែលជួយឱ្យមានការកាត់បន្ថយកម្រិតហានិភ័យដ៏រឹងមាំដែលបង្កើតការគ្រប់គ្រង៣កម្រិត។ រចនាសម្ព័ន្ធនៃកម្រិតនីមួយៗមានការកំណត់តួនាទី និងការទទួលខុសត្រូវបានច្បាស់លាស់នៅទូទាំងគ្រឹះស្ថាន ខេមា។ វាកំណត់នូវតម្រូវការរបស់ គ្រឹះស្ថាន ខេមា សម្រាប់ការបែងចែកភារកិច្ច ដើម្បីធានានូវឯករាជ្យភាពគ្រប់គ្រាន់នៃបុគ្គលិកគ្រប់គ្រងហានិភ័យ។

| ជួរទី ១ | ជួរទី ២ | ជួរទី ៣ |
|---|---|---|
| មុខងារគ្រប់គ្រង និងគ្រប់គ្រងហានិភ័យផ្ទាល់ (ឧទាហរណ៍ អ្នកគ្រប់គ្រងទូទៅ) | មុខងារត្រួតពិនិត្យហានិភ័យ និងអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិ (ឧទាហរណ៍ ប្រតិបត្តិតាម ) | មុខងារដែលផ្តល់ការធានាឯករាជ្យ (ឧទាហរណ៍ សវនកម្មផ្ទៃក្នុង) |

ការគ្រប់គ្រងហានិភ័យស្ថិតនៅក្រោមគ្រប់គ្រង និងដឹកនាំដោយក្រុមប្រឹក្សាភិបាល ក្នុងការកំណត់ និងត្រួតពិនិត្យពីប្រសិទ្ធភាពនៃការគ្រប់គ្រងហានិភ័យជាប្រចាំ។

នាយកដ្ឋានសវនកម្មផ្ទៃក្នុង មានភារៈកិច្ច និងទំនួលខុសត្រូវក្នុងការវាយតម្លៃលើភាពគ្រប់គ្រាន់ និងត្រឹមត្រូវនៃគ្រប់គ្រងហានិភ័យ និងរាយការណ៍ដោយឯករាជ្យទៅគណៈកម្មការសវនកម្ម នៃក្រុមប្រឹក្សាភិបាល។ នាយកដ្ឋានសវនកម្មផ្ទៃក្នុង អនុវត្តតាមប្រកាសរបស់ធនាគារជាតិនៃកម្ពុជា ស្តីពី ការត្រួតពិនិត្យផ្ទៃក្នុងរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ចំពោះការរៀបចំរចនាសម្ព័ន្ធ មុខងារ ធនធាន យុទ្ធសាស្ត្រ និងនីតិវិធីនៃសវកម្ម។ បន្ថែមលើសពីនេះទៀត នាយកដ្ឋានអនុវត្តការងារត្រួតពិនិត្យដោយផ្អែកលើបទដ្ឋានមួយច្បាស់លាស់ក្នុងការអនុវត្តវិជ្ជាជីវៈសវនកម្មផ្ទៃក្នុង។

សកម្មភាពសវនករផ្ទៃក្នុងនឹងមិនត្រូវបានរារាំងពីផ្នែកណាមួយនៅក្នុងគ្រឹះស្ថានរួមមានការជ្រើសរើសក្នុងការចុះធ្វើសវនកម្ម វិសាលភាព នីតិវិធី ភាពញឹកញាប់ ពេលវេលា ឬមាតិកានៃរបាយការណ៍ ដើម្បីរក្សាឯករាជ្យភាព និងសុក្រឹតភាពតាមការចាំបាច់។ សវនករផ្ទៃក្នុងមិនត្រូវត្រួតពិនិត្យលើផ្នែកឬនាយកដ្ឋានដែលជាកន្លែងមានសាច់ញាតិរបស់ពួកគាត់កំពុងបម្រើការងារ ឬជាកន្លែងដែលសវនករផ្ទៃក្នុងធ្លាប់ធ្វើការងារយ៉ាងហោចណាស់រយៈពេល៦ខែ។ សវនករផ្ទៃក្នុងត្រូវមានឯករាជ្យភាពពីប្រតិបត្តិការប្រចាំថ្ងៃនិងត្រូវជៀសវាងការចូលរួមសកម្មភាពដែលអាចត្រូវបានគេឃើញថាប៉ះពាល់លទ្ធភាពរបស់ពួកគាត់ក្នុងការផ្តល់សេវាកម្មដោយឯករាជ្យ និងសុក្រឹតភាព។ ក្នុងការធ្វើសវនកម្ម សវនករផ្ទៃក្នុងមិនមានតួនាទីឬសិទ្ធលើសពីសកម្មភាពណាមួយដែលត្រូវត្រួតពិនិត្យនោះទេ។




គ្រឹះស្ថាន ខេមា ទទួលបាន វិញ្ញាបនបត្រ អនុលោមភាពសារពើពន្ធ ប្រភេទមាស មានសុពលភាពពីរឆ្នាំជាប់គ្នា គឺឆ្នាំ២០២៥ និងឆ្នាំ២០២៦ ពី អគ្គនាយកដ្ឋានពន្ធដារ។

# ៣

# ទិដ្ឋភាពទូទៅ នៃអាជីវកម្ម

- ផលិតផល និងសេវាកម្ម
- សមិទ្ធផលអាជីវកម្ម
- សេចក្តីសង្ខេបអំពីសមិទ្ធផលហិរញ្ញវត្ថុ
- បណ្តុះបណ្តាល និងអភិវឌ្ឍន៍សមត្ថភាពបុគ្គលិក
- អំពីអតិថិជន

# ផលិតផល និងសេវាកម្ម

បន្ទាប់ពីទទួលបានអាជ្ញាបណ្ណផ្លូវការពី ធនាគារជាតិនៃកម្ពុជា ជាងមួយទសវត្សរ៍មកនេះ គ្រឹះស្ថាន ខេមា បានពង្រឹង និងអភិវឌ្ឍផលិតផលថ្មីៗជាច្រើន ផ្តល់ដំណោះស្រាយហិរញ្ញវត្ថុស្របនឹងតម្រូវការរបស់អតិថិជន ជំរុញបរិយាប័ន្នហិរញ្ញវត្ថុប្រកបដោយភាពច្នៃប្រឌិត និងគុណតម្លៃសម្រាប់សង្គម ដើម្បីរក្សាបាននូវសមត្ថភាពប្រកួតប្រជែង និងស្របតាមនិន្នាការឌីជីថល។

ផលិតផលឥណទានក្រុមធានា បាននិងកំពុងបន្តផ្តល់ឱកាសដល់អតិថិជនដែលមានកម្រិតជីវភាពទាបចងក្រុងជាក្រុមមានសមាជិកពី ២-៥នាក់ ទទួលបានសេវាប្រាក់កម្ចីពីគ្រឹះស្ថាន ខេមា។ ឆ្លើយតបនឹងតម្រូវការ និងអត្រាកំណើនសេដ្ឋកិច្ចវិជ្ជមាន គ្រឹះស្ថាន ខេមា បានធ្វើវិសោធនកម្មដំឡើងទំហំប្រាក់កម្ចីអតិបរមារបស់ឥណទានក្រុមធានា ទៅ ១.៥០០ ដុល្លារ ក្នុងសមាជិកម្នាក់នៅក្នុងឆ្នាំ២០២៣ ហើយជាលទ្ធផលអត្រាកំណើនអតិថិជនប្រាក់កម្ចីក្រុមធានា បានកើនឡើង ៩២% និងអត្រាកំណើនផលប័ត្រឥណទាន ៨៦%ដោយក្នុងនោះ មានអតិថិជន ៣៧៩នាក់ ស្មើនឹង ១២,៥៣% នៃចំនួនអតិថិជនសរុប និងផលប័ត្រឥណទានចំនួន ២៣៨.៧២២ ដុល្លារ ស្មើនឹង ០,៨៨% នៃផលប័ត្រឥណទានសរុប។

ផលិតផលឥណទានឯកត្តជនគឺជាផលិតផលឥណទានសំខាន់មួយទៀតរបស់គ្រឹះស្ថាន ខេមា ដែលត្រូវបានបង្កើតឡើង ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់អតិថិជនដែលមានកម្រិតជីវភាពមធ្យមអាចយកទៅប្រើប្រាស់ក្នុងការប្រកបរបរអាជីវកម្ម ឬបំពេញតម្រូវការផ្ទាល់ខ្លួន និងគ្រួសារ។ បច្ចុប្បន្នឥណទានឯកត្តជន មានអតិថិជនចំនួន ១.៩០១នាក់ ស្មើនឹង ៦២,៨៦% នៃចំនួនអតិថិជនសរុប និងមានផលប័ត្រឥណទានចំនួន ២២.៩៤៤.៧៤៦ដុល្លារ ស្មើនឹង ៨៤,៨៨% នៃផលប័ត្រឥណទានសរុប។ ផលិតផលឥណទានឯកត្តជនត្រូវបានបែងចែកទៅតាមទំហំឥណទានដូចជាៈឥណទានខ្នាតតូចបំផុត ឥណទានខ្នាតតូច និងឥណទានខ្នាតមធ្យម ដោយមានទំហំកម្ចីអតិបរមាហូតដល់ ៣០០.០០០ដុល្លារ។

ដើម្បីពង្រឹងភាពធន់ បង្កើនចំនួនអតិថិជន និងពង្រីកវិសាលភាពប្រតិបត្តិការឱ្យកាន់តែទូលំទូលាយប្រកបដោយបរិយាប័ន្នហិរញ្ញវត្ថុ គ្រឹះស្ថាន ខេមា បានកែលម្អផលិតផលឥណទានខ្នាតតូចបំផុតដោយផ្តល់ជូនលក្ខខណ្ឌកាន់តែល្អជាងមុន និងរយៈពេលកាន់តែវែងជាងមុន។ ជាលទ្ធផល ចំនួនអតិថិជនឥណទានខ្នាតតូចបំផុតកើនដល់៥១៤នាក់ស្មើនឹង ១៧% នៃចំនួនអតិថិជនសរុប និងមានផលប័ត្រឥណទាន ១.៣២៨.៨២៤ដុល្លារ ស្មើនឹង ៤,៩២% នៃផលប័ត្រឥណទានសរុប។

ផលិតផលឥណទានកសិកម្ម មានលក្ខខណ្ឌបង់សងត្រឡប់បត់បែនស្របទៅតាមប្រាក់ចំណូលរដូវកាលរបស់អតិថិជន និងផ្តល់លទ្ធភាពឱ្យអតិថិជនដែលប្រកបមុខរបរពាក់ព័ន្ធនឹងវិស័យកសិកម្ម ទិញវត្ថុធាតុដើម ឬគ្រឿងចក្រកសិកម្ម ជាមួយនឹងទំហំឥណទានអតិបរមាហូតដល់ ៥០.០០០ដុល្លារ។ ចំនួនអតិថិជនឥណទានកសិកម្មបានកើនឡើងដល់១២០នាក់ស្មើនឹង៣,៩៧%នៃចំនួនអតិថិជនសរុប និងមានផលប័ត្រឥណទាន ១.៥០៣.៦៨៤ដុល្លារ ស្មើនឹង ៥,៥៦% នៃផលប័ត្រឥណទានសរុប។

ឥណទានអាជីវកម្មខ្នាតតូចនិងមធ្យម (SME) របស់គ្រឹះស្ថាន ខេមា អតិថិជនអាចទទួលបានកម្ចីជាទុនបង្វិល និងទុនវិនិយោគដែលមានទំហំអតិបរមាហូតដល់ ៥០០.០០០ ដុល្លារ។ ក្រោមកិច្ចសហប្រតិបត្តិការជាមួយសាជីវកម្មធានាឥណទានកម្ពុជា (CGCC) នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គ្រឹះស្ថាន ខេមា បានដាក់ឱ្យដំណើរការគម្រោងឥណទានស្តារអាជីវកម្មដែលផ្តល់លទ្ធភាពដល់សហគ្រាសឬក្រុមហ៊ុនពិសេសសហគ្រិនស្ត្រីដែលមានសក្តានុពលនិងមានលទ្ធភាពសងគ្រប់គ្រាន់ ប៉ុន្តែទ្រព្យធានាមិនគ្រប់គ្រាន់ អាចទទួលបានឥណទានពីគ្រឹះស្ថានយកទៅប្រើប្រាស់ក្នុងការពង្រឹងនិងពង្រីកប្រតិបត្តិការអាជីវកម្មរបស់ខ្លួន។ ឥណទានអាជីវកម្មខ្នាតតូចនិងមធ្យម (SME) មានអតិថិជនសរុបចំនួន ១៨នាក់ និងមានផលប័ត្រឥណទានចំនួន ២.៥៣០.០៣០ដុល្លារ ហើយឥណទានស្តារអាជីវកម្ម ក្រោមកិច្ចសហប្រតិបត្តិការជាមួយ សាជីវកម្មធានាឥណទានកម្ពុជា (CGCC) មានអតិថិជនចំនួន ៣នាក់ដែលមានផលប័ត្រឥណទានចំនួន ១១៨.៤២៤ដុល្លារ។

ផលិតផលឥណទានរហ័ស ផ្តល់ជូនអតិថិជនដែលត្រូវការសាច់ប្រាក់ប្រើប្រាស់បន្ទាន់ ដោយគ្រាន់តែមានបណ្ណសម្គាល់យានយន្តដាក់ជាទ្រព្យធានា អតិថិជនអាចទទួលបានប្រាក់កម្ចីទំហំអតិបរមារហូតដល់ ៣.០០០ដុល្លារ។ ចំនួនអតិថិជនឥណទានរហ័សបានកើនឡើងដល់ ៣១០នាក់ ស្មើនឹង ១០,២៥% នៃចំនួនអតិថិជនសរុប និងមានផលប័ត្រឥណទានសរុបចំនួន ៣៤០.៧១៨ដុល្លារ ស្មើនឹង ១,២៦% នៃផលប័ត្រឥណទានសរុប។

ឥណទានគ្មានទ្រព្យធានា គឺជាប្រភេទផលិតផលឥណទានឌីជីថល ផ្តល់ភាពងាយស្រួលដល់អតិថិជនអាចដាក់ស្នើកម្ចីតាមអនឡាញ ហើយការសិក្សាប្រាក់កម្ចីតាមអនឡាញ ដោយអតិថិជនតម្រូវឱ្យអញ្ជើញមកការិយាល័យតែម្តងប៉ុណ្ណោះ គឺនៅពេលបើកប្រាក់។ ឥណទានគ្មានទ្រព្យធានា មានទំហំកម្ចីរហូតដល់ ៥.០០០ដុល្លារ ដែលអតិថិជនអាចយកទៅប្រើប្រាស់បំពេញតម្រូវការផ្ទាល់ខ្លួន ឬប្រកបអាជីវកម្មខ្នាតតូច។ ឥណទានគ្មានទ្រព្យធានា មានចំនួនអតិថិជន ២០០នាក់ ស្មើនឹង ៦,៦១% នៃចំនួនអតិថិជនសរុប និងមានផលប័ត្រឥណទាន ៤២២.៩៤៣ដុល្លារ ស្មើនឹង ១,៥៦% នៃផលប័ត្រឥណទានសរុប។

ក្រៅពីផលិតផលឥណទានស្នូលរបស់ខ្លួនខាងលើ គ្រឹះស្ថាន ខេមា ក៏មានផ្តល់ជូនផលិតផលឥណទានជាច្រើនទៀត ពិសេសអតិថិជនដែលមានតម្រូវការទិញសម្ភារប្រើប្រាស់ផ្ទាល់ខ្លួនដូចជារថយន្ត ម៉ូតូ ម៉ូតូកង់បី ឬមានបំណង ទិញដីផ្ទះ ឬសាងសង់សំណង់ផ្សេងៗជាដើម។ គ្រឹះស្ថាន ខេមា ក៏មានផលិតផលឥណទានប្រាក់បៀវត្ស ផ្តល់ជូនបុគ្គលិក ដែលបម្រើការនៅក្រុមហ៊ុនឯកជន/ឬស្ថាប័នសាធារណៈជាមួយលក្ខខណ្ឌឥណទានងាយស្រួល លឿនរហ័ស និងមានទំហំកម្ចីរហូតដល់ ១.០០០ដុល្លារ។

នៅក្នុងឆ្នាំ២០២៣ គ្រឹះស្ថានបានដាក់ឱ្យដំណើរការផលិតផលឥណទានបៃតង និងឥណទានទឹកស្អាតនិងអនាម័យដើម្បីជំរុញបរិយាប័ន្នហិរញ្ញវត្ថុដោយការបង្កើតផលវិជ្ជមានចំពោះសុខុមាលភាពសហគមន៍ជនបទនៅកម្ពុជា។ នៅឆ្នាំបន្ទាប់ ខេមា គ្រោងកែលម្អនិងជំរុញផលិតផលឥណទានរហ័ស ដើម្បីបង្កើនល្បឿនសេវាកម្ម និងផ្តល់ភាពងាយស្រួលដល់អតិថិជន និងបន្តអភិវឌ្ឍផលិតផលសក្តានុពលថ្មីបន្ថែមទៀត ដើម្បីឆ្លើយតបនឹងតម្រូវការទីផ្សារ និងគាំទ្រដល់ការអនុវត្តផែនការអាជីវកម្មរបស់គ្រឹះស្ថាន។

# សមិទ្ធផលអាជីវកម្ម

## សមិទ្ធផលឥណទានតាមវិស័យ

### ចំនួនអតិថិជន

| ល.រ. | វិស័យ | ២០២១ | ២០២២ | ២០២៣ | ប្រែប្រួល |
|---|---|---|---|---|---|
| ១ | ក្រុមគ្រួសារ | ៤៩៤ | ៥៣៨ | ៨៥៨ | ៥៩% |
| ២ | ពាណិជ្ជកម្ម | ១១៦ | ២០៩ | ៣៣០ | ៥៨% |
| ៣ | កសិកម្ម | ៣៦ | ៦១ | ១២០ | ៩៧% |
| ៤ | សេវាកម្ម | ៧០៥ | ៦១២ | ៥៤៧ | (១១%) |
| ៥ | សំណង់ | ៥១ | ១៨៤ | ២៦៥ | ៤៤% |
| ៦ | ដឹកជញ្ជូន | ៦០ | ៥៥ | ៥៧ | ៤% |
| ៧ | ផ្សេងៗ | ៧៣ | ៥១៨ | ៨៤៧ | ៦៤% |
| | សរុប | ១.៥៣៥ | ២.១៧៧ | ៣.០២៤ | ៣៩% |

### ផលប័ត្រឥណទាន (ដុល្លារ)

| ល.រ. | វិស័យ | ២០២១ | ២០២២ | ២០២៣ | ប្រែប្រួល |
|---|---|---|---|---|---|
| ១ | ក្រុមគ្រួសារ | ៣.៧៧៨.៣០៦ | ៤.៩៩៥.៥៤២ | ៨.១៣៧.៩០៩ | ៦៣% |
| ២ | ពាណិជ្ជកម្ម | ១.១៦៤.៣៩៣ | ៣.០៥២.៥១៣ | ៣.៤២៨.៤៥២ | ១២% |
| ៣ | កសិកម្ម | ៦០៤.១៥៧ | ១.៦៥៦.៩៧២ | ១.៥០៣.៦៨៤ | (៩%) |
| ៤ | សេវាកម្ម | ៧.៣៥២.២៥២ | ៧.៣១២.២៦៧ | ៥.៨៤៩.៦៦៦ | (២០%) |
| ៥ | សំណង់ | ១.៣៦៦.៤៣៤ | ២.៤៦៨.៤៥៣ | ២.៣៩៦.២៩៨ | (៣%) |
| ៦ | ដឹកជញ្ជូន | ៤៧១.៨៧៩ | ៤២៩.៣៥២ | ៤៦៣.៣២៣ | ៨% |
| ៧ | ផ្សេងៗ | ៧៦៥.៣៩៥ | ៣.៧៦៦.៧៧៩ | ៥.២៥១.៦៤៣ | ៤០% |
| | សរុប | ១៥.៥០២.៨១៦ | ២៣.៦៨១.៨៧៧ | ២៧.០៣០.៩៧៤ | ១៤% |

គ្រឹះស្ថាន ខេមា សម្រេចបានផលប័ត្រឥណទាន ២៧.០៣០.៩៧៤ដុល្លារ ក្នុងឆ្នាំ២០២៣ ក្នុងអត្រាកំណើន ១៤% ដែលអត្រាកំណើននេះទទួលបានពីការកើនឡើងនៃអ្នកប្រើប្រាស់ឥណទានក្នុងវិស័យក្រុមគ្រួសារ ៦៣% និងវិស័យពាណិជ្ជកម្ម ១២% បើទោះបីជាមានការថយចុះក្នុងវិស័យសេវាកម្ម -២០% វិស័យកសិកម្ម -៩% និងវិស័យសំណង់ -៣%។

អត្រាកំណើនផលប័ត្រឥណទានឆ្នាំនេះថមថយជាងឆ្នាំមុនបណ្តាលមកពីបញ្ហាប្រឈមនៃអត្រាកំណើនសេដ្ឋកិច្ចយឺតយ៉ាវនិងបញ្ហាប្រឈមផ្សេងៗប៉ុន្តែអត្រាកំណើននេះខ្ពស់ជាងអត្រាកំណើនក្នុងវិស័យជិតបូនដង។

## សមិទ្ធផលឥណទានតាមផលិតផល
### ចំនួនអតិថិជន

| ល.រ. | ប្រភេទឥណទាន | ២០២១ | ២០២២ | ២០២៣ | ប្រែប្រួល |
|---|---|---|---|---|---|
| ១ | ឥណទានខ្នាតតូចបំផុត | ១៨៤ | ៣៣៥ | ៥១៤ | ៥៣% |
| ២ | ឥណទានខ្នាតតូច | ៣៦៥ | ៣៥៤ | ៣៧៣ | ៥% |
| ៣ | ឥណទានខ្នាតមធ្យម | ៦៦៧ | ៨៧៣ | ១.០១៤ | ១៦% |
| ៤ | ឥណទានក្រុម | ៧៤ | ១៩៧ | ៣៧៩ | ៩២% |
| ៥ | ឥណទានបុគ្គលិក | ៣៨ | ៣៣ | ៥០ | ៥២% |
| ៦ | ឥណទានរហ័ស | ១៣៤ | ២១៤ | ៣១០ | ៤៥% |
| ៧ | ឥណទានកញ្ចប់ | ៣៦ | ៤៧ | ៥២ | ១១% |
| ៨ | ឥណទានអចលនទ្រព្យ | ៣៦ | ៥៤ | ៤៨ | (១១%) |
| ៩ | ឥណទានប្រាក់បៀវត្ស | ១ | ១ | - | - |
| ១០ | ឥណទានគ្មានទ្រព្យធានា | - | ៦០ | ២០០ | ២៣៣% |
| ១១ | ឥណទានយានយន្ត | - | ៩ | ៤១ | ៣៥៦% |
| ១២ | ឥណទានបៃតង | - | - | ៤៣ | - |
| | សរុប | ១.៥៣៥ | ២.១៧៧ | ៣.០២៤ | ៣៩% |

## ផលប័ត្រឥណទាន (ដុល្លារ)

| ល.រ. | ប្រភេទឥណទាន | ២០២១ | ២០២២ | ២០២៣ | ប្រែប្រួល |
|---|---|---|---|---|---|
| ១ | ឥណទានខ្នាតតូចបំផុត | ៤២៣.៣៨១ | ៩៥០.៥៤៩ | ១.៣២៨.៨២៤ | ៤០% |
| ២ | ឥណទានខ្នាតតូច | ១.៧៤៨.៨០៩ | ១.៨១៣.៥៩៧ | ២.០០៧.០២៩ | ១១% |
| ៣ | ឥណទានខ្នាតមធ្យម | ១១.៤៩២.២០១ | ១៧.៧៦៦.៥៦៩ | ១៩.៦០៨.៨៩៣ | ១០% |
| ៤ | ឥណទានក្រុម | ១៨.២៧៦ | ១២៨.៥៣១ | ២៣៨.៧២២ | ៨៦% |
| ៥ | ឥណទានបុគ្គលិក | ៣៤៧.៩០៥ | ២០៥.១៧១ | ៣៤២.៨៤៣ | ៦៧% |
| ៦ | ឥណទានរហ័ស | ១០១.៩៧៨ | ១៩៩.៥៩៨ | ៣៤០.៧១៨ | ៧១% |
| ៧ | ឥណទានកញ្ចប់ | ៦៤៤.៤៣៧ | ១.៥៣៤.៦២០ | ១.៦២៥.០១៥ | ៦% |
| ៨ | ឥណទានអចលនទ្រព្យ | ៧២៥.០៥៨ | ៩២៦.១៤១ | ៧១៥.៤៦៩ | (២៣%) |
| ៩ | ឥណទានប្រាក់បៀវត្ស | ៧៧២ | ១៣២ | - | - |
| ១០ | ឥណទានគ្មានទ្រព្យធានា | - | ១៤៤.៨៤០ | ៤២២.៩៤៤ | ១៩២% |
| ១១ | ឥណទានយានយន្ត | - | ១២.១៣០ | ៣៦០.១៣៣ | - |
| ១២ | ឥណទានបៃតង | - | - | ៤០.៣៤៤ | - |
| | សរុប | ១៥.៥០២.៨១៦ | ២៣.៦៨១.៨៧៧ | ២៧.០៣០.៩៣៤ | ១៤% |

ក្នុងឆ្នាំ២០២៣ ចំនួនអតិថិជនប្រើប្រាស់សេវាឥណទានមានអត្រាកំណើន ៣៩% និងមានចំនួនអតិថិជនសរុប ៣.០២៤នាក់។ សន្ទុះកំណើនអតិថិជន គឺបានពីកំណើនអតិថិជនឥណទានក្រុម ៩២% ឥណទានខ្នាតតូចបំផុត ៥៣% ឥណទានរហ័ស ៤៥% និងកំណើនអតិថិជនឥណទានគ្មានទ្រព្យធានាដែលជាផលិតផលថ្មី។

ផលប័ត្រឥណទានខ្នាតមធ្យម ដែលមានចំណែកធំជាងគេនៃផលប័ត្រឥណទានសរុប ទទួលបានអត្រាកំណើនត្រឹម ១០%។ប៉ុន្តែផលិតផលសក្តានុពលផ្សេងទៀតសម្រេចបានអត្រាកំណើនខ្ពស់ដូចជា ឥណទានក្រុម ៨៦% ឥណទានរហ័ស ៧១% ឥណទានខ្នាតតូចបំផុត ៤០% និងឥណទានគ្មានទ្រព្យធានា ១៩២% ដែលជម្រុញឱ្យអត្រាកំណើនផលប័ត្រឥណទានប្រចាំឆ្នាំកើនឡើងទៅ ១៤%។ ដោយឡែក ឥណទានអចលនទ្រព្យមានកំណើនអវិជ្ជមាន -២៣% នៅក្នុងឆ្នាំ២០២៣។

# សេចក្តីសង្ខេបអំពីសមិទ្ធផលហិរញ្ញវត្ថុ

| **របាយការណ៍លទ្ធផល** | **២០២១** | **២០២២** | **២០២៣** | **ប្រែប្រួល** |
|---|---|---|---|---|
| **របាយការណ៍លទ្ធផល (ដុល្លារ)** | **សវនកម្ម** | **សវនកម្ម** | **សវនកម្ម** | |
| ចំណូលការប្រាក់ | ២.១៤៦.៤៤៣ | ២.៧៩០.៤៩១ | ៣.៧៣៣.៣៣១ | ៣៤% |
| ចំណាយការប្រាក់ | (៥៣៥.៣៦៦) | (៨០០.៦២៦) | (១.២២៣.២៥០) | ៥៣% |
| ចំណូលការប្រាក់សុទ្ធ | ១.៦១១.០៧៧ | ១.៩៨៩.៨៦៥ | ២.៥១០.០៨១ | ២៦% |
| សំវិធានធនលើឥណទានមិនដំណើរការ | (៨០.៥៨០) | (២៥.៣០៤) | (៣០.៨៤២) | ២២% |
| ចំណូលការប្រាក់សុទ្ធបន្ទាប់ពីចំណាយសំវិធានធន | ១.៥៣០.៤៩៧ | ១.៩៦៤.៥៦១ | ២.៤៧៩.២៣៩ | ២៦% |
| ចំណូលប្រតិបត្តិការផ្សេងៗ | ១៤៩.១០៥ | ១០២.០៣២ | ១២៧.៥០២ | ២៥% |
| ចំណាយលើបុគ្គលិក | (៩៥០.៥៧៦) | (១.២២៩.២៩៧) | (១.៥៦៦.៩៩៧) | ២៧% |
| ចំណាយប្រតិបត្តិការផ្សេងៗ | (៣៤៥.១១៤) | (៥៨៧.៦៥១) | (៦១៦.៤២០) | ៥% |
| ចំណាយរំលស់ | (៤២.៦៦០) | (៤៣.៧០២) | (៧២.៩៥៧) | ៦៧% |
| ប្រាក់ចំណេញមុនដកពន្ធ | ៣៤១.២៥២ | ២០៥.៩៤៣ | ៣៥០.៣៦៦ | ៧០% |
| ចំណាយពន្ធលើប្រាក់ចំណេញ | (៧៦.១៨៦) | (៦១.៥៥៣) | (៧៦.៩៧២) | ២៥% |
| ប្រាក់ចំណេញសុទ្ធក្នុងឆ្នាំ | ២៦៥.០៦៦ | ១៤៤.៣៩០ | ២៧៣.៣៩៤ | ៨៩% |

ក្នុងឆ្នាំ២០២៣ គ្រឹះស្ថាន ខេមា មីក្រូហិរញ្ញវត្ថុសម្រេចបានលទ្ធផលប្រាក់ចំណេញក្រោយបង់ពន្ធកើនឡើងគួរឱ្យកត់សម្គាល់ចំនួន ២៧៣.៣៩៤ដុល្លារ ប្រមាណជា ៨៩%។ សមិទ្ធផលនេះរួមចំណែកពីការកើនឡើងប្រាក់កម្ចីដែលបានផ្តល់ជូនអតិថិជនចំនួន ១៤%បង្កើតនូវចំណូលការប្រាក់បានចំនួន ៣,៧លានដុល្លារ ដែលមានកំណើនប្រចាំឆ្នាំប្រមាណ ៣៤% និងមានចំណាយប្រតិបត្តិការកើនឡើងបន្តិចបន្តួចប្រមាណ ៥% ធៀបចំណាយ ឆ្នាំ២០២២ ។ ទោះបីជាចំណាយការប្រាក់មានកំណើនកើនខ្ពស់ប្រមាណ ៥៣% ដោយសារតែការកើនឡើងនៃចំណាយថ្លៃដើមដែលទទួលបានពីម្ចាស់ហិរញ្ញប្បទាន ចំណាយប្រាក់បៀវត្ស និងអត្ថប្រយោជន៍ផ្សេងៗ ក៏មានការកើនឡើងផងដែរប្រមាណ ២៧% និងចំណាយរំលស់លើទ្រព្យសកម្មកើនឡើងយ៉ាងខ្លាំងប្រមាណ ៦៧% ធៀបនឹងឆ្នាំ២០២២ ដើម្បីគាំទ្រលើប្រតិបត្តិការក្នុងឆ្នាំ ២០២៣។

| **របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ** | **២០២១** | **២០២២** | **២០២៣** | **ប្រែប្រួល** |
|---|---|---|---|---|
| **របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ(ដុល្លារ)** | **សវនកម្ម** | **សវនកម្ម** | **សវនកម្ម** | |
| ទ្រព្យសកម្ម | ១៦.៥២៦.៣២៥ | ២៤.៨៤៨.៣៣៣ | ២៧.៦៧៨.៧៧២ | ១១% |
| ឥណទាន និងបុរេប្រទានទៅអតិថិជន | ១៥.៥០២.៨១៦ | ២៣.៦៨១.៨៧៧ | ២៧.០៣០.៩៧៤ | ១៤% |
| ទ្រព្យអកម្ម | ៩.៥៩៧.៥៣៤ | ១៧.៧៧៥.១៥២ | ១៩.៣៣២.១៩៧ | ៩% |
| ប្រាក់កម្ចី | ៩.៤៧៧.២០៤ | ១៧.៥៤៣.១២០ | ១៩.១១៤.៩៨៤ | ៩% |
| ទ្រព្យម្ចាស់ភាគទុនិក | ៦.៩២៨.៧៩១ | ៧.០៧៣.១៨០ | ៨.៣៤៦.៥៧៥ | ១៨% |
| ដើមទុន | ៥.៥៩៣.០០០ | ៥.៥៩៣.០០០ | ៧.៣៤៣.០០០ | ៣១% |
| ប្រាក់ចំណេញសុទ្ធរក្សាទុក | ៧៥៤.៧៤៨ | ៩៤០.៤៣២ | ២៦០.៣៨០ | (៧២%) |
| ទុនបម្រុងបទប្បញ្ញត្តិ | ៥៨១.០៤៣ | ៥៣៩.៧៤៩ | ៧៤៣.១៩៥ | ៣៨% |

ក្នុងឆ្នាំ២០២៣នេះ គ្រឹះស្ថាន ខេមា មានកំណើនទ្រព្យសកម្មតិចតួចប្រមាណ ១១% ស្មើនឹង ២៧,៦លានដុល្លារ ធៀបទៅនឹង ឆ្នាំ២០២២។ ការកើនឡើងនេះ រួមចំណែកពីការកើនឡើងនៃឥណទាន និងបុរេប្រទាន ដែលបានផ្តល់ជូនអតិថិជនប្រមាណ ១៤% ស្មើនឹង ២៧លានដុល្លារអាមេរិក នៅក្នុងឆ្នាំ ២០២៣ នេះ។ ការសម្រេចបាននៃកំណើនទ្រព្យសកម្ម និងផលប័ត្រឥណទានសរុបនេះ គឺទទួលបានប្រភពទុនពីម្ចាស់ដៃគូប្រាក់កម្ចី និងម្ចាស់ភាគទុនិកក្នុងស្រុក ដើម្បីគាំទ្រក្នុងប្រតិបត្តិការអាជីវកម្ម។ ម៉្យាងវិញទៀត ដើម្បីគាំទ្រដល់ការពង្រីកប្រតិបត្តិការតាមផែនការ ៥ឆ្នាំ ខេមា មានតម្រូវការទុនបន្ថែមទៀត ពីម្ចាស់ភាគទុនិក ម្ចាស់កម្ចីទាំងក្នុង និងក្រៅប្រទេស ដើម្បីប្រើប្រាស់ក្នុងអាជីវកម្មតាមផែនការគោលដៅ ដើម្បីសម្រេចបាននូវប្រាក់ចំណេញជានិរន្ត និងរក្សាបានភាពធន់។

ការថយចុះយ៉ាងខ្លាំង នៃប្រាក់ចំណេញរក្សាទុកគឺជះឥទ្ធិពលមកពីការផ្ទេរចំនួន ៧៥០ពាន់ដុល្លារ នៃប្រាក់ចំណេញរក្សាទុកទៅជាដើមទុនចុះបញ្ជី ក្នុងឆ្នាំ២០២៣ និងផ្ទេរចំនួន ២០៣ពាន់ដុល្លារទៅទុនបម្រុងបទប្បញ្ញត្តិដែលជាចំនួនខុសគ្នារវាងសំវិធានធនតាមបទប្បញ្ញត្តិនិងអ៊ីមតែរមិនតាមស្តង់ដារគណនេយ្យ CIFRS for SMEs ។ ហេតុដូច្នេះហើយប្រាក់ចំណេញរក្សាទុកមានការថយចុះយ៉ាងខ្លាំងមានចំនួន -៧២% រីឯដើមទុនចុះបញ្ជីកើនចំនួន ៣១% និងទុនបម្រុងបទប្បញ្ញត្តិក៏មានការកើនឡើងចំនួន ៣៨% គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ ។

| អនុបាតសំខាន់សម្រេចបាន | ២០២១ | ២០២២ | ២០២៣ |
|---|---|---|---|
| ចំណេញធៀបនឹងទ្រព្យសកម្ម | ១,៦០% | ០,៦០% | ១,០៣% |
| ចំណេញធៀបនឹងទ្រព្យម្ចាស់ | ៣,៨៣% | ២,០៤% | ៣,៦២% |
| ចំណាយប្រតិបត្តិការធៀបនឹងឥណទាន | ៩,៨១% | ៩,៨១% | ៩,២៣% |
| ចំណាយសរុបថ្លៃដើមធៀបនឹងចំណូលប្រតិបត្តិការ | ៨៨,៤៥% | ៩៥,០១% | ៩៣,៥៤% |
| អនុបាតសាច់ប្រាក់ងាយស្រួល | ១០០% | ១០០% | ១០០% |
| អនុបាតសាធនភាព | ៣៩,៣៧% | ៣៥,៦៩% | ៣១,០៥% |
| ហានិភ័យឥណទានធំជាង ៣០ថ្ងៃ | ៣,៤៤% | ៣,៩២% | ៥,៥៤% |

សមិទ្ធផលហិរញ្ញវត្ថុរបស់គ្រឹះស្ថាន ខេមា មីក្រូហិរញ្ញវត្ថុ លីមីតធីត ក្នុងឆ្នាំ២០២៣ កើនឡើងគួរឱ្យកត់សម្គាល់ពី ០,៦០% ដល់ ១,០៣% ដោយសារតែមានការកើនឡើងលើប្រាក់ចំណេញដែលសម្រេចបានក្នុងឆ្នាំមានចំនួន ៨៩% និងអនុបាតមូលធនក៏មានកំណើនកើនឡើងផងដែរពី ២,០៤% ដល់ ៣,៦២% ធៀបនឹងឆ្នាំ២០២២។ ម៉្យាងវិញទៀត អនុបាតចំណាយប្រតិបត្តិការមានការថយចុះបើធៀបទៅនឹងអនុបាតឆ្នាំ២០២២ ពី ៩,៨១% ទៅ ៩,២៣% នៅឆ្នាំ២០២៣ ចំណែកអនុបាតចំណាយថ្លៃដើមក៏មានការថយចុះប្រមាណ ១,៤៧% ធៀបនឹងឆ្នាំ២០២២។ កត្តាថយចុះទាំងអស់នេះជាហេតុនាំឱ្យមានការកើនឡើងអនុបាតលើប្រាក់ចំណេញខ្ពស់ដល់ ៨៩% ដែលបង្ហាញថា គ្រឹះស្ថាន ខេមា ទទួលបាននូវនិរន្តរភាពប្រាក់ចំណេញ និងមានភាពធន់ក្នុងកិច្ចការប្រកបអាជីវកម្ម។

បន្ថែមពីនេះទៀត គ្រឹះស្ថាន ខេមា មីក្រូហិរញ្ញវត្ថុរក្សាបាននូវអនុបាតសាច់ប្រាក់ងាយស្រួល ១០០% និងអនុបាតសាធនភាព ៣១,០៥% ដែលខ្ពស់ជាងកម្រិត អនុលោមភាពជាអប្បបរមាដែលតម្រូវដោយធនាគារជាតិនៃកម្ពុជាដែលកំណត់ឱ្យរក្សាមិនឱ្យតិចជាង១៥%។ការគ្រប់គ្រងគុណភាពប្រាក់កម្ចីមានហានិភ័យចាប់ពី ៣០ថ្ងៃ មានអត្រា ៥,៥៤% មានការកើនឡើងគួរឱ្យកត់សម្គាល់បើធៀបនឹងឆ្នាំមុន(អត្រា ៣,៩២%) ប៉ុន្តែការកើនឡើងនេះ ស្ថិតក្នុងអត្រាកំណើនជាមធ្យមនៃវិស័យហិរញ្ញវត្ថុទាំងមូល។

## ទស្សនវិស័យឆ្នាំ២០២៤

ឆ្នាំ២០២៤ គ្រឹះស្ថាន ខេមា មីក្រូហិរញ្ញវត្ថុ លីមីតធីត នឹងបង្កើនប្រាក់ចំណូលរបស់ខ្លួន ដោយជំរុញការបញ្ចេញទុនប្រមាណ ៣៤% កើនឡើងជាងឆ្នាំមុន តាមការផ្ដល់ទុនជាទ្រព្យសកម្មដែលមានការប្រាក់ដូចជា ឥណទានមានទ្រព្យធានា ឥណទានខ្នាតតូចបំផុត ឥណទានខ្នាតតូច និងមធ្យម ឥណទានកសិកម្ម ផលិតផលឥណទានបៃតង និងឥណទានទឹកស្អាតនិងអនាម័យ ដល់សហគមន៍បន្ថែមទៀត។

ដើម្បីគាំទ្រកំណើននៃទ្រព្យសកម្មរបស់ខ្លួន ថ្នាក់គ្រប់គ្រងត្រូវបន្តពង្រីកតំបន់ប្រតិបត្តិការរបស់ខ្លួនទៅតំបន់សក្ដានុពលដែលមិនមានហានិភ័យកើតឡើង និងផ្ដោតលើការបង្កើតបន្ថែមនូវផលិតផលឌីជីថល។

គណៈគ្រប់គ្រងយកចិត្តទុកដាក់ផងដែរ លើការធ្វើឱ្យកាន់តែប្រសើរឡើងនូវផលិតផល និងសេវាកម្មរបស់ខ្លួន ភ្ជាប់ជាមួយនឹងបច្ចេកវិទ្យាតិចណូឡូជី ដែលមានផលចំណេញដល់អតិថិជនក្នុងការប្រើប្រាស់។ ដោយនាំមកនូវបទពិសោធន៍ដ៏សម្បូរបែបក្នុងការប្រើប្រាស់នូវផលិតផល និងសេវាកម្មឌីជីថលដែលរួមចំណែកឱ្យមានកំណើនប្រកបដោយនិរន្តរភាពចំពោះអតិថិជនរបស់ខ្លួនផងដែរ។

គណៈគ្រប់គ្រងគ្រឹះស្ថានត្រូវបង្កើនផលិតភាពការងាររបស់បុគ្គលិកប្រកបដោយប្រសិទ្ធភាព ដោយប្ដូរមកប្រើប្រាស់ប្រព័ន្ធអនុម័តឥណទាន (Loan Originating System) ដោយប្រើប្រាស់ Tablet ដែលអាចជួយឱ្យបុគ្គលិកអាចអនុវត្តប្រតិបត្តិការធនាគារពីចម្ងាយភ្ជាប់មកប្រព័ន្ធគ្រប់គ្រងចុះបញ្ជីធនាគារស្នូលដោយផ្ទាល់។ បន្ថែមជាងនេះទៀត អ្នកគ្រប់គ្រងនៅតែបន្តរក្សានូវការត្រួតពិនិត្យដោយប្រុងប្រយ័ត្ន លើការគ្រប់គ្រងគុណភាពទ្រព្យសកម្មបន្ថែមដើម្បីកាត់បន្ថយនូវប្រាក់កម្ចីមិនដំណើរការ។

គ្រឹះស្ថាន ខេមា មីក្រូហិរញ្ញវត្ថុ លីមីតធីត នឹងបន្តផ្ដោតការយកចិត្តទុកដាក់ ថែរក្សានូវកម្រិតសុខភាពសន្ទនីយភាពតាមការរក្សានូវ អនុបាតសាច់ប្រាក់ងាយស្រួល និងអនុបាតសាធនភាព ឱ្យអនុលោមតាមការកំណត់របស់និយ័តករ ក្នុងការគាំទ្រកំណើនកើនឡើងប្រកបដោយ សុខភាព និងជានិរន្តរភាពផងដែរ។




# បណ្តុះបណ្តាល និងអភិវឌ្ឍន៍សមត្ថភាពបុគ្គលិក

### ការលើកទឹកចិត្តបុគ្គលិកលើសមិទ្ធផល

ភាពរីកចម្រើន និងសមិទ្ធផលជាវិជ្ជមានរបស់គ្រឹះស្ថានជាលទ្ធផលដែលបានកើតឡើងពីការខិតខំប្រឹងប្រែងរបស់គណៈគ្រប់គ្រង និងបុគ្គលិកទាំងអស់របស់គ្រឹះស្ថាន ខេមា។ ដើម្បីឆ្លើយតបទៅនឹងភាពរីកចម្រើន និងការខិតខំប្រឹងប្រែងរបស់បុគ្គលិក គណៈគ្រប់គ្រងរបស់គ្រឹះស្ថាន បានសម្រេចធ្វើការកែប្រែ និងបន្ថែមទៅលើអត្ថប្រយោជន៍ផ្សេងៗមួយចំនួនជូនបុគ្គលិក ដើម្បីលើកទឹកចិត្តដល់បុគ្គលិក ទោះបីស្ថិតក្នុងកាលៈទេសៈនៃវិបត្តិសេដ្ឋកិច្ចជាសកលក៏ដោយ ។ មិនតែប៉ុណ្ណោះ គណៈគ្រប់គ្រងក៏បានសម្រេចនៅតែបន្តផ្តល់ប្រាក់រង្វាន់លើកទឹកចិត្តប្រចាំខែ និងប្រចាំត្រីមាស ជូនដល់គ្រប់បុគ្គលិកឥណទាន និងសម្រេចផ្តល់ប្រាក់លើកទឹកចិត្តបំណាច់ឆ្នាំ (Annual Incentive/Bonus) ជូនដល់សាខាផងដែរ ដែលបានខិតខំប្រឹងប្រែងសម្រេចទៅតាមផែនការដែលបានកំណត់។ លើសពីនេះទៅទៀត គ្រឹះស្ថានបានដំឡើងឋានៈ និងតួនាទីដល់បុគ្គលិកសរុបចំនួន ៤រូប (១,៩៧%) ធៀបនឹងចំនួនបុគ្គលិកក្នុងបំណាច់ឆ្នាំ២០២៣ សរុប ២០៣រូប ។

### ការអភិវឌ្ឍចំណេះជំនាញដល់បុគ្គលិក

ដើម្បីធានាបាននូវគុណភាពផលិតផល និងសេវាកម្មជូនដល់អតិថិជន គ្រឹះស្ថាន ខេមា បានយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើការអភិវឌ្ឍធនធានមនុស្សដោយបានវិនិយោគទាំងពេលវេលា និងថវិកា សម្រាប់ការបង្កើតឱ្យមានកម្មវិធីកសាងសមត្ថភាពបុគ្គលិក ដោយផ្តល់ឱកាសសម្រាប់បុគ្គលិកក្នុងការចូលរួមវគ្គបណ្តុះបណ្តាលទាំងខាងក្នុង និងខាងក្រៅគ្រឹះស្ថាន។ គ្រឹះស្ថានបានរៀបចំវគ្គបណ្តុះបណ្តាលខាងក្នុងសម្រាប់ជំនាញបច្ចេកទេស និងជំនាញពាក់ព័ន្ធនឹងការអនុវត្តការងារប្រចាំថ្ងៃនិងលើគោលនយោបាយផ្សេងៗរបស់គ្រឹះស្ថានសរុបចំនួន ៥៣វគ្គ ដែលមានសិក្ខាកាមចូលរួម សរុបចំនួន ៦៨៣រូប។ ការអភិវឌ្ឍចំណេះដឹង ជំនាញ និងផ្នត់គំនិតរបស់បុគ្គលិកគ្រប់ជាន់ថ្នាក់ គឺដើម្បីឱ្យមានលក្ខណៈ សមស្របទៅនឹងបច្ចុប្បន្នភាពនៃទីផ្សារធនាគារ និងមីក្រូហិរញ្ញវត្ថុ និងបរិបទនៃភាពរីកចម្រើនរបស់ គ្រឹះស្ថាន ខេមា ផងដែរ។

លើសពីនេះទៅទៀត គ្រឹះស្ថាន ខេមា ក៏បានបញ្ជូនបុគ្គលិកសរុបចំនួន ១១២រូប សរុបចំនួន ១៩វគ្គ ឱ្យទៅចូល

រួមក្នុងវគ្គបណ្តុះបណ្តាលខាងក្រៅគ្រឹះស្ថាន ដែលក្នុងនោះ រួមមានវគ្គខ្លីទាំងជំនាញទន់ និងជំនាញរឹង ចំនួន ១០២រូប ថ្នាក់ភាសាអង់គ្លេសទូទៅ ១រូប ថ្នាក់បរិញ្ញាបត្ររង ១រូប សិក្សាថ្នាក់បរិញ្ញាបត្រ ១រូប ព្រមទាំងបរិញ្ញាបត្រជាន់ខ្ពស់ ចំនួន ៧រូប ដែលបានរៀបចំដោយសមាគម វិទ្យាស្ថាន និង សាកលវិទ្យាល័យនានាដើម្បីកសាងសមត្ថភាពរបស់បុគ្គលិក បន្ថែមទៀតក្នុងការដឹកនាំគ្រឹះស្ថាន ខេមា ឱ្យមានភាពរលូន និងប្រកបដោយប្រសិទ្ធភាពខ្ពស់។

| សូចនាករ | ២០២០ | ២០២១ | ២០២២ | ២០២៣ |
|---|---|---|---|---|
| ចំនួនបុគ្គលិកសរុប | ១២០ | ១២៩ | ១៧០ | ២០៣ |
| ចំនួនបុគ្គលិកឥណទានសរុប | ៥៤ | ៤៣ | ៥៦ | ៧៨ |
| ភាគរយ(%)បុគ្គលិកស្រី | ៣០% | ២៩% | ២៨% | ២៧% |
| ភាគរយ(%) បុគ្គលិកប្រុស | ៧០% | ៧១% | ៧២% | ៧៣% |

### ការផ្តល់ឱកាសដល់និស្សិតហាត់ការ និងចុះកម្មសិក្សា

ក្នុងឆ្នាំ២០២៣ គ្រឹះស្ថាន ខេមា បានទទួលស្វាគមន៍ ក្រុមនិស្សិតចុះកម្មសិក្សាចំនួន ២ក្រុម និងចុះហាត់ការងារ ១រូប ដែលមានសមាជិកសរុបចំនួន ១២រូប (ស្រី ១២រូប) ហើយគ្រឹះស្ថានក៏បានផ្តល់ឱកាសការងារសម្រាប់និស្សិតដែល បានចុះកម្មសិក្សា និងបុគ្គលិកហាត់ការ ឱ្យក្លាយជាបុគ្គលិក របស់គ្រឹះស្ថាននាពេលអនាគត។

### សុខុមាលភាពរបស់បុគ្គលិក

ជាផ្នែកមួយនៃចក្ខុវិស័យរបស់គ្រឹះស្ថាន ខេមា ការ បង្កើតឱ្យមានភាពសុខដុមរមនានៃបរិយាកាសការងារមួយដ៏ អស្ចារ្យ និងភាពរីករាយដែលបុគ្គលិកអាចមានការអភិវឌ្ឍ និង លូតលាស់ ជាមួយស្ថាប័នដែលមានវប្បធម៌ដ៏រឹងមាំក្នុងការ លើកកម្ពស់ការធ្វើការជាក្រុម តាមរយៈសកម្មភាពសំខាន់ៗ ជាច្រើនដែលបានផ្តួចផ្តើម និងបង្កើតឡើងក្នុងឆ្នាំនីមួយៗ។ គ្រឹះស្ថាន ក៏បានបង្កើតឱ្យមានកម្មវិធីជួបជុំរួមមាន អាហារ សាមគ្គីព្រមទាំងសិក្ខាសាលាប្រចាំឆ្នាំផងដែរក្នុងគោលបំណង ដើម្បីពង្រឹងទំនាក់ទំនងនិងបង្កើតឱ្យមានភាពស្និទ្ធស្នាលរវាង ថ្នាក់គ្រប់គ្រងនិងបុគ្គលិកការិយាល័យកណ្តាលនិងគ្រប់សាខា ទាំងអស់របស់គ្រឹះស្ថាន ខេមា។

លើសពីនេះទៅទៀត គ្រឹះស្ថាន ខេមា ក៏បានអនុញ្ញាត ឱ្យបេក្ខជន ចំនួន ១រូប បានចូលបម្រើការងារជាបុគ្គលិកហាត់ ការជាមួយគ្រឹះស្ថាន ដោយមើលឃើញថា បុគ្គលិក មានភាព ស្មោះត្រង់ សមត្ថភាព ការខិតខំប្រឹងប្រែងបំពេញការងារ និង ស្របតាមតម្រូវការរបស់គ្រឹះស្ថាន ត្រូវបានដំឡើងតួនាទី ពី បុគ្គលិកហាត់ការ ទៅជាបុគ្គលិកពេញសិទ្ធិរបស់គ្រឹះស្ថាន ផងដែរ។

# អំពីអតិថិជន

“ដៃគូហិរញ្ញវត្ថុដ៏ល្អបំផុត” ជាពាក្យស្លោក និងជាការប្តេជ្ញាចិត្តរបស់គ្រឹះស្ថាន ខេមា ក្នុងការផ្តល់សេវាហិរញ្ញវត្ថុប្រកបដោយបរិយាប័ន្ន និងភាពច្នៃប្រឌិតដល់ប្រជាជនកម្ពុជា ដើម្បីឱ្យពួកគាត់មានលទ្ធភាពទទួលបាននូវសេវាហិរញ្ញវត្ថុផ្លូវការ ដើម្បីពង្រីកមុខរបរ បង្កើនប្រាក់ចំណូល និងលើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ពួកគាត់។

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ គ្រឹះស្ថាន ខេមា មានអតិថិជនសរុប ៣.០២៤នាក់ ហើយក្នុងនោះប្រមាណ ៥៩% នៃអតិថិជនជាស្ត្រី។ ទំហំកម្ចីឯកត្តជនជាមធ្យមគឺប្រមាណ ៩.២៥៨ដុល្លារ ហើយទំហំកម្ចីក្រុមជាមធ្យមគឺ ៥៧២ដុល្លារ។ អតិថិជនរបស់គ្រឹះស្ថាន ខេមា ប្រើប្រាស់កម្ចីជាមធ្យមចំនួន ២វគ្គ ហើយអតិថិជនប្រមាណ ១៩,៨៥% ស្ថិតនៅក្រុមអាយុចន្លោះពី ៤០-៤៤ឆ្នាំ និងលើសពាក់កណ្តាល (៥២,១៣%) នៃអតិថិជនសរុបមានអាយុក្រោម ៤០ឆ្នាំ។




| សូចនាករសំខាន់ៗ | ជនបទ | ទីប្រជុំជន |
|---|---|---|
| ចំនួនអតិថិជនសរុប | ២២% | ៧៨% |
| អតិថិជនកម្ចីក្រុម | ៣០% | ៧០% |
| អតិថិជនកម្ចីឯកត្តជន | ២១% | ៧៩% |
| ចំនួនវគ្គកម្ចីជាមធ្យម | ១,២៧ | ២,០៩ |
| អាយុជាមធ្យម | ៣៩ឆ្នាំ | ៣៩ឆ្នាំ |

គ្រឹះស្ថាន ខេមា ប្រមូលទិន្នន័យរៀងរាល់ឆ្នាំស្តីពីការពេញចិត្តរបស់អតិថិជនមកលើ ផលិតផល និងសេវាកម្មរបស់ស្ថាប័ន ដើម្បីប្រើប្រាស់ជាធាតុចូលក្នុងការកែលម្អផលិតផល និងសេវាអតិថិជន ឱ្យកាន់តែល្អជាលំដាប់។ គ្រឹះស្ថានបានកំណត់សូចនាករសំខាន់ៗ ដែលត្រូវប្រមូលទិន្នន័យ និងបែងចែកកម្រិតនៃការពេញចិត្តរបស់អតិថិជនជាប្រាំកម្រិតៈ (១)មិនពេញចិត្តសោះ (២)មិនពេញចិត្ត (៣)មធ្យម (៤)ពេញចិត្ត និង (៥)ពេញចិត្តខ្លាំងណាស់។

យោងលើរបាយការណ៍ស្រាវជ្រាវទីផ្សារស្តីពីការពេញចិត្តរបស់អតិថិជនមកលើគ្រឹះស្ថាន ឆមាសទី២ ឆ្នាំ២០២៣ បង្ហាញថា អតិថិជនភាគច្រើន ៨៣% ពេញចិត្តគ្រឹះស្ថាន ខេមា ១២%ពេញចិត្តខ្លាំងណាស់ និង ៥%មធ្យម ដោយគ្មានអតិថិជនមិនពេញចិត្តនឹងគ្រឹះស្ថានឡើយ។




ឧបករណ៍វាស់វែងសន្ទស្សន៍នៃការចាកផុតពីភាពក្រីក្រ (PPI) ត្រូវបានប្រើប្រាស់ដើម្បីវាស់វែងពីការផ្តល់សេវាហិរញ្ញវត្ថុរបស់គ្រឹះស្ថាន ខេមា ទៅកាន់អតិថិជនក្រីក្រ និងលទ្ធភាពក្នុងការផ្លាស់ប្តូរជីវភាពរស់នៅរបស់អតិថិជន។ តាមរយៈសន្ទស្សន៍នៃការចាកផុតពីភាពក្រីក្រ គ្រឹះស្ថានក៏អាចកំណត់ពីកម្រិតជីវភាពរបស់អតិថិជនគោលដៅក្នុងន័យអភិវឌ្ឍផលិតផលបានសមស្រប និងចំគោលដៅរបស់អតិថិជន។

យោងលើរបាយការណ៍ស្រាវជ្រាវស្តីពី សន្ទស្សន៍នៃការចាកផុតពីភាពក្រីក្រ (PPI) ឆមាសទី២ ឆ្នាំ២០២៣ បង្ហាញថា អតិថិជនគ្រឹះស្ថាន ខេមា ភាគច្រើន ៥៨,២៦% ស្ថិតនៅក្រុមមនុស្សដែលមានចំណូលទាប ៣១,៥៦% មានកម្រិតជីវភាពមិនក្រ ១០,០១% មានកម្រិតជីវភាពក្រ និង ០,១៧% មានកម្រិតជីវភាពក្រខ្លាំង ។



# ៤

# ការរីកចម្រើនប្រកបដោយនិរន្តរភាព

- កិច្ចការពារបរិស្ថាន សង្គម និងអភិបាលកិច្ច
- អនុលោមភាពគោលការណ៍ការពារអតិថិជន
- ទំនួលខុសត្រូវក្នុងសង្គម
- ការលើកកម្ពស់សមភាពយេនឌ័រ
- ផលិតផលដែលជួយលើកកម្ពស់បរិស្ថាន និងសង្គម
- អតិថិជនរបស់ ខេមា

# ការរីកចម្រើនប្រកបដោយនិរន្តរភាព

ក្នុងនាមជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលប្តេជ្ញាចិត្តយ៉ាងមុតមាំក្នុងការផ្តល់សេវាហិរញ្ញវត្ថុប្រកបដោយបរិយាប័ន្ន និងទំនួលខុសត្រូវខ្ពស់ជូនប្រជាជនកម្ពុជា និងរក្សាបាននូវអត្ថប្រយោជន៍ជូនអតិថិជន ភាគទុនិក និងសង្គមជាតិ ប្រកបដោយប្រសិទ្ធភាព និងនិរន្តរភាព គ្រឹះស្ថាន ខេមា បានយកចិត្តទុកដាក់លើការអនុវត្តបទដ្ឋានការពារបរិស្ថាន សង្គម និងអភិបាលកិច្ច អនុលោមភាពគោលការណ៍ការពារអតិថិជន និងចូលរួមចំណែកអភិវឌ្ឍសហគមន៍តាមរយៈផលិតផលដែលជួយលើកកម្ពស់បរិស្ថាន និងសង្គម។

នៅឆ្នាំ២០២៤ គ្រឹះស្ថាន ខេមា នឹងបង្កើនការយកចិត្តទុកដាក់លើ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDG) ដោយបង្កើនការយកចិត្តទុកដាក់លើការដាក់បញ្ចូលបទដ្ឋានការពារបរិស្ថាន សង្គម និងអភិបាលកិច្ច ទៅក្នុងគោលការណ៍ និងនីតិវិធីរបស់ខ្លួន។ គ្រឹះស្ថាននឹងបង្កើតឱ្យមានឧបករណ៍វាស់វែងលើសមិទ្ធផលបរិស្ថាន និងសង្គម ព្រមទាំងគ្រោងបង្កើតឱ្យមានផ្នែកគ្រប់គ្រងការរីកចម្រើនប្រកបដោយនិរន្តរភាពនៅក្នុងរចនាសម្ព័ន្ធរបស់គ្រឹះស្ថាន ដោយស្ថិតក្រោមការគ្រប់គ្រងរបស់នាយកដ្ឋានទីផ្សារ និងអភិវឌ្ឍន៍ផលិតផល។

# កិច្ចការពារបរិស្ថាន សង្គម និងអភិបាលកិច្ច

គ្រឹះស្ថាន ខេមា មីក្រូហិរញ្ញវត្ថុ លីមីតធីត ប្តេជ្ញាចិត្តរួមចំណែកក្នុងកិច្ចការពារសង្គម និងបរិស្ថាន និងការអនុវត្តទៅតាមបទប្បញ្ញត្តិនៃព្រះរាជាណាចក្រកម្ពុជា និងគោលការណ៍ហិរញ្ញវត្ថុប្រកបដោយចីរភាពកម្ពុជា (CSFP)។ គ្រឹះស្ថាន ខេមា បានយកចិត្តទុកដាក់បំផុតចំពោះបរិស្ថាន សង្គម ការពារមនុស្សជាតិ និងអភិរក្សបេតិកភណ្ឌវប្បធម៌ តាមរយៈការសិក្សាវាយតម្លៃ ការគ្រប់គ្រង ការកាត់បន្ថយការទូទាត់សំណង ឬការបញ្ចៀសនូវរាល់ហានិភ័យ ឬផលប៉ះពាល់អវិជ្ជមានសំខាន់ៗដែលកើតចេញពីសកម្មភាពអាជីវកម្មរបស់អតិថិជន។ ដូច្នេះរាល់សកម្មភាពអាជីវកម្មរបស់អតិថិជនត្រូវអនុវត្តដូចខាងក្រោម៖

- អនុលោមតាមច្បាប់ និងបទប្បញ្ញត្តិបរិស្ថាន និងសង្គមជាតិ និងបទដ្ឋានអនុវត្តរបស់គ្រឹះស្ថាន ខេមា
- គោរពបទដ្ឋានអនុវត្តបរិស្ថាននិងសង្គម ដោយត្រូវចៀសវាងដាច់ខាតនូវការបង្កផលប៉ះពាល់ធ្ងន់ធ្ងរដល់បរិស្ថាន និងសង្គម។

បទដ្ឋានការពារបរិស្ថាន សង្គម និងអភិបាលកិច្ចរបស់គ្រឹះស្ថាន ខេមា ផ្តោតទៅលើ៖

- ហានិភ័យ និងផលប៉ះពាល់ដល់បរិស្ថាន និងសង្គម
- ពលកម្ម និងលក្ខខណ្ឌការងារ និងសុខភាព សុវត្ថិភាព និងសុខុមាលភាពសហគមន៍
- ការប្រើប្រាស់ធនធានប្រកបដោយសុវត្ថិភាព និងការគ្រប់គ្រងការបំពុលបរិស្ថាន
- លទ្ធកម្មដីធ្លី និងតាំងទីលំនៅដោយមិនស្ម័គ្រចិត្ត
- ការអភិរក្សជីវចម្រុះ និងការគ្រប់គ្រងធនធានធម្មជាតិមានជីវិតប្រកបដោយចីរភាព
- ជនជាតិដើមភាគតិច និងបេតិកភណ្ឌវប្បធម៌។

### បញ្ជីមុខរបរ ឬសកម្មភាពអាជីវកម្មហាមឃាត់

គ្រឹះស្ថាន ខេមា នឹងមិនផ្តល់ប្រាក់កម្ចីដល់សកម្មភាពទាំងឡាយ នៅក្នុងបញ្ជីមុខរបរ ឬសកម្មភាពអាជីវកម្មហាមឃាត់ដូចខាងក្រោម៖

១. ផលិតកម្ម ឬសកម្មភាពអាជីវកម្មទាំងឡាយណា ដែលពាក់ព័ន្ធនឹងពលកម្មដែលមានគ្រោះថ្នាក់ ឬធ្វើអាជីវកម្មដោយប្រើប្រាស់កម្លាំងពលកម្មបង្ខំ ឬការប្រើប្រាស់ពលកម្មកុមារ
២. ផលិតកម្ម ឬពាណិជ្ជកម្មអាវុធជាតិផ្ទុះ និងគ្រាប់រំសេវ
៣. ល្បែងស៊ីសង កាស៊ីណូ ពេស្យាចារ និងសហគ្រាសដែលមានសកម្មភាពស្រដៀងគ្នា
៤. ពាណិជ្ជកម្មសត្វព្រៃ ឬផលិតផលអំពីសត្វព្រៃ ដែលបានកំណត់ដោយច្បាប់
៥. ផលិតកម្ម ឬពាណិជ្ជកម្មសម្ភារវិទ្យុសកម្ម។ សកម្មភាពនេះមិនរាប់បញ្ចូលចំពោះការទិញឧបករណ៍វេជ្ជសាស្ត្រ ឧបករណ៍ត្រួតពិនិត្យគុណភាព ( ឧបករណ៍វាស់វែង ) និង

ឧបករណ៍ណាមួយដែលគ្រឹះស្ថានចាត់ទុកថាមានប្រភពវិទ្យុសកម្មតិចតួចបំផុត ឬបានការពារគ្រប់គ្រាន់

៦. ផលិតកម្ម ឬពាណិជ្ជកម្មផលិតផល ឬសកម្មភាពណាមួយដែលត្រូវបានចាត់ទុកថាខុសច្បាប់ ឬបទប្បញ្ញត្តិនៃព្រះរាជាណាចក្រកម្ពុជា ឬអនុសញ្ញា និងកិច្ចព្រមព្រៀងអន្តរជាតិឬដែលជាកម្មវត្ថុត្រូវហាមឃាត់ជាអន្តរជាតិដូចជាៈ ថ្នាំសម្លាប់សត្វល្អិត ថ្នាំសម្លាប់ស្មៅដែលមានសារធាតុបំផ្លាញស្រទាប់អូហ្សូន ផលិតផលដែលផ្ទុកសារធាតុ PCBs ផលិតផលអំពីសត្វព្រៃដែលបញ្ញត្តិដោយកិច្ចព្រមព្រៀង CITES

៧. ផលិតកម្ម និងពាណិជ្ជកម្មលើផលិតផលណា ដែលជាកម្មវត្ថុនៃការកាត់បន្ថយ ឬហាមឃាត់ជាអន្តរជាតិ ដែលគ្រឹះស្ថានបានដឹងឮជាផ្លូវការ

៨. ផលិតកម្ម ឬសេវាកម្ម ដែលធ្វើឱ្យប៉ះពាល់ធ្ងន់ធ្ងរដល់បរិស្ថានធម្មជាតិ ហើយដែលត្រូវបានហាមឃាត់ដោយច្បាប់នៃព្រះរាជាណាចក្រកម្ពុជា

៩. សកម្មភាពដទៃផ្សេងទៀតដែលមិនស្របទៅនឹងច្បាប់ឬនិយតកម្មនានា នៃព្រះរាជាណាចក្រកម្ពុជា ឬអនុសញ្ញា និងកិច្ចព្រមព្រៀងអន្តរជាតិ

១០. ផលិតកម្ម ឬពាណិជ្ជកម្មឈើ ឬផលិតផលព្រៃឈើដទៃទៀត ក្រៅពីព្រៃឈើដែលមានការគ្រប់គ្រងប្រកបដោយចីរភាព

១១. ផលិតកម្ម ឬពាណិជ្ជកម្មថ្នាំជក់

១២. ផលិតកម្ម ឬពាណិជ្ជកម្មភេសជ្ជៈមានជាតិអាល់កុល (លើកលែងស្រាបៀរ និងស្រាក្រហម)

១៣. ផលិតកម្ម ឬពាណិជ្ជកម្ម ឬសកម្មភាពអាជីវកម្មប្រើប្រាស់សារធាតុ Unbounded Asbestos Fiber។ សកម្មភាពនេះមិនអនុវត្តចំពោះការទិញ និងការប្រើប្រាស់ហ្វីប្រូស៊ីម៉ង់ត៍ដែលផ្ទុកសារធាតុ asbestos ក្នុងបរិមាណតិចជាង ២០ភាគរយ

១៤. ពាណិជ្ជកម្មដែលបានមកពីប្រតិបត្តិការកាប់ឈើសម្រាប់ប្រើប្រាស់ក្នុងព្រៃត្រូពិច

១៥. ផលិតកម្ម ឬពាណិជ្ជកម្ម ស្តុក ឬការដឹកជញ្ជូនសារធាតុគីមីគ្រោះថ្នាក់ក្នុងបរិមាណច្រើន ឬការប្រើប្រាស់សារធាតុគីមីដែលមានកម្រិតគ្រោះថ្នាក់ខ្ពស់ក្នុងការធ្វើអាជីវកម្ម។ សារធាតុគីមីដែលមានគ្រោះថ្នាក់រួមមានៈ ប្រេងសាំង ប្រេងកាត និងផលិតផលប្រេងផ្សេងទៀត

១៦. ផលិតកម្ម ឬពាណិជ្ជកម្មឱសថ ដែលអន្តរជាតិកាត់បន្ថយ ឬហាមឃាត់

១៧. ផលិតកម្ម ឬពាណិជ្ជកម្មថ្នាំសម្លាប់សត្វល្អិត/តិណជាតិដែលអន្តរជាតិកាត់បន្ថយ ឬហាមឃាត់

១៨. ផលិតកម្ម ឬពាណិជ្ជកម្មសារធាតុបំផ្លាញស្រទាប់អូហ្សូនដែលអន្តរជាតិកាត់បន្ថយ/ហាមឃាត់

១៩. ការនេសាទក្នុងដែនសមុទ្រដែលប្រើប្រាស់មងអួស/អួនដែលមានប្រវែងលើសពី ២,៥គីឡូម៉ែត្រ

២០. ផលិតកម្ម ឬសកម្មភាពទាំងឡាយណា ដែលប៉ះពាល់ដល់ដីដែលជាកម្មសិទ្ធិរបស់ជនជាតិដើមភាគតិចឬមិនមែនជនជាតិដើមភាគតិចឬដែលទាមទារតវ៉ាពីសំណាក់ជនជាតិទាំងនោះ ដោយគ្មានឯកសារយល់ព្រមពេញលេញពីជនជាតិដើមភាគតិច

២១. ផលិតកម្ម ឬសកម្មភាពចែកចាយព័ត៌មានដែលប្រឆាំងនឹងលទ្ធិប្រជាធិបតេយ្យ ឬព័ត៌មានដែលផ្សាយពីការរើសអើងពូជសាសន៍។

# អនុលោមភាពគោលការណ៍ការពារអតិថិជន

គ្រឹះស្ថាន ខេមា មីក្រូហិរញ្ញវត្ថុ លីមីតធីត យកចិត្តទុកដាក់នូវការអនុវត្តក្រមសីលធម៌កម្រិតខ្ពស់បំផុត និងប្រកាន់ខ្ជាប់ជានិច្ចនូវគោលគំនិតទិសដៅមូលដ្ឋានបីសំខាន់គឺៈ មនុស្ស ផែនដី និងប្រាក់ចំណេញ ព្រមជាមួយគ្នានឹងការគោរពចំពោះបរិស្ថាន សង្គម និងសហគមន៍ដែលយើងរស់នៅ។ ដូច្នេះ គ្រឹះស្ថាន ខេមា ប្រកាន់ខ្ជាប់នូវគោលការណ៍ណែនាំទាំងប្រាំបី នៃការការពារអតិថិជនដូចជាៈ

### ការបង្កើត និងការផ្តត់ផ្គង់ផលិតផលសមស្រប

គ្រឹះស្ថាន ខេមា យកចិត្តទុកដាក់លើការអភិវឌ្ឍផលិតផល និងនីតិវិធីក្នុងការផ្តល់ផលិតផលកម្ចី និងសេវាកម្មនានាដល់អតិថិជន សមស្របតាមតម្រូវការទីផ្សារបច្ចុប្បន្ន និងបញ្ចៀសផលប៉ះពាល់អវិជ្ជមានចំពោះអតិថិជន។ផលិតផលរបស់គ្រឹះស្ថាន ខេមា ត្រូវបានអភិវឌ្ឍឡើងដោយមានលក្ខណៈ

សមស្រប តម្លៃសមរម្យ ភាពងាយស្រួលក្នុងការទទួលបាន នីតិវិធីនៃការផ្តល់កម្ចីមានភាពងាយស្រួល និងកំណត់ថ្លៃសេវាអប្បបរមា។ គ្រឹះស្ថាន ខេមា ក៏បានធ្វើការស្រាវជ្រាវបន្ទាប់ពីដាក់ឱ្យដំណើរការផលិតផលថ្មីដើម្បីកែលម្អផលិតផលឱ្យកាន់តែប្រសើរឡើង។

## ការបង្ការបំណុលហួសកម្រិត

គ្រឹះស្ថាន ខេមា យកចិត្តទុកដាក់រៀបចំនីតិវិធីឥណទាន ដើម្បីកំណត់លទ្ធភាពរបស់អតិថិជនឱ្យបានច្បាស់លាស់ និងពង្រឹងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដែលអាចបញ្ចៀសបាននូវបំណុលលើសលទ្ធភាព។ គ្រឹះស្ថាន ខេមា តម្រូវឱ្យប្រមូលព័ត៌មានពីប្រភពនានា និងចូលត្រួតពិនិត្យប្រវត្តិឥណទានរបស់អតិថិជនក្នុងប្រព័ន្ធចែករំលែកព័ត៌មានឥណទាន មុននឹងអនុម័តប្រាក់កម្ចី ដែលមានប្រសិទ្ធភាពក្នុងការបញ្ចៀសនូវបំណុលលើសលទ្ធភាព។ ក្រៅពីនេះ ការស្នើសុំកម្ចីត្រូវបានបែងចែកទៅតាមទំហំ និងលក្ខខណ្ឌ ហើយគណៈកម្មការឥណទាននឹងធ្វើការត្រួតពិនិត្យពីលទ្ធភាពសង និងកម្រិតហានិភ័យយ៉ាងហ្មត់ចត់មុននឹងអនុម័ត។

## តម្លាភាព

គ្រឹះស្ថានផ្តល់ព័ត៌មានពេញលេញ ច្បាស់លាស់ និងទាន់ពេលវេលា ជូនអតិថិជនអំពីលក្ខខណ្ឌឥណទាន អត្រាការប្រាក់ កម្រៃសេវា នីតិវិធីនៃការផ្តល់កម្ចី និងការដោះស្រាយបំណុលដែលមានបញ្ហាដើម្បីជួយសម្រួលដល់ការសម្រេចចិត្តរបស់អតិថិជន។គ្រឹះស្ថានក៏បានបណ្តុះបណ្តាលបុគ្គលិកអំពីវិធីសាស្ត្រទំនាក់ទំនងជាមួយអតិថិជនប្រកបដោយតម្លាភាព និងប្រសិទ្ធភាព ជាពិសេស ការប្រាស្រ័យទាក់ទងជាមួយអតិថិជនដែលជាអនក្ខរជន។ គ្រឹះស្ថានផ្តល់ព័ត៌មានស្តីពីការប្រាក់មានប្រសិទ្ធភាព និងការប្រាក់សរុបប្រចាំឆ្នាំដល់អតិថិជន ដោយអនុលោមទៅតាមច្បាប់នៃ ធនាគារជាតិនៃកម្ពុជា។ ក្រៅពីនេះ គ្រឹះស្ថាន ខេមា បានប្រើប្រាស់មធ្យោបាយជាច្រើនដើម្បីផ្សព្វផ្សាយព័ត៌មានផលិតផលទៅកាន់អតិថិជន ដូចជា៖ ខិត្តបណ្ណ ប័ណ្ណប្រកាស សៀវភៅទិនានុលេខន៍ បណ្តាញសង្គម និងវិបសាយថ៍។

## សមភាព និងការគោរពអតិថិជន

គ្រឹះស្ថានផ្តល់តម្លៃឱ្យអតិថិជនស្មើៗគ្នាដោយមិនរើសអើង និងប្រកាន់ខ្ជាប់ខ្ជួននូវ គុណតម្លៃស្នូល និងក្រមសីលធម៌វិជ្ជាជីវៈ របស់គ្រឹះស្ថាន ហើយគ្រប់បុគ្គលិកទាំងអស់សុទ្ធតែទទួលបានការអប់រំយ៉ាងល្អ ដើម្បីបញ្ចៀសការរើសអើងជាតិសាសន៍ ភេទ សាសនា និងចរិតលក្ខណៈរបស់អតិថិជន។

## ការរក្សាព័ត៌មានសម្ងាត់របស់អតិថិជន

ព័ត៌មានរបស់អតិថិជនត្រូវបានគ្រឹះស្ថាន ខេមា រក្សាទុកជាការសម្ងាត់ ដោយអនុលោមទៅតាមច្បាប់ នៃព្រះរាជាណាចក្រកម្ពុជា និងបទបញ្ជាផ្ទៃក្នុងរបស់គ្រឹះស្ថាន ខេមា។ ព័ត៌មានទាំងនោះអាចត្រូវបានប្រើប្រាស់ ឬចែករំលែកទៅភាគីទីបីបាន លុះត្រាតែមានការអនុញ្ញាតពីគ្រឹះស្ថាន ខេមា ឬមានការព្រមព្រៀងពីអតិថិជន។ គ្រឹះស្ថាន ខេមា មិនអនុញ្ញាតឱ្យបុគ្គលិកប្រើប្រាស់ប្រព័ន្ធអ៊ីនធើណិតដើម្បីបញ្ជូនទិន្នន័យរបស់អតិថិជនក្នុងប្រតិបត្តិការការងារ ក្នុងន័យដើម្បីថែរក្សាសុវត្ថិភាពព័ត៌មានរបស់អតិថិជន។

## យន្តការដោះស្រាយបណ្តឹងរបស់អតិថិជន

គ្រឹះស្ថាន ខេមា យកចិត្តទុកដាក់បម្រើសេវា និងថែរក្សាអតិថិជន ដោយបានបង្កើត គោលការណ៍ និងនីតិវិធីគ្រប់គ្រងបណ្តឹងតវ៉ារបស់អតិថិជន។ តាមរយៈគោលការណ៍នេះ គ្រឹះស្ថានតែងតែផ្តល់ដំណោះស្រាយសមរម្យ និងឆ្លើយតបទៅកាន់អតិថិជនវិញទាន់ពេលវេលា។ ព័ត៌មានបណ្តឹងតវ៉ាដែលទទួលបានត្រូវបានប្រើប្រាស់ដើម្បីកែលម្អលក្ខណៈផលិតផល និងធ្វើឱ្យប្រសើរឡើងនូវគុណភាពសេវាកម្មជូនអតិថិជន។

## អភិបាលកិច្ច និងការគ្រប់គ្រង ប្តេជ្ញាចិត្ត ក្នុងកិច្ចការពារអតិថិជន

គ្រឹះស្ថានយកចិត្តទុកដាក់ក្នុងការអនុវត្តអភិបាលកិច្ចការពារអតិថិជន ដោយបង្កើតឱ្យមានរចនាសម្ព័ន្ធធនធានមនុស្ស រៀបចំឱ្យមានគោលការណ៍ និងនីតិវិធីក្នុងការគាំទ្រដល់ការអនុវត្តកិច្ចការពារអតិថិជន។ គ្រឹះស្ថានបានពង្រឹងការអនុវត្តយន្តការបណ្តឹងតវ៉ារបស់អតិថិជនដោយដំឡើងការតាមដានត្រួតពិនិត្យដល់កម្រិតក្រុមប្រឹក្សាភិបាល។

# ទំនួលខុសត្រូវក្នុងសង្គម

## ការយល់ដឹងអំពីបរិស្ថាន និងហិរញ្ញវត្ថុ

គ្រឹះស្ថានបានបោះពុម្ពខិត្តប័ណ្ណ ៤.០០០សន្លឹក និងប័ណ្ណប្រកាសចំនួន ១.០០០សន្លឹក សម្រាប់ផ្សព្វផ្សាយទៅកាន់ភូមិ-ឃុំ គោលដៅ ដើម្បីបញ្ជ្រាបការយល់ដឹងអំពីសារៈសំខាន់នៃបង្គន់អនាម័យ និងផលប៉ះពាល់ជាអវិជ្ជមានបណ្ដាលមកពីការទទួលទានទឹកមិនស្អាត និងខ្វះអនាម័យ។ គ្រឹះស្ថានក៏បានផ្សព្វផ្សាយខ្លឹមសាររូបភាពនេះនៅលើបណ្ដាញសង្គមរបស់គ្រឹះស្ថានផងដែរ។ បន្ថែមលើការផ្សព្វផ្សាយអំពីសារៈសំខាន់នៃទឹកស្អាតនិងអនាម័យ ខេមា ក៏បានផ្សព្វផ្សាយគន្លឹះខ្លីៗក្នុងការសន្សំសំចៃប្រាក់ និងថែរក្សាបរិស្ថាន តាមរយៈបណ្ដាញសង្គមរបស់គ្រឹះស្ថាន។

ក្រៅពីនេះ គ្រឹះស្ថានក៏បានរចនារូបភាពគន្លឹះខ្លីៗអំពីចំណេះដឹងហិរញ្ញវត្ថុស្ដីពីការសន្សំប្រាក់ ប្រាក់កម្ចី ការរៀបចំផែនការហិរញ្ញវត្ថុ និងចំណេះដឹងក្នុងការចាត់ចែងលុយកាក់ផ្សេងៗ ដើម្បីផ្សព្វផ្សាយនៅលើបណ្ដាញសង្គម។ គ្រឹះស្ថានក៏បានចូលរួមសហការផ្សព្វផ្សាយកម្មវិធី«វិថីហិរញ្ញវត្ថុ»ដែលផលិតដោយក្រុមហ៊ុន អប្សរា មេឌា សឺវីស (AMS) សហការជាមួយ សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា សមាគមធនាគារនៅកម្ពុជា ក្រុមហ៊ុនក្រេឌីតប្យូរ៉ូ (ខេមបូឌា) ខូអិលធីឌី និងក្រោមការគាំទ្រពី ធនាគារជាតិនៃកម្ពុជា។

នៅឆ្នាំ២០២៤ គ្រឹះស្ថាននឹងបន្តផ្សព្វផ្សាយកម្មវិធី«វិថីហិរញ្ញវត្ថុ» និងផ្សព្វផ្សាយចំណេះដឹងហិរញ្ញវត្ថុបន្ថែមទៀតនៅតាមបណ្ដាញសង្គម។ ក្រៅពីនេះ គ្រឹះស្ថានក៏គ្រោងនឹងផ្សព្វផ្សាយវីដេអូអំពីសារៈសំខាន់នៃការប្រើប្រាស់ទឹកស្អាត បង្គន់ និងអនាម័យ ដើម្បីបញ្ជ្រាបការយល់ដឹងទៅកាន់សាធារណជន។

## គ្រឹះស្ថាន ខេមា ដាំដើមឈើ ២០០ដើម នៅស្រុកបសេដ្ឋ

គ្រឹះស្ថាន ខេមា មីក្រូហិរញ្ញវត្ថុ លីមីតធីត បានរៀបចំព្រឹត្តិការណ៍សហគមន៍ដោយធ្វើសកម្មភាពដាំដើមឈើប្រណីតចំនួន ២០០ដើម នៅសាលាបឋមសិក្សា តានួន កាលពីថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២៣ គឺចំថ្ងៃខួប ១៣ឆ្នាំ នៃគ្រឹះស្ថាន ខេមា។

ព្រឹត្តិការណ៍សហគមន៍ ដែលបានប្រព្រឹត្តទៅនៅភូមិបឹងស្នុក ឃុំបសេដ្ឋ ស្រុកបសេដ្ឋ ខេត្តកំពង់ស្ពឺ ជាសកម្មភាពមួយស្របនឹងទិសដៅសង្គមរបស់គ្រឹះស្ថាន ខេមា ដែលយកចិត្តទុកដាក់លើផលប៉ះពាល់ចំពោះសង្គម និងបរិស្ថាន។

ក្រៅពីការដាំដើមឈើ គណៈគ្រប់គ្រងរបស់គ្រឹះស្ថាន ខេមា ក៏បានប្រគល់ជូននូវសម្ភារមួយចំនួនដល់សាលាដូចជា៖ ម៉ាស៊ីនកាត់ស្មៅចបប៉ែលបង្គីធុងស្រោចទឹក និងធុងសម្រាមបរិស្ថាន ដើម្បីយកទៅប្រើប្រាស់ជាប្រយោជន៍នៅក្នុងសាលាផងដែរ។

កម្មវិធីនេះមានវត្តមានចូលរួមរបស់ លោកអគ្គនាយកប្រតិបត្តិស្ដីទី លោកនាយកសាលា លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស និងបុគ្គលិកគ្រឹះស្ថាន ខេមា សរុបជាង ៣០០នាក់។




# ការលើកកម្ពស់សមភាពយេនឌ័រ

គ្រឹះស្ថាន ខេមា មានបេសកកម្មផ្តោតការយកចិត្តទុកដាក់លើការផ្តល់ឥណទានដល់អតិថិជនស្ត្រី និងលើកកម្ពស់សមភាពយេនឌ័រនៅក្នុងគ្រឹះស្ថាន។ នៅឆ្នាំ២០២៣ ក្នុងចំណោមអតិថិជនសរុប ៣.០២៤នាក់ មានអតិថិជនចំនួន ១.៧៨៤នាក់ ជាស្ត្រី ដែលស្មើនឹងប្រមាណ ៥៩% នៃអតិថិជនសរុប។

ជាគ្រឹះស្ថានដែលត្រូវបានផ្តួចផ្តើមបង្កើតឡើងដោយសហគ្រិនស្ត្រី គ្រឹះស្ថាន ខេមា តែងតែផ្តោតការយកចិត្តទុកដាក់ និងផ្តល់តម្លៃខ្ពស់ចំពោះបុគ្គលិកជាស្ត្រីគ្រប់កម្រិតតួនាទី។ ជាក់ស្តែង ក្រុមប្រឹក្សាភិបាល នៃគ្រឹះស្ថាន ខេមា មានប្រធានក្រុមប្រឹក្សាភិបាលជាស្ត្រី និងសមាជិកមួយរូបក្នុងចំណោមពីររូប ជាស្ត្រី។ គ្រឹះស្ថានមានបុគ្គលិកឥណទានជាស្ត្រីចំនួន ៤រូប ហើយ ២៩% នៃបុគ្គលិកស្ត្រីសរុបមានតំណែង ជាគណៈគ្រប់គ្រងនៅក្នុងគ្រឹះស្ថាន។

គ្រឹះស្ថាន ខេមា បានយកចិត្តទុកដាក់ខ្ពស់ចំពោះការអភិវឌ្ឍចំណេះជំនាញដល់បុគ្គលិក ជាពិសេសបុគ្គលិកស្ត្រី។ នាឆ្នាំ២០២៣ ក្នុងចំណោមបុគ្គលិកសរុបចំនួន ៧រូប ដែលទទួលបានអាហារូបករណ៍សិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ពីគ្រឹះស្ថាន មានបុគ្គលិក ៥រូបជាស្ត្រី ។






# ផលិតផលដែលជួយលើកកម្ពស់បរិស្ថាន និងសង្គម

ក្នុងការយកចិត្តទុកដាក់លើកិច្ចការពារបរិស្ថាន សង្គម និងអភិបាលកិច្ច និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព គ្រឹះស្ថាន ខេមា បានអភិវឌ្ឍផលិតផលឥណទានបៃតង និងឥណទានទឹកស្អាតនិងអនាម័យ ដើម្បីលើកកម្ពស់កិច្ចគាំពារបរិស្ថាន សុខុមាលភាព និងជីវភាពរស់នៅរបស់អតិថិជន។

## ឥណទានបៃតង

ឥណទានបៃតងត្រូវបានអភិវឌ្ឍឡើង និងដាក់ឱ្យដំណើរការក្នុងខែកក្កដា ឆ្នាំ២០២៣ ក្នុងគោលបំណងធ្វើឱ្យប្រសើរឡើងនូវជីវភាពរស់នៅ បរិស្ថាន ឬវិនិយោគលើអាជីវកម្មភាតរៈបរិស្ថានដែលចូលរួមចំណែកកាត់បន្ថយផលប៉ះពាល់អវិជ្ជមានលើបរិស្ថាន ឬបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ។

គ្រឹះស្ថានក៏បានសហការជាមួយក្រុមហ៊ុន យ៉ាឌា ខេមបូឌា ដើម្បីផ្តល់ប្រាក់កម្ចីសម្រាប់ទិញម៉ូតូអគ្គិសនី។ តាមរយៈកិច្ចសហការនេះ អតិថិជនអាចស្នើកម្ចីទិញម៉ូតូអគ្គិសនីម៉ាក យ៉ាឌា ដោយមិនតម្រូវឱ្យដាក់ទ្រព្យធានា។ ដូច្នេះអតិថិជនមានភាពងាយស្រួលក្នុងការស្នើកម្ចីទិញយានជំនិះដែលមានលក្ខណៈសន្សំសំចៃ និងកាត់បន្ថយផលប៉ះពាល់ចំពោះបរិស្ថាន។

គិតត្រឹមបំណាច់ឆ្នាំ២០២៣ គ្រឹះស្ថាន ខេមា បានផ្តល់ឥណទានបៃតងដល់អតិថិជនចំនួន ៤៩នាក់ និងមានផលប័ត្រឥណទានចំនួន ៤២.១០០ដុល្លារ។

## ឥណទានទឹកស្អាតនិងអនាម័យ

ឥណទានទឹកស្អាតនិងអនាម័យ ត្រូវបានផ្តល់ជូនដល់អតិថិជនក្នុងគោលបំណងផ្តល់លទ្ធភាពឱ្យពួកគាត់ទទួលបានទឹកស្អាតប្រើប្រាស់ មានបង្គន់អនាម័យ និងរួមចំណែកលើកកម្ពស់សុខុមាលភាពសហគមន៍។ គិតត្រឹមបំណាច់ឆ្នាំ ២០២៣ មានអតិថិជន ១២០នាក់ កំពុងប្រើប្រាស់ប្រាក់កម្ចីទឹកស្អាតនិងអនាម័យ និងមានផលប័ត្រឥណទានប្រមាណ ៨០.៤១៤ដុល្លារអាមេរិក ក្នុងនោះមានចំនួន ៧៤% ប្រើប្រាស់ក្នុងគោលបំណងសាងសង់ឬជួសជុលបង្គន់អនាម័យ ២១% ប្រើប្រាស់ក្នុងគោលបំណងតបណ្តាញទឹកស្អាតនិងសាងសង់បង្គន់អនាម័យ និង ៥% ប្រើប្រាស់ក្នុងគោលបំណងតបណ្តាញទឹកស្អាត។

គ្រឹះស្ថាន ខេមា បានចាប់ដៃគូជាមួយអង្គការ Water.org ដោយបានចុះកិច្ចព្រមព្រៀងដើម្បីចាប់ផ្តើមអនុវត្តគម្រោងហិរញ្ញប្បទានទឹកស្អាតនិងអនាម័យដល់គ្រឹះស្ថានឥណទានជនបទនៅថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២៣។ ក្នុងភាពជាដៃគូនេះ គ្រឹះស្ថាន ខេមា ទទួលបានជំនួយគាំទ្រពីអង្គការ Water.org ដើម្បីបញ្ជ្រាបការយល់ដឹងអំពីសារៈសំខាន់នៃការប្រើប្រាស់ទឹកស្អាត និងអនាម័យ ផ្សព្វផ្សាយឥណទានទឹកស្អាតនិងអនាម័យ តាមរយៈការផ្តល់ហិរញ្ញប្បទានដល់គ្រឹះស្ថានឥណទានជនបទ យកទៅផ្តល់កម្ចីបន្តដល់អតិថិជនរបស់ខ្លួន។



# អតិថិជនរបស់ ខេមា

អ្នកស្រី ញឹម វណ្ណា ប្រកបរបរលោកអ៊ុតសម្លៀកបំពាក់ នៅភូមិកំពង់ត្រាចទី១ ឃុំកំពង់ត្រាចខាងកើត ស្រុកកំពង់ត្រាច ខេត្តកំពត។ ស្ត្រីវ័យ ៤៧ឆ្នាំរូបនេះរម្លឹកថា អ្នកស្រីបានមករស់នៅទីនេះតាំងតែក្រោយការដួលរលំនៃរបបខ្មែរក្រហមមកម្ល៉េះ។ កាលនោះអ្នកស្រីរស់នៅក្នុងផ្ទះតូច និងគ្មានបង្គន់អនាម័យប្រើប្រាស់នៅឡើយទេ។

អ្នកស្រីបានសាងសង់ផ្ទះឡើងវិញនៅឆ្នាំ២០០១ ប៉ុន្តែនៅមិនទាន់មានបង្គន់អនាម័យប្រើប្រាស់នៅឡើយដែលតម្រូវឱ្យអ្នកស្រី និងស្វាមី រួមទាំងកូនស្រីពីរនាក់ និងប្រុសម្នាក់ ត្រូវបង្ខំចិត្តធាក់កង់ទៅគុម្ពោតព្រៃចម្ងាយប្រមាណ ៥០០ម៉ែត្រពីផ្ទះ។ ដោយក្តីបារម្ភពីសុវត្ថិភាព និងសត្វអាសិរពិស សមាជិកគ្រួសារអ្នកស្រីមិនហ៊ានទៅគុម្ពោតព្រៃតែម្នាក់ឯងទេនៅពេលយប់ គឺត្រូវដាស់សមាជិកគ្រួសារដទៃទៅជាមួយ។ អ្នកស្រីបានឱ្យដឹងថា កូនៗរបស់អ្នកស្រីធ្លាប់កើតជម្ងឺគ្រុនឈាមធ្ងន់ធ្ងរដោយសារតែការបន្ទោបង់ក្នុងព្រៃដែលមានមូសច្រើន។

ស្ថិតនៅក្បែរផ្សារកំពង់ត្រាច ច្រកចូលពីផ្លូវជាតិលេខ ៣១ផ្ទះអ្នកស្រីមានទឹកស្អាតប្រើប្រាស់តាំងតែពីឆ្នាំ២០០៧។ នៅជុំវិញផ្ទះអ្នកស្រីលែងសូវមានគុម្ពោតព្រៃបន្ទោបង់ដូចពីមុន ព្រោះអ្នកជិតខាងបានសាងសង់លំនៅដ្ឋានស្ទើរពេញទៅហើយ។ មិនខុសពីអ្នកជិតខាង អ្នកស្រីត្រូវសាងសង់ផ្ទះថ្មី និងបង្គន់អនាម័យ។ ដោយថវិកានៅស្តួចស្តើង អ្នកស្រីសម្រេចចិត្តស្នើឥណទានទឹកស្អាតនិងអនាម័យពី គ្រឹះស្ថាន ខេមា ចំនួន ៣លានរៀល ដើម្បីសាងសង់បន្ទប់ទឹក។

អ្នកស្រីបានប្រៀបធៀបគុណភាពនៃការរស់នៅមុន និងក្រោយមានបង្គន់អនាម័យប្រើប្រាស់ថាៈ "កាលពីមុនពិបាកមាំណាស់ អត់មានបន្ទប់ទឹកត្រូវបន្ទោបង់ក្នុងព្រៃ។ កូនស្រីចេញក្រៅយប់ព្រលប់អីចេះតែខ្លាចសត្វផងអីផង។ ឥឡូវបានមានបន្ទប់ទឹក មានផ្ទះមានអីត្រឹមត្រូវនៅ លែងពិបាកដូចពីមុនហើយ។ សុខសុវត្ថិភាព ចំណេញពេលវេលា សុខភាពក៏ល្អមិនសូវឈឺ"។

# ៥

# របាយការណ៍ហិរញ្ញវត្ថុ និង
# របាយការណ៍របស់សវនករឯករាជ្យ

- របាយការណ៍របស់ក្រុមប្រឹក្សាភិបាល
- របាយការណ៍របស់សវនករឯករាជ្យ
- របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ
- របាយការណ៍លទ្ធផលលម្អិត
- របាយការណ៍ស្តីពីបម្រែបម្រួលមូលធន
- របាយការណ៍លំហូរទឹកប្រាក់

# របាយការណ៍របស់ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលមានសេចក្តីសោមនស្សរីករាយសូមធ្វើការបង្ហាញជូននូវរបាយការណ៍របស់ក្រុមប្រឹក្សាភិបាលនិងរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួចរបស់ ខេមាមីក្រូហិរញ្ញវត្ថុ លីមីតធីត ហៅកាត់ថា ("ក្រុមហ៊ុន") សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០២៣ ។

## សកម្មភាពចម្បង

សកម្មភាពចម្បងរបស់ក្រុមហ៊ុន គឺការផ្តល់សេវាមីក្រូហិរញ្ញវត្ថុដល់សហគមន៍សហគ្រាសធុនតូចនិងមធ្យមនិងកសិកម្មជនបទ ប្រកបដោយប្រសិទ្ធភាព និរន្តរភាព និងការទទួលខុសត្រូវ ជាពិសេសស្ត្រី។

## លទ្ធផលហិរញ្ញវត្ថុ

លទ្ធផលហិរញ្ញវត្ថុរបស់ក្រុមហ៊ុនសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ មានដូចខាងក្រោម៖

| | ២០២៣ | | ២០២២ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ប្រាក់ចំណេញមុនដកពន្ធ | ៣៥០.៣៦៦ | ១.៤៤០.០០៤ | ២០៥.៩៤៣ | ៨៤១.៦៨៩ |
| ចំណាយពន្ធលើប្រាក់ចំណេញ | (៧៦.៩៧២) | (៣១៦.៣៥៥) | (៦១.៥៥៣) | (២៥១.៥៦៧) |
| ប្រាក់ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ | ២៧៣.៣៩៤ | ១.១២៣.៦៤៩ | ១៤៤.៣៩០ | ៥៩០.១២២ |

## ដើមទុន

ពុំមានការប្រែប្រួលរចនាសម្ព័ន្ធភាគហ៊ុន ក្នុងអំឡុងការិយបរិច្ឆេទហិរញ្ញវត្ថុនេះទេ។ សូមមើលកំណត់សម្គាល់ ១៧ សម្រាប់ព័ត៌មានលម្អិត។

## ភាគលាភ

នាកាលបរិច្ឆេទនៃរបាយការណ៍នេះ ពុំមានការប្រកាសឬបែងចែកភាគលាភឡើយ ហើយក្រុមប្រឹក្សាភិបាលក៏ពុំមានអនុសាសន៍ឲ្យមានការបែងចែកភាគលាភ សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ នោះដែរ។

## ទុនបម្រុង និងសំវិធានធន

ពុំមានការប្រែប្រួលជាសារវន្តនៃទុនបម្រុង និងសំវិធានធននៅក្នុងការិយបរិច្ឆេទហិរញ្ញវត្ថុនេះ ក្រៅពីការបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនេះឡើយ។

## ឥណទានអាក្រក់ និងជាប់សង្ស័យ

នៅមុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុ របស់ក្រុមហ៊ុនត្រូវបានរៀបចំឡើង ក្រុមប្រឹក្សាភិបាលបានចាត់វិធានការសមស្របនានា ដើម្បីធ្វើឲ្យប្រាកដថានីតិវិធីពាក់ព័ន្ធជាមួយនឹងការលុបចោលឥណទានអាក្រក់ និងការធ្វើសំវិធានធនលើឥណទានជាប់សង្ស័យ ត្រូវបានយកមកអនុវត្ត ហើយក្រុមប្រឹក្សាភិបាលជឿជាក់ថា រាល់ឥណទានអាក្រក់ ដែលបានដឹងថាមិនអាចទារមកវិញបានត្រូវបានលុបចោល ហើយសំវិធានធនត្រូវបានប៉ាន់ស្មានសមស្របសម្រាប់ ឥណទានអាក្រក់ និងជាប់សង្ស័យ។

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីព្រឹត្តិការណ៍ណាមួយដែលអាចបណ្តាលឲ្យចំនួនទឹកប្រាក់នៃឥណទានអាក្រក់ដែលបានលុបចោល ឬចំនួនទឹកប្រាក់សំវិធានធនលើឥណទានជាប់សង្ស័យនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន មានចំនួនមិនគ្រប់គ្រាន់ជាសារវន្តនោះទេ។

## ទ្រព្យសកម្ម

នៅមុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនត្រូវបានរៀបចំឡើង ក្រុមប្រឹក្សាភិបាលបានចាត់វិធានការសមស្របនានា ដើម្បីបញ្ជាក់ថាបណ្តាទ្រព្យសកម្មរយៈពេលខ្លីទាំងអស់ក្រៅពីឥណទាន ដែលទំនងជាមិនអាចទទួលស្គាល់បាននៅក្នុងប្រតិបត្តិការអាជីវកម្មធម្មតាក្នុងតម្លៃរបស់វាដែលបានកត់ត្រានៅក្នុងបញ្ជីគណនេយ្យរបស់ក្រុមហ៊ុន ត្រូវបានបន្ថយនៅស្មើនឹងតម្លៃដែលគិតថានឹងអាចទទួលស្គាល់បានជាក់ស្តែង។

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សា

ភិបាលពុំបានដឹងពីហេតុការណ៍ណាមួយដែលអាចបណ្តាលឲ្យការកំណត់តម្លៃទ្រព្យសកម្មរយៈពេលខ្លីនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន មានភាពមិនត្រឹមត្រូវនោះទេ។

## វិធីសាស្ត្រកំណត់តម្លៃ

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយដែលបានកើតឡើង ហើយនឹងធ្វើឲ្យប៉ះពាល់ដល់ការអនុវត្តវិធីសាស្ត្រ ដែលមានកន្លងមកក្នុងការវាយតម្លៃទ្រព្យសកម្ម និងបំណុលនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនមានភាពមិនត្រឹមត្រូវនិងមិនសមស្របនោះទេ។

## បំណុលយថាហេតុ និងបំណុលផ្សេងៗ

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ គឺពុំមាន៖

(ក) ការដាក់បញ្ចាំទ្រព្យសកម្មណាមួយ របស់ក្រុមហ៊ុនចាប់តាំងពីថ្ងៃចុងការិយបរិច្ឆេទហិរញ្ញវត្ថុមកក្នុងការធានាចំពោះបំណុលរបស់បុគ្គលណាម្នាក់ឡើយ ឬ

(ខ) បំណុលយថាហេតុណាមួយដែលកើតមានឡើងចំពោះក្រុមហ៊ុន ចាប់តាំងពីចុងការិយបរិច្ឆេទហិរញ្ញវត្ថុមកក្រៅអំពីប្រតិបត្តិការអាជីវកម្ម ធម្មតារបស់ក្រុមហ៊ុនឡើយ។

ក្រុមប្រឹក្សាភិបាលមានមតិថាពុំមានបំណុលយថាហេតុឬបំណុលផ្សេងទៀតរបស់ក្រុមហ៊ុនដែលត្រូវបំពេញឬអាចនឹងត្រូវបំពេញក្នុងរយៈពេល ១២ខែ បន្ទាប់ពីចុងការិយបរិច្ឆេទហិរញ្ញវត្ថុដែលនឹងធ្វើឲ្យមានផលប៉ះពាល់ឬអាចនឹងប៉ះពាល់ជាសារវន្តដល់លទ្ធភាពរបស់ក្រុមហ៊ុន ក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួនដូចដែលបានកំណត់ និងនៅពេលដែលដល់ថ្ងៃកំណត់។

## ក្រុមប្រឹក្សាភិបាល

សមាជិកក្រុមប្រឹក្សាភិបាល នៅក្នុងការិយបរិច្ឆេទ និងនាកាលបរិច្ឆេទនៃរបាយការណ៍នេះ រួមមាន៖

- លោកស្រី **ឌិត នីតា** ប្រធានក្រុមប្រឹក្សាភិបាល
- លោក **ខូវ សូវៀត** អភិបាល
- លោកស្រី **យូ បូរី** អភិបាលឯករាជ្យ

## ប្រតិបត្តិការមិនប្រក្រតី

ក្រុមប្រឹក្សាភិបាលមានមតិថា លទ្ធផលនៃការធ្វើប្រតិបត្តិការរបស់ក្រុមហ៊ុនក្នុងការិយបរិច្ឆេទហិរញ្ញវត្ថុនេះមិនមានផលប៉ះពាល់ជាសារវន្តដោយសកម្មភាពប្រតិបត្តិការ ឬព្រឹត្តិការណ៍ណាមួយដែលមានលក្ខណៈជាសារវន្ត និងមិនប្រក្រតីនោះទេ។

ក្រុមប្រឹក្សាភិបាលក៏មានមតិផងដែរថា នៅក្នុងចន្លោះពេលចាប់ពីថ្ងៃចុងការិយបរិច្ឆេទហិរញ្ញវត្ថុ ដល់ថ្ងៃចេញរបាយការណ៍នេះ ពុំមានចំណាត់ថ្នាក់សកម្មភាពប្រតិបត្តិការ ឬព្រឹត្តិការណ៍ណាមួយដែលមានលក្ខណៈ ជាសារវន្ត និងមិនប្រក្រតីកើតមានឡើងដែលអាចនាំឲ្យប៉ះពាល់ជាសារវន្តដល់លទ្ធផលនៃប្រតិបត្តិការរបស់ក្រុមហ៊ុន ក្នុងកាលបរិច្ឆេទហិរញ្ញវត្ថុដែលរបាយការណ៍នេះបានរៀបចំឡើងនោះទេ។

## ភាគកម្មរបស់ក្រុមប្រឹក្សាភិបាល

ព័ត៌មានស្តីពីភាគហ៊ុនក្រុមហ៊ុន និងអភិបាលរបស់ខ្លួនក្នុងការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ មានដូចខាងក្រោម៖

| | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ (%) ភាគរយនៃម្ចាស់កម្មសិទ្ធ | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ (%) ភាគរយនៃម្ចាស់កម្មសិទ្ធ |
|---|---|---|
| លោកស្រី ឌិត នីតា | ៤៨,៤៤% | ៤០,៣១% |

ក្រៅពីព័ត៌មានបង្ហាញខាងលើ អភិបាលមិនបានកាន់ភាគហ៊ុនណាមួយនៅក្នុងក្រុមហ៊ុនឬនៅក្នុងក្រុមហ៊ុនដែលទាក់ទងគ្នាណាមួយឡើយ។

## អត្ថប្រយោជន៍របស់ក្រុមប្រឹក្សាភិបាល

នៅក្នុងអំឡុងការិយបរិច្ឆេទ និងនាចុងការិយបរិច្ឆេទហិរញ្ញវត្ថុនេះពុំមានកិច្ចព្រមព្រៀងណាមួយដែលក្រុមហ៊ុនជាភាគីម្ខាងដែលកម្មវត្ថុនៃកិច្ចព្រមព្រៀងនោះបានផ្តល់លទ្ធភាពដល់ក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន ឲ្យទទួលបាននូវអត្ថប្រយោជន៍តាមមធ្យោបាយនៃការទិញភាគហ៊ុននោះឡើយ។

ចាប់តាំងពីចុងការិយបរិច្ឆេទហិរញ្ញវត្ថុមុន ពុំមានក្រុមប្រឹក្សាភិបាលណាម្នាក់បានទទួល ឬមានសិទ្ធិទទួលបាននូវអត្ថប្រយោជន៍ណាមួយ (ក្រៅពីអត្ថប្រយោជន៍ ដែលបានរួមបញ្ចូលនៅក្នុងបរិលាភសរុបទទួលបានឬដល់កំណត់ទទួលបានដោយក្រុមប្រឹក្សាភិបាលដូចបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ) តាមរយៈការចុះកិច្ចសន្យាធ្វើឡើងដោយក្រុមហ៊ុន ឬដោយសាជីវកម្មពាក់ព័ន្ធណាមួយ ជាមួយនឹង

ក្រុមហ៊ុនណាមួយដែលក្រុមប្រឹក្សាភិបាលនោះជាសមាជិកនៃក្រុមហ៊ុននោះឬក៏ជាមួយក្រុមហ៊ុនដែលសមាជិកក្រុមប្រឹក្សាភិបាលនោះមានភាគកម្មផ្នែកហិរញ្ញវត្ថុជាសារវន្តនោះទេ លើកលែងតែអ្វីដែលបានបង្ហាញ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនេះ។

## ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលលើរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាលមានភារៈ ធ្វើការអះអាងបញ្ជាក់ថារបាយការណ៍ហិរញ្ញវត្ថុ បានរៀបចំឡើងយ៉ាងត្រឹមត្រូវជាសារវន្ត បង្ហាញនូវភាពត្រឹមត្រូវនៃស្ថានភាពហិរញ្ញវត្ថុ របស់ក្រុមហ៊ុន នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរទឹកប្រាក់របស់ក្រុមហ៊ុន សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់។ នៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះ ក្រុមប្រឹក្សាភិបាលចាំបាច់ត្រូវ៖

- អនុម័តនូវគោលនយោបាយគណនេយ្យ ដែលសមស្របដោយផ្អែកលើការវិនិច្ឆ័យនិងការប៉ាន់ប្រមាណយ៉ាងសមហេតុផលនិងប្រុងប្រយ័ត្នហើយធ្វើការអនុវត្តប្រកបដោយសង្គតិភាព
- អនុលោមទៅតាមស្តង់ដារបាយការណ៍ ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូច និងមធ្យម ឬប្រសិនបើមានការផ្លាស់ប្តូរពីនេះ គឺត្រូវតែបង្ហាញពន្យល់ និងកំណត់បរិមាណឲ្យបានច្បាស់លាស់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ដើម្បីបង្ហាញនូវភាពពិត និងត្រឹមត្រូវ
- ត្រួតពិនិត្យប្រព័ន្ធដំណើរការនៃរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន និងរក្សាទុកនូវបញ្ជីគណនេយ្យឲ្យបានគ្រប់គ្រាន់ និងប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងឱ្យមានប្រសិទ្ធភាព
- វាយតម្លៃនូវលទ្ធភាពរបស់ក្រុមហ៊ុនក្នុងការបន្តនិរន្តរភាពអាជីវកម្ម ទទួលខុសត្រូវលើការលាតត្រដាងព័ត៌មានប្រសិនបើពាក់ព័ន្ធនូវបញ្ហាទាំងឡាយដែលទាក់ទងទៅនឹងនិរន្តរភាពអាជីវកម្ម និងប្រើប្រាស់មូលដ្ឋាននិរន្តរភាពនៃគណនេយ្យ លើកលែងតែអ្នកគ្រប់គ្រងមានបំណងចង់ជម្រះបញ្ជី ផ្អាកដំណើរការក្រុមហ៊ុន ឬគ្មានជម្រើសសមរម្យដទៃទៀតក្រៅពីធ្វើបែបនេះ និង
- ត្រួតពិនិត្យ និងដឹកនាំក្រុមហ៊ុនឲ្យមានប្រសិទ្ធភាពលើរាល់សេចក្តីសម្រេចដែលមានសារៈសំខាន់ទាំងអស់ដែលប៉ះពាល់ដល់សកម្មភាពប្រតិបត្តិការ និងដំណើរការរបស់ក្រុមហ៊ុន ហើយត្រូវប្រាកដថា កិច្ចការនេះត្រូវបានឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

ក្រុមប្រឹក្សាភិបាលធានាអះអាងថា ក្រុមប្រឹក្សាភិបាលបានអនុវត្តនូវរាល់តម្រូវការ ដូចមានរាយការណ៍ខាងលើ ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ។

## ការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុ

យើងខ្ញុំ សូមធ្វើការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុ រួមទាំងកំណត់សម្គាល់ដែលបានភ្ជាប់មកជាមួយដូចដែលបានបង្ហាញនៅទំព័រទី១០ ដល់ទី៦៤ ថាបានបង្ហាញនូវភាពត្រឹមត្រូវលើរាល់ទិដ្ឋភាពជាសារវន្ត នៃស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរទឹកប្រាក់របស់ក្រុមហ៊ុន សម្រាប់ការិយបរិច្ឆេទ ដែលបានបញ្ចប់ ដោយអនុលោមទៅតាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូចនិងមធ្យម។

*ចុះហត្ថលេខាក្នុងនាមក្រុមប្រឹក្សាភិបាលដោយយោងលើការអនុម័តរបស់ក្រុមប្រឹក្សាភិបាល៖*

**លោកស្រី ឌិត នីតា**
*ប្រធានក្រុមប្រឹក្សាភិបាល*

**លោក លី ឈាង**
*អគ្គនាយកប្រតិបត្តិស្តីទី*

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២៤

# របាយការណ៍របស់សវនករឯករាជ្យ

ជូនចំពោះភាគទុនិករបស់ ខេមា មីក្រូហិរញ្ញវត្ថុ លីមីតធីត

## មតិសវនកម្ម

យើងខ្ញុំ បានធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុរបស់ ខេមា មីក្រូហិរញ្ញវត្ថុ លីមីតធីត ហៅកាត់ថា (ក្រុមហ៊ុន) ដែលរួមមានរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ របាយការណ៍លទ្ធផលលម្អិតរបាយការណ៍ស្តីពី បម្រែបម្រួលមូលធន និងរបាយការណ៍លំហូរទឹកប្រាក់សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់និងកំណត់សម្គាល់ដែលរួមមានគោលនយោបាយគណនេយ្យសារវន្តព្រមទាំងព័ត៌មានពន្យល់ផ្សេងៗទៀតដូចបានបង្ហាញនៅទំព័រទី១០ដល់ទី៦៤ (ដែលហៅកាត់ថា "របាយការណ៍ហិរញ្ញវត្ថុ")។

ជាមតិរបស់យើងខ្ញុំ របាយការណ៍ហិរញ្ញវត្ថុដែលបានភ្ជាប់មកជាមួយ បានបង្ហាញនូវភាពត្រឹមត្រូវលើរាល់ទិដ្ឋភាពជាសារវន្ត នៃស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរទឹកប្រាក់របស់ក្រុមហ៊ុនសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ដោយអនុលោមទៅតាមស្តង់ដារបាយការណ៍ ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូច និងមធ្យម។

## មូលដ្ឋាននៃមតិសវនកម្ម

យើងខ្ញុំ បានធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដាសវនកម្មអន្តរជាតិនៃកម្ពុជា។ ការទទួលខុសត្រូវរបស់យើងខ្ញុំដែលស្របតាមស្តង់ដាទាំងនោះត្រូវបានពណ៌នាបន្ថែមទៀតនៅក្នុងកថាខណ្ឌស្តីពី ការទទួលខុសត្រូវរបស់សវនករចំពោះការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ ដែលមាននៅក្នុងរបាយការណ៍របស់យើងខ្ញុំ។ យើងខ្ញុំ មានភាពឯករាជ្យពីក្រុមហ៊ុន ដោយស្របទៅតាមលក្ខខណ្ឌតម្រូវនៃក្រមសីលធម៌វិជ្ជាជីវៈនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលពាក់ព័ន្ធនឹងសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ ហើយយើងខ្ញុំបានបំពេញនូវទំនួលខុសត្រូវក្រមសីលធម៌វិជ្ជាជីវៈផ្សេងៗទៀតស្របតាមលក្ខខណ្ឌតម្រូវទាំងនេះ។ យើងខ្ញុំជឿជាក់ថាភស្តុតាងសវនកម្មដែលយើងខ្ញុំប្រមូលបាន មានលក្ខណៈគ្រប់គ្រាន់ និងសមស្របសម្រាប់ជាមូលដ្ឋានក្នុងការបញ្ចេញមតិសវនកម្មរបស់យើងខ្ញុំ។

## ព័ត៌មានផ្សេងៗ

អ្នកគ្រប់គ្រង មានភារៈទទួលខុសត្រូវលើព័ត៌មានផ្សេងៗ។ ព័ត៌មានផ្សេងៗ រួមមានរបាយការណ៍របស់ក្រុមប្រឹក្សាភិបាលដូចបានបង្ហាញនៅទំព័រទី១ដល់ទី៥និងរបាយការណ៍ប្រចាំឆ្នាំរបស់ក្រុមហ៊ុន ដែលរំពឹងថានឹងរួចរាល់បន្ទាប់ ពីកាលបរិច្ឆេទនៃរបាយការណ៍សវនកម្មនេះ។ មតិសវនកម្មរបស់យើងខ្ញុំ ទៅលើរបាយការណ៍ហិរញ្ញវត្ថុមិនបានគ្របដណ្តប់លើព័ត៌មានផ្សេងៗឡើយ ហើយយើងខ្ញុំមិនធ្វើការផ្តល់នូវអំណះអំណាងណាមួយ ទៅលើព័ត៌មានផ្សេងៗនេះទេ។

ពាក់ព័ន្ធនឹងការធ្វើសវនកម្មរបស់យើងខ្ញុំលើរបាយការណ៍ហិរញ្ញវត្ថុ ការទទួលខុសត្រូវរបស់យើងខ្ញុំ គឺត្រូវអានព័ត៌មានផ្សេងៗហើយពិចារណាថាតើព័ត៌មានផ្សេងៗនោះមានភាពមិនស្របគ្នាជាសារវន្តជាមួយរបាយការណ៍ហិរញ្ញវត្ថុ ឬការយល់ដឹងរបស់យើងខ្ញុំនៅក្នុងការធ្វើសវនកម្ម ឬមានបង្ហាញនូវកំហុសឆ្គងជាសារវន្ត។

ប្រសិនបើការអានព័ត៌មានផ្សេងៗដែលបានទទួលមុនកាលបរិច្ឆេទនៃរបាយការណ៍សវនកម្មនេះ អាចឲ្យយើងខ្ញុំសន្និដ្ឋានថា មានកំហុសឆ្គងជាសារវន្តកើតឡើងលើព័ត៌មានផ្សេងៗនេះយើងខ្ញុំត្រូវរាយការណ៍ទៅតាមស្ថានភាពជាក់ស្តែង។ យើងខ្ញុំពុំមានអ្វីដែលត្រូវរាយការណ៍ពាក់ព័ន្ធនឹងព័ត៌មានផ្សេងៗនេះទេ។

## ការទទួលខុសត្រូវរបស់អ្នកគ្រប់គ្រង និងអ្នកទទួលខុសត្រូវលើអភិបាលកិច្ចលើរបាយការណ៍ហិរញ្ញវត្ថុ

អ្នកគ្រប់គ្រងមានភារៈទទួលខុសត្រូវ លើការរៀបចំនិងការបង្ហាញនូវភាពត្រឹមត្រូវ នៃរបាយការណ៍ហិរញ្ញវត្ថុដោយអនុលោមទៅតាមស្តង់ដារបាយការណ៍ ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូច និងមធ្យម ហើយទទួលខុសត្រូវលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងដែលអ្នកគ្រប់គ្រងកំណត់ថាមានភាពចាំបាច់សម្រាប់ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ឱ្យជៀសផុតពីការបង្ហាញខុសជាសារវន្តដោយសារតែការក្លែងបន្លំ ឬកំហុសឆ្គង។

នៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុអ្នកគ្រប់គ្រង

មានភារៈទទួលខុសត្រូវ លើការវាយតម្លៃនូវលទ្ធភាពរបស់ក្រុមហ៊ុនក្នុងការបន្តនិរន្តរភាពអាជីវកម្មទទួលខុសត្រូវលើការលាតត្រដាងព័ត៌មានប្រសិនបើពាក់ព័ន្ធនូវបញ្ហាទាំងឡាយដែលទាក់ទិនទៅនឹងនិរន្តរភាពអាជីវកម្ម និងប្រើប្រាស់មូលដ្ឋាននិរន្តរភាពនៃគណនេយ្យ លើកលែងតែអ្នកគ្រប់គ្រងមានបំណងចង់ជម្រះបញ្ជីផ្អាកដំណើរការក្រុមហ៊ុនឬគ្មានជម្រើសសមរម្យដទៃទៀត ក្រៅពីធ្វើបែបនេះ។

អ្នកទទួលខុសត្រូវលើអភិបាលកិច្ច មានភារៈទទួលខុសត្រូវក្នុងការត្រួតពិនិត្យដំណើរការ នៃការវាយការណ៍ព័ត៌មានហិរញ្ញវត្ថុរបស់ក្រុមហ៊ុន។

គោលដៅរបស់យើងខ្ញុំគឺទទួលបាននូវអំណះអំណាងសមហេតុផលថារបាយការណ៍ហិរញ្ញវត្ថុទាំងមូល មិនមានការបង្ហាញខុសជាសារវន្តដោយសារតែការក្លែងបន្លំ ឬកំហុសឆ្គង និងផ្តល់នូវរបាយការណ៍របស់សវនករ ដែលរួមបញ្ចូលទាំងមតិសវនកម្មរបស់យើងខ្ញុំ។ អំណះអំណាងសមហេតុផលគឺជាអំណះអំណាងមួយដែលមានកម្រិតខ្ពស់ ប៉ុន្តែវាមិនអាចធានាថាគ្រប់ពេលនៃការធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដាសវនកម្មអន្តរជាតិនៃកម្ពុជាអាចរកឃើញនូវការបង្ហាញខុសជាសារវន្តដែលបានកើតឡើងនោះទេ។ ការបង្ហាញខុសអាចកើតឡើងដោយសារការក្លែងបន្លំឬកំហុសឆ្គងហើយត្រូវបានចាត់ទុកថាមានលក្ខណៈសារវន្ត នៅពេលដែលការក្លែងបន្លំឬកំហុសឆ្គងដោយឡែកឬក៏រួមបញ្ចូលគ្នាអាចត្រូវបានរំពឹងទុកយ៉ាងសមហេតុផលថានឹងជះឥទ្ធិពលដល់ការសម្រេចចិត្តផ្នែកសេដ្ឋកិច្ចរបស់អ្នកប្រើប្រាស់ដោយយោងលើរបាយការណ៍ហិរញ្ញវត្ថុនេះ។

ជាផ្នែកមួយនៃការធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដាសវនកម្មអន្តរជាតិនៃកម្ពុជាយើងខ្ញុំអនុវត្តនូវការវិនិច្ឆ័យដែលប្រកបទៅដោយវិជ្ជាជីវៈ និងរក្សានូវមជ្ឈធាតុនិយមក្នុងអំឡុងពេលធ្វើសវនកម្ម។ យើងខ្ញុំក៏ៈ

- ធ្វើការកំណត់និងវាយតម្លៃនូវហានិភ័យនៃការបង្ហាញខុសជាសារវន្តនៃរបាយការណ៍ហិរញ្ញវត្ថុ ដោយសារតែការក្លែងបន្លំ ឬកំហុសឆ្គង និងទទួលខុសត្រូវលើការតាក់តែងនិងអនុវត្តនូវនីតិវិធីសវនកម្ម ដើម្បីឆ្លើយតបទៅនឹងហានិភ័យទាំងនោះ និងប្រមូលនូវភស្តុតាងដែលមានលក្ខណៈគ្រប់គ្រាន់និងសមស្របសម្រាប់ជាមូលដ្ឋានក្នុងការបញ្ចេញមតិសវនកម្មរបស់យើងខ្ញុំ។ ហានិភ័យនៃការរកមិនឃើញនូវការបង្ហាញខុសជាសារវន្តដែលបណ្តាលមកពីការក្លែងបន្លំមានលក្ខណៈខ្ពស់ជាងការបង្ហាញខុសដែលបណ្តាលមកពីកំហុសឆ្គង ដោយសារតែការក្លែងបន្លំអាចទាក់ទិននឹងការឃុបឃិតគ្នា ការលួចបន្លំ ការលុបចោលដោយចេតនា ការបកស្រាយមិនពិត ឬមិនអនុវត្តតាមនីតិវិធី នៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង។
- ធ្វើការស្វែងយល់អំពីប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដែលពាក់ព័ន្ធនឹងការធ្វើសវនកម្ម ក្នុងគោលបំណងដើម្បីតាក់តែងនូវនីតិវិធីសវនកម្មដែលសមស្របទៅតាមកាលៈទេសៈប៉ុន្តែមិនមែនក្នុងគោលបំណងដើម្បីបញ្ចេញមតិលើប្រសិទ្ធភាពនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់ក្រុមហ៊ុនឡើយ។
- ធ្វើការវាយតម្លៃលើភាពសមស្របនៃគោលនយោបាយគណនេយ្យដែលក្រុមហ៊ុនបានអនុវត្តនិងភាពសមហេតុផលនៃការប៉ាន់ស្មានគណនេយ្យព្រមទាំងការលាតត្រដាងព័ត៌មានពាក់ព័ន្ធនានាដែលបានធ្វើឡើងដោយអ្នកគ្រប់គ្រង។
- ធ្វើការសន្និដ្ឋានលើ ភាពសមស្របនៃការប្រើប្រាស់មូលដ្ឋាននិរន្តរភាពនៃគណនេយ្យរបស់អ្នកគ្រប់គ្រង ហើយដោយផ្អែកទៅលើភស្តុតាងសវនកម្មដែលទទួលបានធ្វើការសន្និដ្ឋានថាតើភាពមិនប្រាកដប្រជាជាសារវន្តបានកើតមានឡើងពាក់ព័ន្ធទៅនឹងព្រឹត្តិការណ៍ ឬលក្ខខណ្ឌដែលអាចបង្កឲ្យមានមន្ទិលជាសារវន្តលើលទ្ធភាពរបស់ក្រុមហ៊ុន ដើម្បីបន្តនិរន្តរភាពអាជីវកម្មដែរ ឬទេ។ ប្រសិនបើយើងខ្ញុំ ធ្វើការសន្និដ្ឋានថា មានអត្ថិភាពនៃភាពមិនប្រាកដប្រជាជាសារវន្ត យើងខ្ញុំចាំបាច់ត្រូវទាញចំណាប់អារម្មណ៍ នៅក្នុងរបាយការណ៍សវនកម្មរបស់យើងខ្ញុំ លើការលាតត្រដាងព័ត៌មានពាក់ព័ន្ធនៅក្នុង របាយការណ៍ហិរញ្ញវត្ថុ ឬប្រសិនបើការលាតត្រដាងព័ត៌មានមានលក្ខណៈមិនគ្រប់គ្រាន់ យើងខ្ញុំចាំបាច់ត្រូវផ្តល់មតិសវនកម្មដែលមានបញ្ហា។ ការសន្និដ្ឋានរបស់យើងខ្ញុំ គឺផ្អែកតាមភស្តុតាងសវនកម្មដែលប្រមូលបានត្រឹមកាលបរិច្ឆេទនៃរបាយការណ៍សវនកម្មរបស់យើងខ្ញុំ។ ទោះជាយ៉ាងណាក៏ដោយព្រឹត្តិការណ៍ឬលក្ខខណ្ឌនាពេលអនាគតអាចធ្វើឱ្យក្រុមហ៊ុនបញ្ឈប់និរន្តរភាពនៃអាជីវកម្ម។
- ធ្វើការវាយតម្លៃលើការបង្ហាញទម្រង់ និងខ្លឹមសារនៃ

របាយការណ៍ហិរញ្ញវត្ថុទាំងមូលដោយរួមបញ្ចូលទាំងការលាតត្រដាងព័ត៌មាន និងវាយតម្លៃថាតើរបាយការណ៍ហិរញ្ញវត្ថុបានបង្ហាញពីប្រតិបត្តិការ និងព្រឹត្តិការណ៍ពាក់ព័ន្ធក្នុងអត្ថន័យដែលអាចសម្រេចបាននូវការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុដ៏ត្រឹមត្រូវ។

យើងខ្ញុំ ផ្តល់ព័ត៌មាន ក្នុងចំណោមបញ្ហាផ្សេងៗ ជូនអ្នកទទួលខុសត្រូវលើអភិបាលកិច្ចស្តីពីវិសាលភាព និងពេលវេលាដែលបានគ្រោងទុកសម្រាប់ការធ្វើសវនកម្ម និងការរកឃើញបញ្ហាជាសារវន្តដោយរួមបញ្ចូលទាំងចំណុចខ្វះខាតជាសារវន្តក្នុងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងដែលយើងខ្ញុំបានរកឃើញក្នុងអំឡុងពេលធ្វើសវនកម្ម។

តំណាងក្រុមហ៊ុន **ខេភីអឹមជី ខេមបូឌា**




***ហ្គោក ឆាវ***

*Partner*

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២៤

# របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ

នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣

| | ២០២៣ | | ២០២២ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| **ទ្រព្យសកម្ម** | | | | |
| សាច់ប្រាក់ក្នុងដៃ | ១៩១.០៣៥ | ៧៨០.៣៧៨ | ១៥៤.៤១២ | ៦៣៥.៧១៤ |
| សមតុល្យនៅធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុនានា | ៤១.៦៨៧ | ១៧០.២៩១ | ៧៤១.៧៥៦ | ៣.០៥៣.៨០៩ |
| សមតុល្យនៅធនាគារជាតិនៃកម្ពុជា | ៣៧១.១៦៤ | ១.៥១៦.២០៥ | ២៨២.០៣២ | ១.១៦១.១២៦ |
| ឥណទានផ្តល់ដល់អតិថិជន | ២៦.៦៩៩.៧៧២ | ១០៩.០៦៨.៥៧០ | ២៣.៣២៧.៣២៩ | ៩៦.០៣៨.៦១៣ |
| ទ្រព្យសកម្មផ្សេងៗ | ១០៥.២៤១ | ៤២៩.៩០៩ | ១៥៧.២៣២ | ៦៤៧.៣២៥ |
| ទ្រព្យ និងបរិក្ខារ | ១៩៣.០៨០ | ៧៨៨.៧៣២ | ១៤៩.២៩៣ | ៦១៤.៦៤០ |
| ទ្រព្យសកម្មអរូបី | ៧៦.៧៩៣ | ៣១៣.៦៩៩ | ៣៦.២៧៩ | ១៤៩.៣៦០ |
| **ទ្រព្យសកម្មសរុប** | **២៧.៦៧៨.៧៧២** | **១១៣.០៦៧.៧៨៤** | **២៤.៨៤៨.៣៣៣** | **១០២.៣០០.៥៨៧** |
| | | | | |
| **បំណុល និងមូលធន** | | | | |
| **បំណុល** | | | | |
| បំណុលពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ | ១២.៥៩៩ | ៥១.៤៦៧ | ៧៥.៧៧៣ | ៣១១.៩៥៧ |
| ប្រាក់កម្ចី | ១៨.២១៣.៩៩៧ | ៧៤.៤០៤.១៧៨ | ១៥.៣៤១.០៧៧ | ៦៣.១៥៩.២១៤ |
| អនុបំណុល | ៩០០.៩៨៦ | ៣.៦៨០.៥២៨ | ២.២០២.០៤៣ | ៩.០៦៥.៨១១ |
| បំណុលផ្សេងៗ | ១៧៣.៩៦៨ | ៧១០.៦៥៩ | ១៥៥.០៦៦ | ៦៣៨.៤០៧ |
| បំណុលពន្ធពន្យារ | ៣០.៦៤៧ | ១២៥.១៩៣ | ១.១៩៣ | ៤.៩១២ |
| **បំណុលសរុប** | **១៩.៣៣២.១៩៧** | **៧៨.៩៧២.០២៥** | **១៧.៧៧៥.១៥២** | **៧៣.១៨០.៣០១** |
| **មូលធន** | | | | |
| ដើមទុន | ៧.៣៤៣.០០០ | ២៩.៣៧២.០០០ | ៥.៥៩៣.០០០ | ២២.៣៧២.០០០ |
| ទុនបម្រុងតាមបទប្បញ្ញត្តិ | ៧៤៣.១៩៥ | ៣.០២៣.៩៨៦ | ៥៣៩.៧៤៩ | ២.១៩២.៩០៩ |
| ប្រាក់ចំណេញរក្សាទុក | ២៦០.៣៨០ | ១.១៣២.៩៧២ | ៩៤០.៤៣២ | ៣.៨៤០.៤០០ |
| ទុនបម្រុងពីការប្តូររូបិយប័ណ្ណ | - | ៥៦៦.៨០១ | - | ៧១៤.៩៧៧ |
| **មូលធនសរុប** | **៨.៣៤៦.៥៧៥** | **៣៤.០៩៥.៧៥៩** | **៧.០៧៣.១៨១** | **២៩.១២០.២៨៦** |
| **បំណុល និងមូលធនសរុប** | **២៧.៦៧៨.៧៧២** | **១១៣.០៦៧.៧៨៤** | **២៤.៨៤៨.៣៣៣** | **១០២.៣០០.៥៨៧** |

# របាយការណ៍លទ្ធផលលម្អិត

## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣

| | ២០២៣ | | ២០២២ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ចំណូលពីការប្រាក់ | ៣.៧៣៣.៣៣១ | ១៥.៣៤៣.៩៩១ | ២.៧៩០.៤៩១ | ១១.៤០៤.៧៣៧ |
| ចំណាយលើការប្រាក់ | (១.២២៣.២៥០) | (៥.០២៧.៥៥៨) | (៨០០.៦២៦) | (៣.២៧២.១៥៨) |
| **ការប្រាក់សុទ្ធ** | **២.៥១០.០៨១** | **១០.៣១៦.៤៣៣** | **១.៩៨៩.៨៦៥** | **៨.១៣២.៥៧៩** |
| ចំណូលប្រតិបត្តិការផ្សេងៗ | ១២៧.៥០២ | ៥២៤.០៣៣ | ១០២.០៣២ | ៤១៧.០០៤ |
| **ចំណូលប្រតិបត្តិការសុទ្ធ** | **២.៦៣៧.៥៨៣** | **១០.៨៤០.៤៦៦** | **២.០៩១.៨៩៧** | **៨.៥៤៩.៥៨៣** |
| ការខាតបង់លើឱនភាពនៃតម្លៃសុទ្ធ លើទ្រព្យសកម្មហិរញ្ញវត្ថុ | (៣០.៨៤២) | (១២៦.៧៦១) | (២៥.៣០៤) | (១០៣.៤១៧) |
| ចំណាយបុគ្គលិក | (១.៥៦៦.៩៩៧) | (៦.៤៤០.៣៥៨) | (១.២២៩.២៩៧) | (៥.០២៤.១៣៧) |
| ចំណាយរំលស់ | (៧២.៩៥៨) | (២៩៩.៨៥៧) | (៤៣.៧០២) | (១៧៨.៦១០) |
| ចំណាយប្រតិបត្តិការផ្សេងៗ | (៦១៦.៤២០) | (២.៥៣៣.៤៨៦) | (៥៨៧.៦៥១) | (២.៤០១.៧៣០) |
| **ប្រាក់ចំណេញមុនដកពន្ធ** | **៣៥០.៣៦៦** | **១.៤៤០.០០៤** | **២០៥.៩៤៣** | **៨៤១.៦៨៩** |
| ចំណាយពន្ធលើប្រាក់ចំណេញ | (៧៦.៩៧២) | (៣១៦.៣៥៥) | (៦១.៥៥៣) | (២៥១.៥៦៧) |
| **ប្រាក់ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ** | **២៧៣.៣៩៤** | **១.១២៣.៦៤៩** | **១៤៤.៣៩០** | **៥៩០.១២២** |
| ***លទ្ធផលលម្អិតផ្សេងៗ៖*** | | | | |
| *ធាតុដែលមិនត្រូវបានធ្វើចំណាត់ថ្នាក់ ឡើងវិញក្នុងចំណេញ ឬខាត* | | | | |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | (២៣៣.១៧៦) | - | ៣០២.២៦៩ |
| **លទ្ធផលលម្អិតសរុបសម្រាប់ការិយបរិច្ឆេទ** | **២៧៣.៣៩៤** | **៨៩០.៤៧៣** | **១៤៤.៣៩០** | **៨៩២.៣៩១** |

# របាយការណ៍ស្តីពីបម្រែបម្រួលមូលធន

សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣

| | ដើមទុន | | ទុនបម្រុងតាមបទប្បញ្ញត្តិ | | ប្រាក់ចំណេញរក្សាទុក | | ទុនបម្រុងពីការប្តូររូបិយប័ណ្ណ | | សរុប | |
|---|---|---|---|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ថ្ងៃទី១ ខែមករា ឆ្នាំ២០២៣ | ៥.៥៩៣.០០០ | ២២.៣៧២.០០០ | ៥៣៩.៧៤៩ | ២.១៩២.៩០៩ | ៩៤០.៤៣២ | ៣.៨៤០.៤០០ | - | ៧១៤.៩៧៧ | ៧.០៧៣.១៨១ | ២៩.១២០.២៨៦ |
| **ប្រតិបត្តិការទទួលស្គាល់ដោយផ្ទាល់ នៅក្នុងមូលធន៖** | | | | | | | | | | |
| ផ្ទេរពីប្រាក់ចំណេញរក្សាទុក ទៅទុនបម្រុងតាមបទប្បញ្ញត្តិ | - | - | ២០៣.៤៤៦ | ៨៣១.០៧៧ | (២០៣.៤៤៦) | (៨៣១.០៧៧) | - | - | - | - |
| **ប្រតិបត្តិការជាមួយភាគទុនិក៖** | | | | | | | | | | |
| ការតម្លើងដើមទុនតាមរយៈ៖ | | | | | | | | | | |
| ការផ្ទេរពីអនុបំណុលទៅដើមទុន | ១.០០០.០០០ | ៤.០០០.០០០ | - | - | - | - | - | ៨៥.០០០ | ១.០០០.០០០ | ៤.០៨៥.០០០ |
| ផ្ទេរពីប្រាក់ចំណេញរក្សាទុកទៅដើមទុន | ៧៥០.០០០ | ៣.០០០.០០០ | - | - | (៧៥០.០០០) | (៣.០០០.០០០) | - | - | - | - |
| | ១.៧៥០.០០០ | ៧.០០០.០០០ | ២០៣.៤៤៦ | ៨៣១.០៧៧ | (៩៥៣.៤៤៦) | (៣.៨៣១.០៧៧) | - | ៨៥.០០០ | ១.០០០.០០០ | ៤.០៨៥.០០០ |
| **លទ្ធផលលម្អិតសរុប៖** | | | | | | | | | | |
| ប្រាក់ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ | - | - | - | - | ២៧៣.៣៩៤ | ១.១២៣.៦៤៩ | - | - | ២៧៣.៣៩៤ | ១.១២៣.៦៤៩ |
| លទ្ធផលលម្អិតផ្សេងៗ - លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | - | - | - | (២៣៣.១៧៦) | - | (២៣៣.១៧៦) |
| | - | - | - | - | ២៧៣.៣៩៤ | ១.១២៣.៦៤៩ | - | (២៣៣.១៧៦) | ២៧៣.៣៩៤ | ៨៩០.៤៧៣ |
| ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ | ៧.៣៤៣.០០០ | ២៩.៣៧២.០០០ | ៧៤៣.១៩៥ | ៣.០២៣.៩៨៦ | ២៦០.៣៨០ | ១.១៣២.៩៧២ | - | ៥៦៦.៨០១ | ៨.៣៤៦.៥៧៥ | ៣៤.០៩៥.៧៥៩ |
| | | | | | | | | | | |
| ថ្ងៃទី១ ខែមករា ឆ្នាំ២០២២ | ៥.៥៩៣.០០០ | ២២.៣៧២.០០០ | ៥៨១.០៤៣ | ២.៣៦២.៩១៦ | ៧៥៤.៧៤៨ | ៣.០៨០.២៧១ | - | ៤១២.៧០៨ | ៦.៩២៨.៧៩១ | ២៨.២២៧.៨៩៥ |
| **ប្រតិបត្តិការជាមួយភាគទុនិក៖** | | | | | | | | | | |
| ផ្ទេរពីប្រាក់ចំណេញរក្សាទុកទៅទុនបម្រុងតាមបទប្បញ្ញត្តិ | - | - | (៤១.២៩៤) | (១៧០.០០៧) | ៤១.២៩៤ | ១៧០.០០៧ | - | - | - | - |
| | - | - | (៤១.២៩៤) | (១៧០.០០៧) | ៤១.២៩៤ | ១៧០.០០៧ | - | - | - | - |
| **លទ្ធផលលម្អិតសរុប៖** | | | | | | | | | | |
| ប្រាក់ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ | - | - | - | - | ១៤៤.៣៩០ | ៥៩០.១២២ | - | - | ១៤៤.៣៩០ | ៥៩០.១២២ |
| លទ្ធផលលម្អិតផ្សេងៗ - លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | - | - | - | ៣០២.២៦៩ | - | ៣០២.២៦៩ |
| | - | - | - | - | ១៤៤.៣៩០ | ៥៩០.១២២ | - | ៣០២.២៦៩ | ១៤៤.៣៩០ | ៨៩២.៣៩១ |
| ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ | ៥.៥៩៣.០០០ | ២២.៣៧២.០០០ | ៥៣៩.៧៤៩ | ២.១៩២.៩០៩ | ៩៤០.៤៣២ | ៣.៨៤០.៤០០ | - | ៧១៤.៩៧៧ | ៧.០៧៣.១៨១ | ២៩.១២០.២៨៦ |

# របាយការណ៍លំហូរទឹកប្រាក់

## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣

| | ២០២៣ | | ២០២២ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| **លំហូរទឹកប្រាក់ពីសកម្មភាពប្រតិបត្តិការ** | | | | |
| ប្រាក់ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ | ២៧៣.៣៩៤ | ១.១២៣.៦៤៩ | ១៤៤.៣៩០ | ៥៩០.១២២ |
| *និយ័តភាពលើ៖* | | | | |
| ការខាតបង់លើឱនភាពនៃតម្លៃសុទ្ធលើទ្រព្យសកម្មហិរញ្ញវត្ថុ | ៣០.៨៤២ | ១២៦.៧៦១ | ២៥.៣០៤ | ១០៣.៤១៧ |
| រំលស់ | ៧២.៩៥៨ | ២៩៩.៨៥៧ | ៤៣.៧០២ | ១៧៨.៦១០ |
| ចំណូលពីការប្រាក់ | (៣.៧៣៣.៣៣១) | (១៥.៣៤៣.៩៩១) | (២.៧៩០.៤៩១) | (១១.៤០៤.៧៣៧) |
| ចំណាយពីការប្រាក់ | ១.២២៣.២៥០ | ៥.០២៧.៥៥៨ | ៨០០.៦២៦ | ៣.២៧២.១៥៨ |
| ចំណាយពន្ធលើប្រាក់ចំណេញ | ៧៦.៩៧២ | ៣១៦.៣៥៥ | ៦១.៥៥៣ | ២៥១.៥៦៧ |
| | (២.០៥៥.៩១៥) | (៨.៤៤៩.៨១១) | (១.៧១៤.៩១៦) | (៧.០០៨.៨៦៣) |
| *បម្រែបម្រួលនូវ៖* | | | | |
| ឥណទានផ្តល់ដល់អតិថិជន | (៣.២៨៦.១១០) | (១៣.៥០៥.៩១២) | (៨.០៥៩.១៩៨) | (៣២.៩៣៧.៩៤២) |
| ទ្រព្យសកម្មផ្សេងៗ | ៥១.៩៩១ | ២១៣.៦៨៣ | (៦១.២១៩) | (២៥០.២០២) |
| ប្រាក់តម្កល់តាមច្បាប់ | (៨៧.៥០០) | (៣៥៩.៦២៥) | - | - |
| បំណុលផ្សេងៗ | ៣១.១៤២ | ១២៧.៩៩៤ | ៨៤.៤៣៤ | ៣៤៥.០៨២ |
| សាច់ប្រាក់ប្រើប្រាស់ក្នុងប្រតិបត្តិការ | (៥.៣៤៦.៣៩២) | (២១.៩៧៣.៦៧១) | (៩.៧៥០.៨៩៩) | (៣៩.៨៥១.៩២៥) |
| ចំណូលពីការប្រាក់បានទទួល | ៣.៦១៥.៥០៣ | ១៤.៨៥៩.៧១៨ | ២.៧០០.១០៤ | ១១.០៣៥.៣២៥ |
| ចំណាយលើការប្រាក់បានបង់ | (១.១៨៤.៦៣៥) | (៤.៨៦៨.៨៥០) | (៧៩១.៤៥៣) | (៣.២៣៤.៦៦៨) |
| ពន្ធលើប្រាក់ចំណេញបានបង់ | (១១០.៦៩២) | (៤៥៤.៩៤៤) | (៣៤.២៨៥) | (១៤០.១២៣) |
| **សាច់ប្រាក់សុទ្ធប្រើប្រាស់ក្នុងសកម្មភាពប្រតិបត្តិការ** | **(៣.០២៦.២១៦)** | **(១២.៤៣៧.៧៤៧)** | **(៧.៨៧៦.៥៣៣)** | **(៣២.១៩១.៣៩១)** |
| **លំហូរទឹកប្រាក់ពីសកម្មភាពវិនិយោគ** | | | | |
| ការទិញទ្រព្យ និងបរិក្ខារ | (១១១.១៦២) | (៤៥៦.៨៧៦) | (១១៣.៩៤៥) | (៤៦៥.៦៩៣) |
| ការទិញទ្រព្យសកម្មអរូបិយ | (៤៦.០៩៧) | (១៨៩.៤៥៩) | (៣៩.៤៨៤) | (១៦១.៣៧១) |
| សាច់ប្រាក់សុទ្ធប្រើប្រាស់ក្នុងសកម្មភាពវិនិយោគ | (១៥៧.២៥៩) | (៦៤៦.៣៣៥) | (១៥៣.៤២៩) | (៦២៧.០៦៤) |
| **លំហូរទឹកប្រាក់ពីសកម្មភាពហិរញ្ញប្បទាន** | | | | |
| សាច់ប្រាក់ទទួលបានពីប្រាក់កម្ចី | ១៩.៣១១.៣៨៥ | ៧៩.៣៦៩.៧៩២ | ១៦.៤៧៧.៥៤៨ | ៦៧.៣៤៣.៧៣៩ |
| ការទូទាត់សងប្រាក់កម្ចី | (១៦.៤៨៩.៧៣៥) | (៦៧.៧៧២.៨១១) | (១០.៦២០.៨២៨) | (៤៣.៤០៧.៣២៤) |
| សាច់ប្រាក់ទទួលបានពីអនុបំណុល | - | - | ២.៧៥០.០២៣ | ១១.២៣៩.៣៤៤ |
| ការទូទាត់សងអនុបំណុល | (២៩៩.៩៨៩) | (១.២៣២.៩៥៥) | (៥៥០.០០០) | (២.២៤៧.៨៥០) |
| **សាច់ប្រាក់សុទ្ធទទួលបានពីសកម្មភាពហិរញ្ញប្បទាន** | **២.៥២១.៦៦១** | **១០.៣៦៤.០២៦** | **៨.០៥៦.៧៤៣** | **៣២.៩២៧.៩០៩** |
| **ការ(ថយចុះ)/កើនឡើងសុទ្ធនៃសាច់ប្រាក់** | | | | |
| **និងសាច់ប្រាក់សមមូល** | **(៦៦១.៨១៤)** | **(២.៧២០.០៥៦)** | **២៦.៧៨១** | **១០៩.៤៥៣** |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលនាថ្ងៃទី១ ខែមករា** | **៨៩៨.៥៥០** | **៣.៦៩៩.៣៣០** | **៨៧១.៧៦៩** | **៣.៥៥១.៥៨៧** |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | (១២.២០៨) | - | ៣៨.២៩០ |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលនាថ្ងៃទី៣១ ខែធ្នូ** | **២៣៦.៧៣៦** | **៩៦៧.០៦៦** | **៨៩៨.៥៥០** | **៣.៦៩៩.៣៣០** |
| **ប្រតិបត្តិការមិនមែនសាច់ប្រាក់សំខាន់ៗ៖** | | | | |
| ប្រតិបត្តិការមិនមែនសាច់ប្រាក់សំខាន់ៗមានដូចខាងក្រោម៖ | | | | |
| ការផ្ទេរពីអនុបំណុលទៅដើមទុន | ១.០០០.០០០ | ៤.០០០.០០០ | - | - |
| ការផ្ទេរពីប្រាក់ចំណេញរក្សាទុកទៅដើមទុន | ៧៥០.០០០ | ៣.០០០.០០០ | - | - |




# បណ្តាញសាខា

**ការិយាល័យកណ្តាល**

ផ្ទះលេខ ១០១អា ផ្លូវ២៨៩ សង្កាត់បឹងកក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ៖ ០១៧ ៩០៧ ៥៥៥ | ០៩៨ ៩០៧ ៥៥៥
អ៊ីម៉ែល ៖ info@camma.com.kh
គេហទំព័រ ៖ www.camma.com.kh
ហ្វេសប៊ុក ៖ www.facebook.com/camma.MFI

**ការិយាល័យប្រតិបត្តិការ**

ផ្ទះលេខ ១០១អា ផ្លូវ២៨៩ សង្កាត់បឹងកក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ
ទូរស័ព្ទ៖ ០៨៩ ៩៩៩ ១៩៣

**សាខាស្រុកអង្គស្នួល**

ផ្ទះលេខ ៣៨អា១ ផ្លូវជាតិលេខ៤ ភូមិស្វាយជ្រុំ ឃុំបែកចាន ស្រុកអង្គស្នួល ខេត្តកណ្តាល
ទូរស័ព្ទ៖ ០៨៩ ៩៩៩ ១៧៤

**សាខាក្រុងតាខ្មៅ**

ផ្លូវលេខ១១៥ ភូមិព្រែកសំរោង សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្តាល
ទូរស័ព្ទ៖ ០៨៩ ៦៦៦ ០០៣

**សាខាស្រុកគងពិសី**

ផ្ទះលេខ អា៧ ផ្លូវជាតិលេខ៣ ភូមិក្របីត្រាំ ឃុំជង្រុក ស្រុកគងពិសី ខេត្តកំពង់ស្ពឺ
ទូរស័ព្ទ៖ ០៨៩ ៦៦៦ ០០៤

**សាខាខេត្តកំពង់ស្ពឺ**

ផ្លូវជាតិលេខ៤ ភូមិក្រាំងពលទេព សង្កាត់រការធំ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ
ទូរស័ព្ទ៖ ០៨៩ ៦៦៦ ៤០០

**សាខាស្រុកស្អាង**

ផ្លូវជាតិលេខ២១ ភូមិត្រើយត្រឹង្ស ឃុំព្រែកអំបិល ស្រុកស្អាង ខេត្តកណ្តាល
ទូរស័ព្ទ៖ ០៨៩ ៩៩៩ ៤០២

**សាខាស្រុកកំពង់ត្រាច**

ផ្លូវជាតិលេខ៣៣ ភូមិកំពង់ត្រាចទី២ ឃុំកំពង់ត្រាចខាងលិច ស្រុកកំពង់ត្រាច ខេត្តកំពត
ទូរស័ព្ទ៖ ០៨៩ ៩៩៩ ៤៦១

ដៃគូហិរញ្ញវត្ថុដ៏ល្អបំផុត

Excellent Financial Partner

**ការិយាល័យកណ្តាល**

ផ្ទះលេខ ១០១អា ផ្លូវ២៨៩ សង្កាត់បឹងកក់ទី១ ខណ្ឌទួលគោក

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ៖ ០១៧ ៩០៧ ៥៥៥ | ០៩៨ ៩០៧ ៥៥៥

អ៊ីម៉ែល៖ info@camma.com.kh | គេហទំព័រ៖ www.camma.com.kh